01210665

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 02 / 03 / 2016
ម៉ោង (Time/Heure): 14:55
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

D239/1/8

# ភាគនាមប្រជារាស្ត្រខ្មែរ និងភាគនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

**សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ ១៩)**

**ចំពោះមុខ:** ចៅក្រម ប្រាក់ គីមសាន ជាប្រធាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន័យ ថុល
ចៅក្រម Steven J. BWANA
ចៅក្រម ហួត វុទ្ធី

**កាលបរិច្ឆេទ:** ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦

---

## សម្ងាត់

## សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រេចដាក់អ្នកស្រីឲ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ

---

**សហព្រះរាជអាជ្ញា:**
ជា លាង
Nicholas KOUMJIAN

**សហមេធាវី អ៊ឹម ចែម**
ប៊ិត ស៊ាងលីម
John R.W.D. JONES

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ហុង គីមសួន
គីម ម៉េងឃី
ម៉ុច សុវណ្ណារី
សំ សុគង់
ទី ស្រីនណា
វ៉ែន ពៅ
Linda BEHNKE
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Martine JACQUIN
Emmanuel JACOMY
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN

Laure DESFORGES　　　Beini YE

Herve DIAKIESE

01210667



**អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "បណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អ៊ឹម ចែម ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រេចដាក់អ្នកស្រីឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ*" ដែលបានដាក់ជាភាសាអង់គ្លេសនៅថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៥ និងជាភាសាខ្មែរនៅថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៥ ("បណ្តឹងឧទ្ធរណ៍")[1]។

## I. សេចក្តីផ្តើម

1. បណ្តឹងឧទ្ធរណ៍នេះ ពាក់ព័ន្ធនឹងដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលបានចេញនៅថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៥ "សម្រេចដាក់ អ៊ឹម ចែម ឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ*" ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភលើក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦, ជូនដំណឹងអ្នកស្រីអំពីបទចោទប្រកាន់ តាមរយៈការជូនដំណឹងអំពីបទចោទជាលាយលក្ខណ៍អក្សរ ដែលបានប្រគល់ទៅឱ្យសហមេធាវីការពារក្តីរបស់អ្នកស្រី និងអនុញ្ញាតឱ្យសហមេធាវីការពារក្តីរបស់អ្នកស្រីចូលពិនិត្យមើលសំណុំរឿង ("ដីកាសម្រេចដែលរងការជំទាស់")[2]។

## ក. សាវតារ

2. នៅថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ ទៅការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលនៅក្នុងនោះ គាត់បានចោទប្រកាន់ថា អ៊ឹម ចែម ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនានានៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក[3]។ ការចោទប្រកាន់បន្ថែមទៀតប្រឆាំងនឹងអ្នកស្រី មានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមចំនួនពីរ ដែលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមមួយ បានដាក់នៅ

---

[1] បណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អ៊ឹម ចែម ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រេចដាក់អ្នកស្រីឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ* ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ D239/1/2 ("បណ្តឹងឧទ្ធរណ៍")។

[2] ដីកាសម្រេចដាក់ អ៊ឹម ចែម ឱ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ D239 ("ដីកាសម្រេចដែលរងការជំទាស់")។ ឧបសម្ព័ន្ធសម្ងាត់៖ ការជូនដំណឹងអំពីបទចោទប្រកាន់ប្រឆាំង អ៊ឹម ចែម ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ D239.1 ("ការជូនដំណឹងអំពីបទចោទ")។

[3] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ របស់សហព្រះរាជអាជ្ញា ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ឯកសារ D1។ សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី អំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី៣ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៩ ឯកសារ D1/1។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C • C.E.T.C

ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១[4] និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមមួយទៀត បាន ដាក់នៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤[5]។

3. នៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេត បានដាក់បញ្ចូលក្នុងសំណុំ ឯកសារនូវការខ្វែងយោបល់គ្នាសម្ងាត់ អនុលោមតាមវិធាន ៧២ នៃវិធានផ្ទៃក្នុង[6]។

4. នៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានកោះហៅ អ៊ឹម ចែម ឲ្យចូលបង្ហាញខ្លួនលើកដំបូងនៅ អ.វ.ត.ក នៅថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៤ ("ដីកាកោះ")[7]។ នៅថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៤ ដីកាកោះនេះត្រូវបានប្រគល់ដោយផ្ទាល់ទៅឲ្យ អ៊ឹម ចែម ដែលបានបដិសេធមិនចុះហត្ថលេខាលើលិខិតទទួលស្គាល់ការប្រគល់ដីកាកោះនេះឡើយ[8]។

5. ចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៤ សហមេធាវីបានជំទាស់ទៅនឹងសុពលភាពនៃដីកាកោះនេះ នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត និងបានជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេត អន្តរជាតិថា ពួកគាត់បដិសេធមិនចូលរួមក្នុងការបង្ហាញខ្លួនលើកដំបូងរបស់កូនក្តីពួកគាត់នៅពេល នេះទេ[9] ដោយលើកទឡ្ហីករណ៍ថា សហចៅក្រមស៊ើបអង្កេតចាំបាច់ត្រូវតែឆ្លើយតបជាមុនសិនទៅ នឹងសំណើរបស់ពួកគាត់ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៤ ដែលនៅក្នុងសំណើនោះ ពួក គាត់ស្នើសុំឲ្យមានការបញ្ជាក់បំភ្លឺ "ទាក់ទិននឹងបញ្ហាថាតើ សហចៅក្រមស៊ើបអង្កេតមានការខ្វែង យោបល់គ្នា ឬយ៉ាងណា ចំពោះការកោះហៅ និងការចោទប្រកាន់កូនក្តីរបស់យើង និងការបញ្ជាក់

---

[4] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការ ធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១ ឯកសារ D65។

[5] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអំពើហិង្សាយេនឌ័រ ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ D191។

[6] កំណត់ហេតុនៃការខ្វែងយោបល់គ្នា ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៤។

[7] ដីកាកោះឲ្យបង្ហាញខ្លួនលើកដំបូង ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ A150 ("ដីកាកោះ")។

[8] កំណត់ហេតុនៃការប្រគល់ដីកាកោះ ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ A150/1។

[9] លិខិតឆ្លើយតបទៅនឹងដីកាកោះអញ្ជើញមេធាវី ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ A151/2។ សំណើសុំបន្ទាន់របស់អ្នកស្រី អ៊ឹម ចែម ស្នើសុំឲ្យបញ្ជូនសំណើសុំមោឃភាពដីកាកោះហៅអ្នកស្រី និងសហ មេធាវីការពារក្តីគាត់ ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៤ ទៅអង្គបុរេជំនុំជម្រះ ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ D207 ("សំណើសុំមោឃភាព")។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

ថា បញ្ហានេះ "នឹងត្រូវដាក់ជូនដើម្បីស្វែងរកដំណោះស្រាយ អនុលោមតាមវិធាន ៧២ នៃវិធានផ្ទៃក្នុង" ("សំណើសុំការបញ្ជាក់បំភ្លឺ")[10]។ នៅថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបញ្ជាក់ជាថ្មីថា ដីកាកោះ គឺមានសុពលភាព ហើយថា តាមផ្លូវច្បាប់ អ៊ឹម ចែម តម្រូវឱ្យចូលបង្ហាញខ្លួននៅ អ.វ.ត.ក នៅថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៤[11]។ នៅថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបដិសេធសំណើសុំការបញ្ជាក់បំភ្លឺ និងបានអះអាងជាថ្មីថា "ការអនុវត្តរបស់ ស.ច.ស នៅក្នុងសំណុំរឿង ០០៤ គឺគោរពទាំងស្រុងតាមបទប្បញ្ញត្តិពាក់ព័ន្ធនានា និងស្មារតីទូទៅនៃច្បាប់ដែលចែងអំពីការស៊ើបអង្កេតនៅ អ.វ.ត.ក"[12]។

6. នៅថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៤ សហមេធាវី បានស្នើសុំព្យួរការអនុវត្តដីកាកោះហៅអ្នកស្រី អ៊ឹម ចែម នៅចំពោះមុខអង្គបុរេជំនុំជម្រះ[13]។ សំណើសុំនេះ ត្រូវបានបដិសេធដោយអង្គបុរេជំនុំជម្រះ

---

[10] ញត្តិរបស់ អ៊ឹម ចែម ស្នើសុំឱ្យមានការស្រាយបំភ្លឺ ទាក់ទិននឹងការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ D204 ទំព័រ ១។ សូមមើល ការឆ្លើយឆ្លងពីមុនរវាងសហមេធាវី និងសហចៅក្រមស៊ើបអង្កេត ទាក់ទិននឹងនីតិវិធីសម្រាប់ដាក់ឱ្យស្ថិតក្រោមការពិនិត្យ ៖ សំណើសុំបញ្ចូលសហចៅក្រមស៊ើបអង្កេតទាំងពីររូបនៅក្នុងទំនាក់ទំនងទាំងអស់ជាផ្លូវការ ទាក់ទិននឹងអ្នកស្រី អ៊ឹម ចែម និងស្នើថា ការខ្វែងយោបល់គ្នាមួយចំនួនដែលទាក់ទិននឹងការកោះហៅ និងការចោទប្រកាន់លើអ្នកស្រី អ៊ឹម ចែម គួរត្រូវបានបញ្ជូនទៅកាន់អង្គបុរេជំនុំជម្រះ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ A122 ទំព័រ ២។ លិខិតរបស់លោកស្នើសុំឱ្យបញ្ចូលសហចៅក្រមស៊ើបអង្កេតទាំងពីររូបទៅក្នុងទំនាក់ទំនងទាំងអស់ជាផ្លូវការ ទាក់ទិននឹងអ្នកស្រី អ៊ឹម ចែម និងស្នើថាការខ្វែងយោបល់គ្នាមួយចំនួនដែលទាក់ទិននឹងការកោះហៅ និងការចោទប្រកាន់លើអ្នកស្រី អ៊ឹម ចែម គួរត្រូវបានបញ្ជូនទៅកាន់អង្គបុរេជំនុំជម្រះ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ A122/1។

[11] លិខិតរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ៖ លិខិតរបស់លោក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៤ ទាក់ទិននឹងការកោះអញ្ជើញលោកឱ្យចូលរួមក្នុងការបង្ហាញខ្លួនលើកដំបូងរបស់កូនក្ដីរបស់លោក ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ A151/2/1។

[12] ដីកាសម្រេចលើញត្តិរបស់ជនសង្ស័យស្នើសុំឱ្យមានការស្រាយបំភ្លឺ ទាក់ទិននឹងការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ D204/2 កថាខណ្ឌ ១១។ សំណើសុំមោឃភាព ត្រូវបានបដិសេធនៅថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៤ ដោយផ្អែកទៅលើការពុំមានសិទ្ធិ។ សូមមើល ដីកាសម្រេចលើសំណើបន្ទាន់របស់អ្នកស្រី អ៊ឹម ចែម ស្នើសុំឱ្យបញ្ជូនសំណើសុំមោឃភាពដីកាកោះហៅអ្នកស្រី និងសហមេធាវីការពារក្ដីគាត់ទៅអង្គបុរេជំនុំជម្រះ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ D207/1 កថាខណ្ឌ ៣២។

[13] សំណើបន្ទាន់របស់អ្នកស្រី អ៊ឹម ចែម សុំព្យួរការអនុវត្តដីកាកោះហៅអ្នកស្រី អ៊ឹម ចែម ឱ្យមកបង្ហាញខ្លួនជាលើកដំបូង ចុះកាលបរិច្ឆេទថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៥ ប៉ុន្តែដាក់នៅថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៥ ឯកសារ A122/6.1/1។

នៅថ្ងៃដដែលនោះដែរ[14]។

7. នៅថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៤ អ៊ឹម ចែម មិនបានចូលមកបង្ហាញខ្លួនលើកដំបូងតាមកាលកំណត់ឡើយ[15]។ នៅថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១៤ សហមេធាវីបានជូនដំណឹងទៅសហចៅក្រមស៊ើបអង្កេតអន្តរជាតិថា កូនក្តីរបស់ខ្លួនពុំព្រមចូលបង្ហាញខ្លួនឆ្លើយតបទៅនឹងដីកាកោះ ដែលចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់នោះឡើយ[16]។

8. នៅថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចេញដីកាបង្គាប់ឲ្យនាំខ្លួន ដើម្បីធានាឲ្យមានការចូលបង្ហាញខ្លួនលើកដំបូងរបស់ អ៊ឹម ចែម នៅ អ.វ.ត.ក ("ដីកាបង្គាប់ឲ្យនាំខ្លួន")[17]។ នៅថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៤ ដីកាបង្គាប់ឲ្យនាំខ្លួននេះ ត្រូវបានបញ្ជូនទៅឲ្យនគរបាលយុត្តិធម៌កម្ពុជាដើម្បីយកទៅអនុវត្ត[18]។

9. នៅថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៥ បន្ទាប់ពីមានការព្យាយាមមួយចំនួនដើម្បីឲ្យមានការអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួននេះរួចមក[19] សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសរសេរលិខិតមួយជូនទៅប្រធានគណៈកម្មការសន្តិសុខសម្រាប់ អ.វ.ត.ក ដោយបញ្ជាក់ថា ដោយសារថាការពន្យាពេលបន្ថែមទៀតអាចបង្កើតឲ្យមានហានិភ័យដែលមិនអាចទទួលយកបាននោះ គាត់នឹងសម្រេចដាក់ អ៊ឹម ចែម ឲ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ* ប្រសិនបើអ្នកស្រីមិនចូលបង្ហាញខ្លួននៅ អ.វ.ត.ក ឲ្យបានមុនថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឬក៏ប្រសិនបើអ្នកស្រីមិនត្រូវបាននាំខ្លួនមកនៅ

---

[14] សេចក្តីសម្រេចលើសំណើបន្ទាន់របស់អ្នកស្រី អ៊ឹម ចែម សុំព្យួរការអនុវត្តដីកាកោះហៅអ្នកស្រីឲ្យមកបង្ហាញខ្លួនជាលើកដំបូង ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ A122/6.1/2 (សេចក្តីសម្រេច) និងថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ A122/6.1/3 (សំអាងហេតុ)។

[15] កំណត់ត្រារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទាក់ទិននឹងការបង្ហាញខ្លួនលើកដំបូងរបស់ អ៊ឹម ចែម ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ A150/2។

[16] ការឆ្លើយឆ្លងតាមអ៊ីម៉ែលរវាងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងសហមេធាវីអន្តរជាតិ នៅថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៤ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ A150/2/2.1។

[17] ដីកាបង្គាប់ឲ្យនាំខ្លួន ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ C1។

[18] របាយការណ៍ស្តីពីការប្រគល់ដីកាបង្គាប់ឲ្យនាំខ្លួនជូននគរបាលយុត្តិធម៌ ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ C1.1។

[19] *សូមមើល* ដីកាសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២៣-២៩។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

ត្រឹមកាលបរិច្ឆេទនោះទេ[20]។

10. កាលបរិច្ឆេទថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៥ បានកន្លងផុត ដោយគ្មានការចូលបង្ហាញខ្លួនរបស់ អ៊ឹម ចែម នៅចំពោះមុខ អ.វ.ត.ក ឬការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួននោះឡើយ ដូច្នេះហើយនៅថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចេញដីកាសម្រេចដែលរងការជំទាស់ ដែលនៅក្នុងដីកាសម្រេចនោះ គាត់បានសម្រេចដាក់ អ៊ឹម ចែម ឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* និងបានបង្គាប់ឱ្យក្រឡាបញ្ជីចាត់វិធានការចាំបាច់ដើម្បីផ្តល់សិទ្ធិឱ្យសហមេធាវីរបស់ អ៊ឹម ចែម ចូលពិនិត្យមើលសំណុំរឿង ០០៤ ឱ្យបានឆាប់តាមដែលអាចធ្វើបាន។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានរៀបរាប់លម្អិតអំពីបទចោទប្រឆាំង អ៊ឹម ចែម ដែលរួមមានការចោទប្រកាន់អំពីការរំលោភបំពានលើក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ និងឧក្រិដ្ឋកម្មមួយចំនួនប្រឆាំងនឹងមនុស្សជាតិ នៅក្នុងឧបសម្ព័ន្ធដាច់ដោយឡែកមួយភ្ជាប់ជាមួយនឹងដីកាសម្រេចដែលរងការជំទាស់នេះ[21]។ ដីកាសម្រេចដែលរងការជំទាស់ រួមទាំងការជូនដំណឹងអំពីបទចោទប្រកាន់ផងដែរនោះ ត្រូវបានប្រគល់ជូនសហមេធាវី នៅថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៥។

11. នៅថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៥ អង្គបុរេជំនុំជម្រះបានសម្រេចជាឯកច្ឆ័ន្ទបដិសេធចោលបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើញត្តិសុំពិចារណាឡើងវិញ និងសុំលុបចោលដីកាកោះចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ ដោយសន្និដ្ឋានថាមិនអាចទទួលយកបានទេ[22]។

## ខ. បណ្តឹងឧទ្ធរណ៍

12. សហមេធាវីបានដាក់បណ្តឹងឧទ្ធរណ៍ជាភាសាអង់គ្លេសនៅថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៥ និងជាភាសាខ្មែរនៅថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៥។ នៅថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ អង្គបុរេ

[20] លិខិតផ្ញើជូនប្រធានគណៈកម្មការសន្តិសុខសម្រាប់ អ.វ.ត.ក ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៥ ឯកសារ D238 ទំព័រ ២។

[21] ការជូនដំណឹងអំពីបទចោទប្រកាន់ ។

[22] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើញត្តិសុំពិចារណាឡើងវិញ និងសុំលុបចោលដីកាកោះចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ D236/1/1/8។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C • C.E.T.C

01210672



ជំនុំជម្រះបានទទួលស្គាល់សុពលភាពនៃបណ្តឹងឧទ្ធរណ៍ ដែលបានដាក់ជាភាសាខ្មែរហួសពេលកំណត់ ហើយបណ្តឹងឧទ្ធរណ៍ត្រូវបានដាក់ទៅក្នុងសំណុំរឿង និងជូនដំណឹងទៅដល់ភាគីទាំងអស់ ទាំងពីរភាសា[23]។ មេធាវីការពារក្តីអះអាងថា បណ្តឹងឧទ្ធរណ៍ អាចទទួលយកបាន អនុលោមតាមវិធាន ២១ និង ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង ហើយថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសអង្គច្បាប់ និងបានប្រព្រឹត្ត *ហួសពីដែនអំណាច* នៅក្នុងការដាក់ អ៊ឹម ចែម ឲ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ*[24]។ ដូច្នេះ សហមេធាវីស្នើសុំឲ្យអង្គបុរេជំនុំជម្រះ៖ ក) ទទួលយកបណ្តឹងឧទ្ធរណ៍នេះ ខ) ច្រានចោលកថាខណ្ឌ ៣៩, ៤០, ៤២-៤៦, ៥៧-៥៨, ៧៣ (ផ្នែកខ្លះ) និងកថាខណ្ឌ ៧៦ នៃដីកាសម្រេចដែលរងការជំទាស់ ទាក់ទិននឹងការចោទប្រកាន់ អ៊ឹម ចែម ដែលដីកាសម្រេចនេះមានកំហុសអង្គច្បាប់ និង គ) ទុកជាមោឃៈការជូនដំណឹងអំពីបទចោទប្រកាន់ដែល *ហួសពីដែនអំណាច*[25]។

13. សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ចម្លើយតបមួយទៅនឹងបណ្តឹងឧទ្ធរណ៍នេះជាភាសាអង់គ្លេស នៅថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥ និងជាភាសាខ្មែរនៅថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៥ ("ចម្លើយតប")[26] ដោយសារមានការអនុញ្ញាតកាលពីមុនដោយអង្គបុរេជំនុំជម្រះ[27]។ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា បណ្តឹងឧទ្ធរណ៍នេះ គឺអាចទទួលយកបាន អនុលោមតាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង[28] ប៉ុន្តែវាពុំមានខ្លឹមសារអ្វីឡើយ ដោយសារតែដីកាសម្រេចដែលរងការជំទាស់នោះ ត្រូវបានសម្រេចឡើងយ៉ាងត្រឹមត្រូវ និងស្របទៅនឹងច្បាប់ពាក់ព័ន្ធទាំងអស់[29]។

---

[23] នៅថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៥ សហមេធាវីបានស្នើសុំការអនុញ្ញាតដាក់បណ្តឹងឧទ្ធរណ៍ជាភាសាអង់គ្លេសជាមុនសិន ដោយដាក់សំណៅបកប្រែជាភាសាខ្មែរតាមក្រោយ។ សំណើនេះមិនអាចយកមកពិចារណានៅពេលនោះបានទេ ដោយសារតែអង្គបុរេជំនុំជម្រះមិនទាន់ត្រូវបានបង្កើតឡើងពេញលេញនៅឡើយទេ។

[24] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២។

[25] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២។

[26] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ប្រឆាំងនឹងដីកាសម្រេចដាក់ឲ្យគាត់ស្ថិតនៅក្រោមការពិនិត្យដោយកំបាំងមុខ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ D239/1/6 ("ចម្លើយតប")។

[27] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំពន្យាពេលកំណត់ក្នុងការឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម និងសំណើពាក់ព័ន្ធនានារបស់មេធាវីការពារក្តី ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ D239/1/5 ទំព័រ ៣។

[28] ចម្លើយតប កថាខណ្ឌ ១២។

[29] ចម្លើយតប កថាខណ្ឌ ១។

14. សហមេធាវីបានដាក់ការឆ្លើយតបមួយជាភាសាអង់គ្លេសនៅថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០១៥ និង ជាភាសាខ្មែរនៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៥ ("ការឆ្លើយតប")[30] ដោយសារមានការអនុញ្ញាត កាលពីមុនដោយអង្គបុរេជំនុំជម្រះ[31]។

## II. ភាពអាចទទួលយកបាន

15. សហមេធាវីអះអាងថា បណ្តឹងឧទ្ធរណ៍នេះ គឺអាចទទួលយកបាន អនុលោមតាមវិធាន ២១(១) និង ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង[32]។ សហព្រះរាជអាជ្ញាអន្តរជាតិទទួលស្គាល់ថា បណ្តឹងឧទ្ធរណ៍ នេះ គឺអាចទទួលយកបាន អនុលោមតាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង។

16. អនុលោមតាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង "ជនត្រូវចោទ" អាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា ឬសេចក្តីសម្រេចមួយចំនួនដែលត្រូវបានកំណត់ របស់សហចៅក្រមស៊ើបអង្កេត រួមមាន សេចក្តី សម្រេចដែល "បញ្ជាក់ពីយុត្តាធិការរបស់ អ.វ.ត.ក" ។

17. វិធាន ២១(១) នៃវិធានផ្ទៃក្នុង ដែលមានចំណងជើងថា "គោលការណ៍ជាសារវ័ន្ត" ចែងបន្ថែម ទៀតនៅក្នុងផ្នែកពាក់ព័ន្ធ ថា៖

> "១. ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជា រដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានានូវអំពីសច្ចភាពផ្លូវច្បាប់ និង កិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះ វិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ និង កិច្ចព្រមព្រៀង។ ក្នុងបរិបទនេះ៖

---

[30] ការឆ្លើយតបរបស់អ្នកស្រី អ៊ឹម ចែម ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិចំពោះបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាសម្រេចដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យដោយកំបាំងមុខ ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារ D239/1/7 ("ការឆ្លើយ តប")។

[31] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំពន្យារពេលកំណត់ក្នុងការឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ របស់ អ៊ឹម ចែម និងសំណើពាក់ព័ន្ធនានារបស់មេធាវីការពារក្តី ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ D239/1/5 កថាខណ្ឌ ៣។

[32] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៣។

> ក) ដំណើរការនីតិវិធីក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ។ នីតិវិធីត្រូវធានាឱ្យបាននូវភាពដាច់ដោយឡែកពីគ្នារវាងអាជ្ញាធរដែលទទួលបន្ទុកការចោទប្រកាន់ និង អាជ្ញាធរដែលទទួលបន្ទុកការវិនិច្ឆ័យទោស"។

អង្គបុរេជំនុំជម្រះធ្លាប់បានសម្រេចពីមុនថា គោលការណ៍ជាសារវ័ន្តដែលមានចែងនៅក្នុងវិធាននេះ ដែលឆ្លុះបញ្ចាំងនូវលក្ខខណ្ឌតម្រូវនៃការជំនុំជម្រះក្តីដោយយុត្តិធម៌ដែលថា អ.វ.ត.ក មានកាតព្វកិច្ចត្រូវអនុវត្ត អនុលោមតាមមាត្រា ១៣(១) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ("កិច្ចព្រមព្រៀង")[33], មាត្រា ៣៥*ថ្មី* នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[34] និងមាត្រា ១៤(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ICCPR")[35] អាចតម្រូវឱ្យធ្វើការបកស្រាយសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ក្នុងន័យទូលាយ ដើម្បីធានាថា ដំណើរការនិតិវិធីមានភាពយុត្តិធម៌ និងគោរពគោលការណ៍ចំពោះមុខ[36]។ នៅក្នុងករណីដ៏កម្រដែលអង្គហេតុពិសេសនៃរឿងក្តីមួយ បានលើកឡើងនូវបញ្ហាសិទ្ធិជា

---

[33] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៣។

[34] ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ រួមជាមួយនឹងច្បាប់វិសោធនកម្ម ដែលប្រកាសឱ្យប្រើចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤។

[35] *សូមមើល ឧទា.* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស ("សំណុំរឿង ០០២") (អបជ៦៤) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធសំណើសុំអនុញ្ញាតថតសំឡេង/រូបភាពវីដេអូនៃការជួបជាមួយលោក អៀង សារី នៅក្នុងមន្ទីរឃុំឃាំង ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារ A371/2/12 ("សាលដីកាលើសំណើសុំថតសំឡេង/រូបភាពរបស់ អៀង សារី") កថាខណ្ឌ ១៣-១៨ និង ២៧។

[36] *សូមមើល ឧទា.* សំណុំរឿង ០០២ (អបជ១១) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគី ទាក់ទងនឹងការបកប្រែ ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៨ ឯកសារ A190/I/20 កថាខណ្ឌ ៣៦។ សំណុំរឿង ០០២ (អបជ៧១) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស បដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង និងសេចក្តីសង្ខេបបន្ថែម និងសំណើសុំផ្អាកដំណើរការនីតិវិធី ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារ D390/1/2/4 ("សាលដីកាស្តីពីចម្លើយតបរបស់ អៀង សារី") កថាខណ្ឌ ១៣។ សំណុំរឿង ០០២ (អបជ១៤) សាលដីកាលើការជូនដំណឹងរបស់មេធាវីការពារក្តីអំពីការបកប្រែ មានកំហុសឆ្គង ថ្ងៃទី ១៧ ខែ [illegible] ឯកសារលេខ

សារវ័ន្ត ឬបញ្ហាធ្ងន់ធ្ងរនៃភាពត្រឹមត្រូវនៃដំណើរការនីតិវិធី អង្គបុរេជំនុំជម្រះបានទទួលយកបណ្តឹងឧទ្ធរណ៍ អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង[37] ឬបានបកស្រាយយ៉ាងទូលំទូលាយនូវបទប្បញ្ញត្តិជាក់លាក់នៃវិធានផ្ទៃក្នុង ដែលផ្តល់យុត្តាធិការទៅឱ្យអង្គជំនុំជម្រះ[38]។ ទោះបីជាយ៉ាងណាក៏ដោយ អង្គបុរេជំនុំជម្រះបានរំលឹកជារឿយៗថា វិធាន ២១ នៃវិធានផ្ទៃក្នុង មិនបានផ្តល់ការអនុញ្ញាតឱ្យប្តឹងឧទ្ធរណ៍ដោយស្វ័យប្រវត្តិឡើយ ទោះបីជាបណ្តឹងឧទ្ធរណ៍លើកឡើងនូវបញ្ហានៃការជំនុំជម្រះក្តី ដោយយុត្តិធម៌ក៏ដោយ[39]។ ដើម្បីឱ្យអង្គបុរេជំនុំជម្រះពិចារណាលើបណ្តឹងឧទ្ធរណ៍ អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង ម្ចាស់បណ្តឹងឧទ្ធរណ៍ចាំបាច់ត្រូវបង្ហាញថា ស្ថានភាពដែលជាបញ្ហាចោទនេះ មិនស្ថិតនៅក្នុងវិធានជាធរមានឡើយ ហើយថា កាលៈទេសៈពិសេសនៃរឿងក្តី តម្រូវឱ្យមានអន្តរាគមន៍ពីអង្គជំនុំជម្រះ ដើម្បីបញ្ចៀសកុំឱ្យមានព្យសនកម្ម*ដែលមិនអាចជួសជុលបាន* ចំពោះភាពយុត្តិធម៌នៃការស៊ើបអង្កេត ឬកិច្ចដំណើរការនីតិវិធី ឬចំពោះសិទ្ធិជាមូលដ្ឋានរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍[40]។

---

D2 ("សាលដីកាស្តីពីកំហុសឆ្គងក្នុងការបកប្រែ") កថាខណ្ឌ ៣។ សំណុំរឿង ០០២ (អបជ៧៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ៤៩។

[37] *សូមមើល ឧទា.* សំណុំរឿង ០០២ (អបជ៤២) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត បដិសេធលើសំណើសុំមោឃភាព និងព្យួរកិច្ចស៊ើបសួរដោយមូលហេតុរំលោភនីតិវិធី (D264/1) ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១០ ឯកសារ D264/2/6 កថាខណ្ឌ ១៣-១៤។ សាលដីកាលើចម្លើយតបរបស់ អៀង សារី កថាខណ្ឌ ១៣ និងសាលដីកាស្តីពីកំហុសឆ្គងនៃការបកប្រែ កថាខណ្ឌ ២-៦។

[38] *សូមមើល ឧទា.* សំណុំរឿង ០០២ (អបជ០៥) សេចក្តីសម្រេចស្តីពីភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍របស់ អៀង សារី អំពីសិទ្ធិចូលជួប ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៨ ឯកសារ A104/II/4 កថាខណ្ឌ ១០។

[39] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ តាអាន ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើរបស់គាត់ស្នើសុំព័ត៌មានទាក់ទងនឹងករណីខ្វែងយោបល់គ្នារបស់សហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៣ ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ ឯកសារ D208/1/1/2 កថាខណ្ឌ ៨។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើសំណើរបស់ជនសង្ស័យទាក់ទងនឹងដីកាកោះ ដែលចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ D117/1/1/2 កថាខណ្ឌ ១៥។

[40] *សូមមើល ឧទា.* សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អវតក/កសចស ("សំណុំរឿង ០០៤") (អបជ១៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ តា អាន ប្រឆាំងដីកាសម្រេចបដិសេធសំណើរបស់គាត់ស្នើសុំព័ត៌មានទាក់ទងនឹងករណីខ្វែងយោបល់គ្នា

18. អង្គបុរេជំនុំជម្រះ ជាបឋម នឹងធ្វើការពិនិត្យថាតើបណ្តឹងឧទ្ធរណ៍នេះ អាចទទួលយកបានដែរ ឬទេ អនុលោមតាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង ដែលកំណត់យ៉ាងច្បាស់នូវមូលដ្ឋានសម្រាប់បណ្តឹងឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះ មុនពេលធ្វើការពិចារណាអំពីភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍នេះ អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង ប្រសិនបើចាំបាច់។

## ក. វិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង

19. សហមេធាវីអះអាងថា ដីកាសម្រេចដែលរងការជំទាស់ គឺជាសេចក្តីសម្រេចមួយដែល "បញ្ជាក់ពីយុត្តាធិការរបស់ អ.វ.ត.ក" ដូច្នេះហើយដីកាសម្រេចនេះ អាចប្តឹងឧទ្ធរណ៍បាន អនុលោមតាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង[41]។ ជាពិសេស សហមេធាវីអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានប្រព្រឹត្ត *ហួសពីដែនអំណាច* នៅពេលគាត់បញ្ជាក់ថា គាត់មានយុត្តាធិការបុគ្គល យុត្តាធិការពេលវេលា និងយុត្តាធិការតាមកម្មវត្ថុ ទៅលើ អ៊ឹម ចែម តាមរយៈការចេញដីកាសម្រេចដែលរងការជំទាស់ និងដាក់គាត់ឲ្យស្ថិតក្រោមការពិនិត្យ[42]។

20. សហព្រះរាជអាជ្ញាអន្តរជាតិ ឆ្លើយតបថា ដោយសារតែ អ៊ឹម ចែម ត្រូវបានពិចារណាយ៉ាងត្រឹមត្រូវថាជាជនត្រូវចោទមួយរូបនោះ បណ្តឹងឧទ្ធរណ៍នេះគឺអាចទទួលយកបាន អនុលោមតាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង[43]។

21. អង្គបុរេជំនុំជម្រះយល់ឃើញថា ទឡ្ហីករណ៍របស់សហមេធាវី មិនគួរឲ្យជឿជាក់បានឡើយ។ ដីកាសម្រេចដែលរងការជំទាស់ មិន "បញ្ជាក់" ពីយុត្តាធិការរបស់ អ.វ.ត.ក *លើបុគ្គល លើរឿងក្តី តាមពេលវេលា និងទីកន្លែង* ឡើយ ហើយបណ្តឹងឧទ្ធរណ៍នេះទៀតសោត មិនបានលើកឡើងនូវការជំទាស់ណាមួយ ទាក់ទិននឹងបញ្ហានេះទេ។ ទោះបីជាយ៉ាងណាក៏ដោយ អង្គបុរេជំនុំជម្រះ

---

របស់សហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៣ ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ ឯកសារ D208/1/1/2 កថាខណ្ឌ ៨។

[41] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៩-២០។

[42] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២០។

[43] ចម្លើយតប កថាខណ្ឌ ១២។

នឹងពិនិត្យថាតើ បណ្ដឹងឧទ្ធរណ៍នេះ ស្ថិតនៅក្នុងវិសាលភាពនៃវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង សម្រាប់ហេតុផលផ្សេងៗទៀត ដែរឬទេ។

22. ជាទូទៅ សញ្ញាណនៃបណ្ដឹងជំទាស់យុត្តាធិការ ត្រូវបានគេយល់ថាជាការតវ៉ាចំពោះសមត្ថកិច្ច របស់តុលាការ *លើបុគ្គល លើរឿងក្ដី តាមពេលវេលា និងទីកន្លែង*[44]។ ទោះបីជាយ៉ាងណាក៏ដោយ តុលាការអន្តរជាតិនានា ក្នុងករណីមួយចំនួន បានអនុម័តនិយមន័យយ៉ាងទូលំទូលាយមួយ នៅក្នុងការពិចារណាអំពីអង្គហេតុដែលថា i) តុលាការទាំងនោះដំណើរការនៅក្របខ័ណ្ឌមួយដែលច្បាប់ជាធរមាន មិនសូវមានលក្ខណៈលម្អិតដូចនៅក្នុងយុត្តាធិការជាតិ និងតែងតែមិនមែនស្ថិតនៅក្រោមការបកស្រាយមុនៗ[45] និង ii) តុលាការទាំងនោះ ពុំមានរចនាសម្ព័ន្ធកណ្ដាល ហើយដំណើរការជាប្រព័ន្ធមួយឯករាជ្យ ដែលអាចនាំឲ្យមានបញ្ហាសំខាន់ៗដែលត្រូវទុកចោលមិនទាន់បានដោះស្រាយរហូតដល់ចុងបញ្ចប់នៃកិច្ចដំណើរការនីតិវិធី[46]។ នៅក្នុងរឿងក្ដី *Tadić*[47] អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានសម្រេចថា “យុត្តាធិការ មិនមែនត្រឹមតែជាវិសាលភាព ឬដែនប៉ុណ្ណោះទេ (នៅក្នុងករណីនេះ គួរពិពណ៌នាថាជា “សមត្ថកិច្ច”)។ ជាមូលដ្ឋាន ពាក្យនេះមានប្រភពដើមចេញពីភាសាឡាតាំង *jurisdictio* ដែលមានន័យថាជាអំណាចផ្លូវច្បាប់ ដូច្នេះវាជាអំណាចធម្មានុរូប “ក្នុងការបកស្រាយច្បាប់” (*dire le droit*) ក្នុងកម្រិតវិសាលភាពនេះ នៅក្នុងលក្ខណៈស្ថាពរ និងតាមអាជ្ញាព្រឹត្ត”[48]។ ការអនុម័តការបកស្រាយក្នុងន័យទូលាយទៅលើសញ្ញាណនៃ “យុត្តាធិការ” អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានសម្រេចនៅក្នុងរឿងក្ដី *Tadić* ថា បណ្ដឹងជំទាស់ទៅនឹងនីត្យានុកូលភាពនៃការបង្កើតតុលាការ គឺជាការជំទាស់មួយដោយផ្អែកទៅលើកង្វះយុត្តាធិការ[49]។ នៅ អ.វ.ត.ក អនុលោមតាមវិធាន ៧៤(៣)(ក)នៃ

---

[44] សំណុំរឿង ០០២ (អបជ ៣៥) សាលដីកាលើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ ឯកសារ D97/14/15 កថាខណ្ឌ ២២។

[45] សំណុំរឿង ០០២ (អបជ៣៥) សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ ឯកសារ D97/14/15 កថាខណ្ឌ ២២។

[46] រឿងក្ដី រដ្ឋអាជ្ញា ទល់នឹង *Tadic* សំណុំរឿង Case IT-94-1-AR72 សាលដីកាលើញត្តិរបស់មេធាវីការពារក្ដីស្នើសុំប្ដឹងឧទ្ធរណ៍បន្ទាន់បង្ខំលើយុត្តាធិការ អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៩៥ កថាខណ្ឌ ៦, ១១។

[47] ដូចយោងខាងលើ។

[48] ដូចយោងខាងលើ កថាខណ្ឌ ១០។

[49] ដូចយោងខាងលើ កថាខណ្ឌ ៦ និង ១២។

វិធានផ្ទៃក្នុង អង្គជំនុំជម្រះនេះ បានទទួលយកបណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដែលត្រូវបានរកឃើញថាបានបញ្ជាក់យុត្តាធិការរបស់ អ.វ.ត.ក យ៉ាងច្បាស់ទៅលើទម្រង់នៃការទទួលខុសត្រូវ[50]។

23. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា នៅក្នុងដីកាសម្រេចដែលរងការជំទាស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានព្យាយាមលើកឡើងនូវស្ថានភាពមួយដែលគាត់យល់ថាជាការពុំអាចប្រមើលដឹងមុនបាន នៅក្នុងវិធានដែលចែងអំពីកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក។ ដូច្នេះ វាមិនមែនជាការគួរឱ្យភ្ញាក់ផ្អើលឡើយដែលថា ដីកាសម្រេចដែលរងការជំទាស់នេះ មិនបំពេញលក្ខខណ្ឌឱ្យបានពេញលេញនៅក្នុងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ដែលកំណត់អំពីយុត្តាធិការលើបណ្តឹងឧទ្ធរណ៍របស់អង្គបុរេជំនុំជម្រះ។ មានការកត់សម្គាល់បន្ថែមទៀតថា សេចក្តីសម្រេចនោះ ត្រូវបានធ្វើឡើង *តាមឆន្ទៈរបស់ខ្លួនឯងផ្ទាល់* ដូច្នេះកិច្ចដំណើរការនីតិវិធីលើបណ្តឹងឧទ្ធរណ៍ទាំងនេះ គឺជាឱកាសដំបូងសម្រាប់ភាគីក្នុងការបង្ហាញនូវទស្សនៈរបស់ខ្លួនអំពីបញ្ហានេះ ដែលចាំបាច់ត្រូវដោះស្រាយឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ពីព្រោះវាអាចមានអានុភាពទៅលើការបន្តកិច្ចដំណើរការនីតិវិធីតទៅទៀតប្រឆាំងនឹង អ៊ឹម ចែម។ ដោយពិចារណាលើគោលការណ៍ជាសារវ័ន្តនៅក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង ដែលចែងថា វិធានផ្ទៃក្នុងត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនត្រូវចោទ និងដើម្បីធានានូវអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធី "ដោយយុត្តិធម៌ និងគោរពគោលការណ៍ចំពោះមុខ" អង្គបុរេជំនុំជម្រះយល់ឃើញថា នៅក្នុងរឿងក្តីនេះ វាជាការត្រឹមត្រូវក្នុងការអនុម័តការបកស្រាយក្នុងន័យទូលាយទៅលើសិទ្ធិប្តឹងឧទ្ធរណ៍ អនុលោមតាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង[51] និងពិនិត្យលើភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ ដោយ

---

[50] *សូមមើល ឧទា.* សំណុំរឿង ០០២ (អបជ៣៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ ឯកសារ D97/14/15 កថាខណ្ឌ ២២-២៤។

[51] *សូមមើល ឧទា.* STL, CH/AC/2010/02 សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ចៅក្រមអង្គបុរេជំនុំជម្រះ ទាក់ទិននឹងយុត្តាធិការ និងសិទ្ធិ អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១០ កថាខណ្ឌ ៥៤៖ "អង្គជំនុំជម្រះតុលាការកំពូល ជាធម្មតា នឹងមិនពិចារណាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទំ ដែលស្ថិតនៅក្រៅវិសាលភាពនៃវិធានឡើយ ប៉ុន្តែយល់ឃើញថា វាចាំបាច់ដែលត្រូវធ្វើការពិចារណាក្នុងករណីដែលស្ថានភាពមួយបានកើតឡើង ដែលមិនត្រូវបានប្រមើលដឹងជាមុនដោយវិធាននោះ ហើយមានការចោទប្រកាន់ថា កំហុសផ្នែកយុត្តាធិការត្រូវបានប្រព្រឹត្តឡើង ហើយអាចនាំឱ្យមានភាពអយុត្តិធម៌ ប្រសិនបើកំហុសនោះ បន្សល់ទុកមិនមានការកែតម្រូវនោះ"។

ពិចារណាទៅលើនិយមន័យនៃ "យុត្តាធិការ" ដែលកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY នៅក្នុងរឿងក្តី *Tadić* ។

24. នៅក្នុងដីកាសម្រេចដែលរងការជំទាស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពិនិត្យថាតើត្រូវបន្តកិច្ចដំណើរការនីតិវិធីបែបណា អនុលោមតាមច្បាប់ ដើម្បីដាក់ អ៊ឹម ចែម ឱ្យស្ថិតក្រោមការពិនិត្យ ដោយសារតែពុំមានបទប្បញ្ញត្តិច្បាស់លាស់ចែងអំពីផលវិបាកនៃអវត្តមានរបស់អ្នកស្រីនៅពេលបង្ហាញខ្លួនលើកដំបូងនោះ។ បន្ទាប់ពីស្វែងរកការណែនាំនៅក្នុងវិធានស្តីពីនីតិវិធីដែលបានបង្កើតឡើងនៅកម្រិតអន្តរជាតិរួចមក សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសន្និដ្ឋានថា គាត់មានអំណាចក្នុងការដាក់ អ៊ឹម ចែម ឱ្យស្ថិតក្រោមការពិនិត្យ *"ដោយកំបាំងមុខ"*។ ដោយសារថាដីកាសម្រេចដែលរងការជំទាស់នេះ ពិនិត្យទៅលើអំណាចតាមផ្លូវច្បាប់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៅក្នុងកាលៈទេសៈដែលគាត់បានបង្ហាញថាមាន *បញ្ហាចន្លោះប្រហោង* នៅក្នុងច្បាប់ជាធរមាននៅចំពោះមុខ អ.វ.ត.ក អង្គបុរេជំនុំជម្រះយល់ឃើញថា វាជាសេចក្តីសម្រេចមួយ "ដែលបញ្ជាក់ពីយុត្តាធិការរបស់ អ.វ.ត.ក" នៅពេលបកស្រាយយ៉ាងទូលាយនោះ។

25. ដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា បណ្តឹងឧទ្ធរណ៍នេះ គឺអាចទទួលយកបាន អនុលោមតាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង ដែលបកស្រាយដោយពិចារណាទៅលើវិធាន ២១ នៃវិធានផ្ទៃក្នុង។

### ខ. វិធាន ២១(១) នៃវិធានផ្ទៃក្នុង

26. សហមេធាវីក៏បានអះអាងផងដែរថា បណ្តឹងឧទ្ធរណ៍នេះ គឺអាចទទួលយកបាន អនុលោមតាមវិធាន ២១(១) នៃវិធានផ្ទៃក្នុង ដើម្បីការពារសិទ្ធិរបស់ អ៊ឹម ចែម ក្នុងការទទួលបាននូវសច្ចភាពផ្លូវច្បាប់[52]។ សហមេធាវីជំទាស់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ខកខានមិនបានអនុវត្តច្បាប់ដែលអាចព្យាករណ៍បាន និងច្បាស់លាស់ ដោយសារគាត់បានប្រើ "ច្បាប់កម្ពុជាដោយខុសច្បាប់នៅពេលវិធានផ្ទៃក្នុង មិនបានលើកឡើងអំពីបញ្ហាដែលពុំអាចដោះស្រាយបាន និងជាបន្តបន្ទាប់គាត់បានស្វែងរកការណែនាំនៅក្នុងនីតិវិធីព្រហ្មទណ្ឌអន្តរជាតិដែលមិនចាំបាច់ ខណៈដែលច្បាប់កម្ពុជាមានចែងយ៉ាងច្បាស់អំពីបញ្ហានេះ"[53] ដែលជាការរំលោភលើមាត្រា ១២ នៃកិច្ចព្រមព្រៀង។

[52] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៧។

[53] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៧។

27. សហព្រះរាជអាជ្ញាអន្តរជាតិ ពុំបានឆ្លើយតបទៅនឹងទឡ្ហីករណ៍ដែលបានលើកឡើងដោយសហមេធាវី ទាក់ទិននឹងភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុងឡើយ[54]។

28. ដោយសារតែការសន្និដ្ឋានពីមុនរបស់ខ្លួនថា បណ្តឹងឧទ្ធរណ៍នេះ អាចទទួលយកបាន អនុលោមតាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុងនោះ អង្គបុរេជំនុំជម្រះយល់ឃើញថា អង្គបុរេជំនុំជម្រះមិនចាំបាច់ពិចារណាទឡ្ហីករណ៍អំពីភាពអាចទទួលយកបាន អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុងទេ។

## III. បទដ្ឋាននៃការពិនិត្យឡើងវិញ

29. អនុលោមតាមយុត្តិសាស្ត្រដែលបានបង្កើតដោយអង្គបុរេជំនុំជម្រះ ដីកាសម្រេចរបស់ "សហចៅក្រមស៊ើបអង្កេត" អាចត្រូវបានច្រានចោល ប្រសិនបើដីកាសម្រេចនោះ ក) បានផ្អែកលើកំហុសនៃអង្គច្បាប់ ដែលនាំឱ្យមោឃៈដីកាសម្រេចនោះ ខ) បានផ្អែកលើកំហុសនៃអង្គហេតុដែលនាំឱ្យដីកាសម្រេចនោះមានភាពមិនយុត្តិធម៌ ឬ គ) មានភាពអយុត្តិធម៌ ឬមិនសមហេតុផលខ្លាំង ដែលបង្កើតបានជាការបំពានលើឆន្ទានុសិទ្ធិរបស់ចៅក្រម"[55]។ ទាំងសហមេធាវី[56] ទាំងសហព្រះរាជអាជ្ញាអន្តរជាតិ[57] យល់ស្របទៅនឹងបទដ្ឋាននេះ។

## IV. អង្គសេចក្តី

30. បន្ទាប់ពីពិភាក្សារួចមក ចៅក្រមនៃអង្គបុរេជំនុំជម្រះមិនអាចរកបានមតិភាគច្រើនដើម្បីធ្វើសេចក្តីសម្រេចទៅលើអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍នេះបានឡើយ។

---

[54] សហព្រះរាជអាជ្ញាអន្តរជាតិ គ្រាន់តែពិភាក្សាអំពីលក្ខខណ្ឌតម្រូវផ្លូវច្បាប់សម្រាប់ភាពអាចទទួលយកបាន ស្របតាម វិធាន ២១ នៃវិធានផ្ទៃក្នុង អនុលោមតាមយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ។ សូមមើល ចម្លើយតប កថាខណ្ឌ ៦។

[55] សាលដីកាលើសំណើសុំថតសំឡេង/រូបភាពរបស់ អៀង សារី កថាខណ្ឌ ២២។

[56] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៩។

[57] ចម្លើយតប កថាខណ្ឌ ១១។



PRE-TRIAL CHAMBER • E.C.C.C • C.E.T.C • CHAMBRE PRELIMINAIRE

01210681



31. ដូច្នេះ ទោះបីជាសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះចំពោះភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍នេះ មានបញ្ជាក់យ៉ាងច្បាស់នៅក្នុងកថាខណ្ឌខាងមុខយ៉ាងណាក៏ដោយ ក៏មានការភ្ជាប់បន្ថែមមកជាមួយនូវយោបល់ដាច់ដោយឡែករបស់ចៅក្រមនានានៃអង្គបុរេជំនុំជម្រះ ទាក់ទិននឹងអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍ តាមលក្ខខណ្ឌតម្រូវនៃវិធាន ៧៧(១៤) នៃវិធានផ្ទៃក្នុង។

## សេចក្តីសម្រេច

**យោងនៅលើហេតុផលទាំងនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆ័ន្ទថា៖**

១. បណ្តឹងឧទ្ធរណ៍នេះ អាចទទួលយកបាន អនុលោមតាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង ដែលត្រូវបកស្រាយដោយពិចារណាទៅលើវិធាន ២១ នៃវិធានផ្ទៃក្នុង។

២. **ប្រកាសថា** អង្គបុរេជំនុំជម្រះមិនអាចរកបានសម្លេងគាំទ្រពីចៅក្រម ៤(បួន)រូប យ៉ាងតិច ដើម្បីចេញសេចក្តីសម្រេចមួយទៅលើអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍នេះបានឡើយ។

**រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន** **Oliver BEAUVALLET** **ន័យ ធុល** **Steven J. BWANA** **ហួត វុទ្ធី**

ចៅក្រម **ប្រាក់ គឹមសាន** ចៅក្រម **ន័យ ធុល** និងចៅក្រម **ហួត វុទ្ធី** ភ្ជាប់បន្ថែមនូវមតិយោបល់របស់ខ្លួន ទាក់ទិននឹងបណ្តឹងឧទ្ធរណ៍។

ចៅក្រម **Oliver BEAUVALLET** និងចៅក្រម **Steven J. BWANA** ភ្ជាប់បន្ថែមនូវមតិយោបល់របស់ខ្លួន ទាក់ទិននឹងបណ្តឹងឧទ្ធរណ៍។

**មតិយោបល់របស់ចៅក្រម ប្រាក់ គីមសាន ចៅក្រម ន៉យ ថុល និងចៅក្រម ហួត វុទ្ធី**

**ក. ប្រវត្តិនីតិវិធី**

1. នៅថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៥ អង្គបុរេជំនុំជម្រះ បានទទួលបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តីឱ្យអ្នកស្រី អ៊ឹម ចែម ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សម្រេចដាក់អ្នកស្រី អ៊ឹម ចែម ឱ្យស្ថិតក្រោមការត្រួតពិនិត្យកំបាំងមុខ ដែលចេញនៅថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៥ "បណ្តឹងឧទ្ធរណ៍"[58]។

2. នៅថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៥ សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំពន្យាពេលកំណត់ក្នុងការឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម[59] ហើយអង្គបុរេជំនុំជម្រះ ចេញសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំពន្យាពេលកំណត់ក្នុងការឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម អនុញ្ញាតពន្យាពេល ១០ ថ្ងៃសម្រាប់សហព្រះរាជអាជ្ញាដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ត្រឹមថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥[60]។

3. នៅថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ប្រឆាំងនឹងដីកាសម្រេចដាក់ឱ្យគាត់ស្ថិតក្រោមការពិនិត្យកំបាំងមុខ[61]។ បន្ទាប់មកនៅថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០១៥ សហមេធាវីការពារក្តីឱ្យអ្នកស្រី អ៊ឹម ចែម បានដាក់ចម្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ[62]។

---

[58] បណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អ៊ឹម ចែម ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រេចដាក់អ្នកស្រីឱ្យស្ថិតក្រោមការត្រួតពិនិត្យកំបាំងមុខ ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៥ (ឯកសារលេខ៖ D239/1/2)។

[59] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំពន្យាពេលកំណត់ក្នុងការឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណរបស់ អ៊ឹម ចែម ចុះថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ ២០១៥ (ឯកសារលេខ៖ D239/1/3)។

[60] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំពន្យាពេលកំណត់ក្នុងការឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៥ (ឯកសារលេខ៖ D239/1/5)។

[61] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ប្រឆាំងនឹងដីកាសម្រេចដាក់ឱ្យគាត់ស្ថិតក្រោមការពិនិត្យកំបាំងមុខ ចុះថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០១៥ (ឯកសារលេខ៖ D239/1/6)។

[62] ចម្លើយតបរបស់សហមេធាវីការពារក្តីឱ្យអ្នកស្រី អ៊ឹម ចែម ទៅនឹងចម្លើយតបសហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០១៥ (ឯកសារលេខ៖ D239/1/7)។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

**ខ.និត្យានុកូលភាពនៃបណ្តឹងឧទ្ធរណ៍**

4. ចៅក្រមជាតិ នឹងបង្ហាញអំពីមតិយោបល់ទៅលើបញ្ហានីតិវិធីដែលមានពេលនេះ។ យ៉ាងណាក៏ដោយ ជាការចាប់ផ្តើម យើងសូមធ្វើការបញ្ជាក់អំពីការយល់ឃើញរបស់យើងចំពោះការផ្សព្វផ្សាយជាសាធារណៈនៃសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ។

5. អនុលោមតាមមាត្រា ៣.១២ នៃសេចក្តីណែនាំអនុវត្ត អ.វ.ត.ក ផ្តល់សិទ្ធិឱ្យអ្នកស្រី អ៊ឹម ចែម អាចស្នើសុំមកអង្គបុរេជំនុំជម្រះធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញជា "សាធារណៈ" នូវឯកសារ "សំងាត់" ឬ "សំងាត់បំផុត" ដោយអនុលោមតាមបទប្បញ្ញត្តិនៃសេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងសំណុំរឿង។

6. មាត្រា ៣.១២ វាក្យខណ្ឌទី២ នៃសេចក្តីណែនាំអនុវត្ត អ.វ.ត.ក បានចែងថា "តាមករណីសមស្រប ទាល់តែមានការចេញដីកាដំណោះស្រាយ និងសេចក្តីសម្រេចប្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាដំណោះស្រាយ ទើបសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះត្រូវពិនិត្យពិចារណា ថាតើចំណាត់ថ្នាក់ប្រភេទឯកសារដែលបានស្នើសុំនោះមានលក្ខណៈសមស្របដែរឬទេ ហើយបើសិនជាមិនសមស្របទេ ត្រូវធ្វើសេចក្តីសម្រេចថាតើចំណាត់ប្រភេទអ្វីទើបសមស្រប"។

7. ផ្អែកតាមទឡ្ហីករណ៍ខាងលើ ចៅក្រមជាតិ យល់ឃើញថា ការធ្វើចំណាត់ថ្នាក់ឯកសារ "សម្ងាត់" ទៅជា "សាធារណៈ" នៅពេលនេះ គឺពុំទាន់មានភាពចាំបាច់ ហើយក៏មិននាំឱ្យប៉ះពាល់សិទ្ធិ និងផលប្រយោជន៍របស់អ្នកស្រី អ៊ឹម ចែម ដែរ ព្រោះទោះបីឯកសារនោះជាប្រភេទ "ឯកសារសម្ងាត់" ក៏អ្នកស្រី អ៊ឹម ចែម អាចមើលឯកសារទាំងនោះបានដែរ។ ហេតុដូចនេះ អង្គបុរេជំនុំជម្រះ គប្បីពិចារណាលើការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ នៅពេលចេញដីកាដំណោះស្រាយ និងសេចក្តីសម្រេចប្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាដំណោះស្រាយ អនុលោមតាមមាត្រា ៣.១២ វាក្យខណ្ឌទី២ នៃសេចក្តីណែនាំអនុវត្ត អ.វ.ត.ក។

8. សហមេធាវីការពារក្តីឱ្យអ្នកស្រី អ៊ឹម ចែម បានលើកឡើងនូវទឡ្ហីករណ៍ថា អត្ថន័យធម្មតាដោយសុទ្ធចិត្តនៃវិធាន ៥៧ តម្រូវថា វត្តមានជាក់ស្តែងរបស់អ្នកស្រី អ៊ឹម ចែម ក្នុងពេលបង្ហាញខ្លួនលើកដំបូង គឺជាបុរេលក្ខខណ្ឌដើម្បីឱ្យចៅក្រម Harmon ធ្វើការចោទប្រកាន់លើរូបអ្នក

ស្រីបាន។ តុលាការអាចធ្វើការចោទប្រកាន់លើជនសង្ស័យបានតែ "នៅពេលចូលបង្ហាញខ្លួនលើកដំបូង" តែប៉ុណ្ណោះ ដែលការចូលបង្ហាញខ្លួននេះ ត្រូវបានកំណត់និយមន័យនៅក្នុងសន្ទានុក្រមនៃវិធានផ្ទៃក្នុង ថាជាការ "សំដៅទៅលើការបង្ហាញខ្លួនលើកដំបូងរបស់ជនត្រូវចោទនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត"[63]។

9. សហមេធាវីការពារក្តីឱ្យអ្នកស្រី អ៊ឹម ចែម បានលើកឡើងនូវទឡ្ហីករណ៍បន្ថែមថា មិនមានការពាក់ព័ន្ធគ្នាទេ ចំពោះការដែលចៅក្រម Harmon យោងលើមាត្រា ៣៣៣ មាត្រា ៣៥១ មាត្រា ៣៦១ និងមាត្រា ៣៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលមាត្រាទាំងនេះ អនុវត្តបានតែនៅក្នុងដំណាក់កាលជំនុំជម្រះប៉ុណ្ណោះ។ តាមពិតបទប្បញ្ញត្តិទាំងនេះបង្ហាញថា អ្នករៀបចំសេចក្តីព្រាងក្រមនីតិវិធីកម្ពុជា មិនមានគោលបំណងឱ្យមានករណីលើកលែងនូវលក្ខខណ្ឌតម្រូវក្នុងការមានវត្តមានរបស់ជនសង្ស័យនៅពេលចោទប្រកាន់នោះទេ។ ដូចដែលបានលើកឡើងខាងលើ អ្នកពង្រាងក្រម គួរត្រូវគេសន្មត់បានពីការមានចេតនា និងបំណងក្នុងពេលគាត់បញ្ចូលភាសាណាមួយដាក់ទៅក្នុងផ្នែកមួយ ប៉ុន្តែលុបចោលនៅក្នុងផ្នែកផ្សេងវិញ។ម្យ៉ាងវិញទៀត នៅក្នុងច្បាប់ស៊ីវិល ដែលជាច្បាប់មួយអាស្រ័យស្ទើរតែទាំងស្រុងលើវិធានតាមក្រម ជាហេតុធ្វើឱ្យករណីលើកលែងត្រូវតែបានបកស្រាយក្នុងន័យចង្អៀត[64]។

10. សហមេធាវីការពារក្តីឱ្យអ្នកស្រី អ៊ឹម ចែម បានបញ្ជាក់ថា ច្បាប់បារាំងក៏បង្ហាញផងដែរថា ជនសង្ស័យត្រូវតែបង្ហាញខ្លួននៅពេលត្រូវធ្វើការចោទប្រកាន់។ មាត្រា ៨០-១ មាត្រា ៨០-២ និងមាត្រា ១១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ជាបទប្បញ្ញត្តិសំខាន់ដែលបានចែងទាក់ទងនឹងដំណើរការចោទប្រកាន់នៅក្នុងតុលាការប្រទេសបារាំង។ ចៅក្រម Harmon បានភាន់ច្រឡំក្នុងការសំអាងលើមាត្រាទាំងបីនេះ។ ក្នុងក្រមនីតិវិធីបារាំង ចៅក្រមស៊ើបសួរអាចចោទប្រកាន់លើជនសង្ស័យ តែក្រោយពីការចូលបង្ហាញខ្លួនលើកដំបូងរបស់ជននោះតែប៉ុណ្ណោះ និងបន្ទាប់ពីចៅក្រមបានសួរចម្លើយ ឬបន្ទាប់ពីបានផ្តល់ឱកាសឱ្យជននោះ ធ្វើសេចក្តីថ្លែងការណ៍ហើយ។ ការប្រើប្រាស់ឱកាសនេះទៅបាន លុះណាតែជនសង្ស័យចូលបង្ហាញខ្លួនជាក់ស្តែងនៅចំពោះមុខចៅក្រមស៊ើបសួរ។ ក្រោយពីជនសង្ស័យបញ្ចេញយោបល់ (ឬ បានជ្រើសយកជម្រើសនៅស្ងៀម

---

[63] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី ៣៤ (ឯកសារលេខ៖ D239/1/2)។

[64] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី ៤៧ (ឯកសារលេខ៖ D239/1/2)។

មិនឆ្លើយតបទៅនឹងសំណួរ) ទើបចៅក្រមស៊ើបសួរអាចធ្វើការសម្រេចចិត្តថា តើត្រូវចោទប្រកាន់ ឬមិនចោទប្រកាន់លើជនរូបនោះ[65]។

11. វិធាន ៥៧ នៃវិធានផ្ទៃក្នុងចែងថា នៅពេលជនត្រូវចោទចូលបង្ហាញខ្លួន ចំពោះមុខសហចៅក្រមស៊ើបអង្កេតជាលើកដំបូង សហចៅក្រមស៊ើបអង្កេតត្រូវកត់ត្រាទុកនូវអត្តសញ្ញាណរបស់ជននោះ និង ប្រាប់ជននោះអំពីបទចោទប្រកាន់ និង អំពីសិទ្ធិមានមេធាវី និង សិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយនឹងសំណួរ។ ជនត្រូវចោទមានសិទ្ធិពិគ្រោះជាមួយមេធាវីមុនពេលដែលខ្លួនត្រូវបានសួរចម្លើយ និងមានមេធាវីអមជាមួយនៅក្នុងពេលសួរចម្លើយ។ ប្រសិនបើជនត្រូវចោទយល់ព្រមឆ្លើយនោះ សហចៅក្រមស៊ើបអង្កេតត្រូវធ្វើការសួរចម្លើយនោះភ្លាម។

12. តាមវិធាន ៥៧ នៃវិធានផ្ទៃក្នុងខាងលើ បានចែងយ៉ាងច្បាស់ពីការបង្ហាញខ្លួនលើកដំបូងរបស់ជនត្រូវចោទ គឺត្រូវបង្ហាញខ្លួនដោយផ្ទាល់ និងកំណត់ពីកាតព្វកិច្ចរបស់សហចៅក្រមស៊ើបអង្កេតក្នុងការប្រាប់ជននោះអំពីបទចោទប្រកាន់ និង អំពីសិទ្ធិមានមេធាវី និង សិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយនឹងសំណួរ។

13. ដោយគិតដល់លក្ខណៈពិសេសរបស់តុលាការនេះ ផលប្រយោជន៍របស់ជនសង្ស័យ និងជនត្រូវចោទ ត្រូវតែការពារជានិច្ច ដើម្បីធានានូវសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព។ សិទ្ធិក្នុងការទទួលបានសច្ចភាពផ្លូវច្បាប់តម្រូវថា ច្បាប់ត្រូវតែអាចព្យាករបាន និងមានន័យច្បាស់លាស់ ព្រមទាំងមានប្រសិទ្ធិភាពក្នុងការអនុវត្តក្នុងលក្ខណៈមួយដែលអាចទប់ស្កាត់មិនឲ្យមានការធ្វើសេចក្ដីសម្រេចតាមទំនើងចិត្ត[66]។

14. មាត្រា ១២ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ បានចែងថា នីតិវិធីត្រូវសមស្របជាមួយច្បាប់កម្ពុជា។ នៅពេលណាដែលច្បាប់កម្ពុជា ពុំអាចដោះស្រាយបានចំពោះបញ្ហាពិសេសណាមួយ ឬមានភាពមិនច្បាស់លាស់ទាក់ទងទៅនឹងការបកស្រាយ ឬការអនុវត្តបទប្បញ្ញត្តិនាដែលពាក់ព័ន្ធក្នុងច្បាប់កម្ពុជា ឬក៏មានបញ្ហា

---

[65] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌទី ៥១ (ឯកសារលេខ៖ D239/1/2)។

[66] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌទី ១៥ (ឯកសារលេខ៖ D239/1/2)។

ទាក់ទងទៅនឹងភាពសមស្របគ្នា រវាងបទប្បញ្ញត្តិបែបនេះ ទៅនឹងបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ។

15. ច្បាប់ស្តីពីនីតិវិធីរបស់ អ.វ.ត.ក ត្រូវតែអនុវត្តដោយអាចព្យាករបាន និងមានភាពច្បាស់លាស់ អនុលោមតាមមាត្រា ១២ នៃកិច្ចព្រមព្រៀង។ ខ្លឹមសារសំខាន់ៗដោយអនុលោមតាមកិច្ចព្រមព្រៀងនេះគឺ (ក) វិធានផ្ទៃក្នុងមានមូលដ្ឋានគ្រឹះខ្ពស់ជាងគេក្នុងការកំណត់នីតិវិធី (ខ) វិធាននីតិវិធីសម្រាប់ប្រទេសកម្ពុជា អាចអនុវត្តលុះត្រាតែមានបញ្ហាចោទណាមួយ ពុំអាចដោះស្រាយបាននៅក្នុងវិធានផ្ទៃក្នុងតែប៉ុណ្ណោះ និង (គ) ចៅក្រមអាចស្វែងរកការណែនាំឱ្យអនុវត្តនៅក្នុងវិធាននីតិវិធីព្រហ្មទណ្ឌអន្តរជាតិ ល្គឹកណាដែលច្បាប់របស់ប្រទេសកម្ពុជាមិនមានចែងពីបញ្ហាចោទណាមួយទាក់ទិនការបកស្រាយច្បាប់ ឬមានបញ្ហាទាក់ទងនឹងភាពស្របគ្នាជាមួយនឹងបទដ្ឋានអន្តរជាតិ។ ការស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីអន្តរជាតិ អាចធ្វើបានតែក្នុងករណីចាំបាច់ និងសមស្របតែប៉ុណ្ណោះ[67]។

16. ផ្អែកតាមកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ, ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ និងវិធានផ្ទៃក្នុង គឺបង្កើតឡើងគោរពនូវគោលការណ៍ជំនុំជម្រះក្តីប្រកបដោយភាពយុត្តិធម៌ ជាពិសេសគោលការណ៍ចំពោះមុខ។ ស្តែងចេញពីគោលការណ៍នេះ ទើបវិធាន ៥៧ នៃវិធានផ្ទៃក្នុង តម្រូវឱ្យមានវត្តមានជនត្រូវចោទដោយផ្ទាល់ នៅចំពោះមុខសហចៅក្រមស៊ើបអង្កេតនៅពេលបង្ហាញខ្លួនលើកដំបូង ហើយសហចៅក្រមស៊ើបអង្កេត ត្រូវដាក់ជនត្រូវចោទឱ្យស្ថិតក្រោមការពិនិត្យដោយចំពោះមុខដែរ។ វាជាការមិនសមស្របឡើយ ប្រសិនបើអង្គបុរេជំនុំជម្រះ ទទួលស្គាល់ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ថាជាការត្រឹមត្រូវ ដែលរំលោភលើវិធានមួយដែលចែងយ៉ាងច្បាស់នៅក្នុងបទប្បញ្ញត្តិនៃក្រមច្បាប់ អ.វ.ត.ក និងវិធានផ្ទៃក្នុង។

---

[67] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី ១៦ (ឯកសារលេខ៖ D239/1/2)។

01210687



17. ផ្អែកតាមទឡ្ហីករណ៍ខាងលើ ច្បាប់ និងវិធាន ៥៧ នៃវិធានផ្ទៃក្នុង បានកំណត់យ៉ាងច្បាស់ អំពីនីតិវិធីរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការដាក់ជនត្រូវចោទឱ្យស្ថិតក្រោមការពិនិត្យ *ដោយចំពោះមុខ* ហេតុដូច្នេះអង្គបុរេជំនុំជម្រះមិនចាំបាច់ស្វែងរកច្បាប់ ឬយុត្តិសាស្ត្រតុលាការជាតិ ឬតុលាការអន្តរជាតិ មកអនុវត្តលើបញ្ហានេះឡើយ។ បន្ថែមពីនេះទៅទៀត ទោះបីពិនិត្យមើលយុត្តិសាស្ត្រតុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀត ក៏មិនធ្លាប់អនុវត្តនីតិវិធីនៃការដាក់ជនត្រូវចោទឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ* ឡើយ គឺមានតែនីតិវិធីជំនុំជម្រះ *ដោយកំបាំងមុខ* តែប៉ុណ្ណោះ។

18. លើសពីនេះទៅទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនទាន់បានអនុវត្តឱ្យអស់លទ្ធភាពនូវកិច្ចស៊ើបសួរដែលវិធានផ្ទៃក្នុងផ្តល់សិទ្ធិអំណាចឱ្យ ក្នុងការធានានូវវត្តមានរបស់ជនត្រូវចោទនៅចំពោះខ្លួននៅឡើយ។

19. ហេតុដូច្នេះ ចៅក្រមជាតិ យល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពុំមានសិទ្ធិក្នុងការដាក់អ្នកស្រី អ៊ឹម ចែម ដាក់ឱ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខទេ។

**ភ្នំពេញ ថ្ងៃទី ០១ ខែមីនា ឆ្នាំ២០១៦**

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C • C.E.T.C.

**ប្រធាន ប្រាក់ គីមសាន** | **ចៅក្រម ន៉ី ថុល** | **ចៅក្រម ហួត វុទ្ធី**

## មតិយោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BWANA ("ចៅក្រមដែលបានចុះហត្ថលេខា") ស្តីអំពីអង្គសេចក្តីនៃមូលដ្ឋាន ខ នៃបណ្តឹងឧទ្ធរណ៍

1. យើងជាចៅក្រមដែលបានចុះហត្ថលេខាខាងក្រោមនេះ នឹងបង្ហាញអំពីមតិយោបល់របស់យើងទៅលើបញ្ហានីតិវិធីដែលមានពេលនេះ។ យ៉ាងណាក៏ដោយ ជាការចាប់ផ្តើម យើងសូមធ្វើការបញ្ជាក់អំពីការយល់ឃើញរបស់យើងចំពោះការផ្សព្វផ្សាយជាសាធារណៈនៃសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ។

2. វិធាន ៧៨ នៃវិធានផ្ទៃក្នុងចែងថា រាល់សេចក្តីសម្រេចដែលមានសំឡេងគាំទ្រគ្រប់គ្រាន់ និងរាល់សេចក្តីសម្រេចដែលមិនមានសម្លេងគាំទ្រគ្រប់គ្រាន់របស់អង្គបុរេជំនុំជម្រះ រួមទាំងមតិជំទាស់ផង ត្រូវបោះពុម្ពផ្សាយទាំងស្រុង លើកលែងតែអង្គបុរេជំនុំជម្រះសម្រេចថា ការបោះពុម្ពផ្សាយនោះអាចប៉ះពាល់ដល់ផលប្រយោជន៍នៃការអង្កេតបឋម ឬការស៊ើបសួរ។

3. ដូចនេះ ជាគោលការណ៍ វិធាន ៧៨ នៃវិធានផ្ទៃក្នុង និង មាត្រា ៤(ង) នៃសេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងសំណុំរឿង តម្រូវឱ្យមានការផ្សព្វផ្សាយជាសាធារណៈនូវសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ។ អាស្រ័យហេតុនេះ ខ្លឹមសារនៃសេចក្តីសម្រេច ឬមតិយោបល់ ដែលមិនប៉ះពាល់ដល់ផលប្រយោជន៍នៃការស៊ើបសួរ មិនគួរមានការកោសលុបឡើយ។

4. យើងយល់ឃើញថា សេចក្តីសម្រេចណាមួយរបស់អង្គជំនុំជម្រះទាក់ទិននឹងចំណាត់ប្រភេទឯកសារ ដែលប្រាសចាកពីគោលការណ៍ផ្សព្វផ្សាយជាសាធារណៈដូចដែលមានចែងនៅក្នុងវិធាន ៧៨ នៃវិធានផ្ទៃក្នុង ត្រូវតែធ្វើឡើងដោយមានសំអាងផ្លូវច្បាប់គ្រប់គ្រាន់ ដើម្បីប្រានចោលគោលការណ៍ដែលបានបញ្ជាក់ជូនខាងលើ។

5. អនុលោមតាមគោលការណ៍នៃការផ្សព្វផ្សាយជាសាធារណៈនៃសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ដូចដែលមានចែងនៅក្នុងវិធាន ៧៨ នៃវិធានផ្ទៃក្នុង យើងរក្សាសិទ្ធិក្នុងការផ្សព្វផ្សាយសំណៅ (កោសលុប) ជាសាធារណៈនៃមតិយោបល់នេះ នៅក្នុងករណីសមស្រប។

6. នៅក្នុងដីកាសម្រេចដែលរងការជំទាស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចថា "ច្បាប់ដែលអាចអនុវត្តបាននៅ អ.វ.ត.ក អនុញ្ញាតឱ្យដាក់ជនសង្ស័យឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ* នៅពេលដែលជនសង្ស័យបានបដិសេធមិនចូលបង្ហាញខ្លួនលើកដំបូង អនុលោមតាមវិធាន ៥៧ នៃវិធានផ្ទៃក្នុង និងនៅពេលដែលកិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់មកទៀតដើម្បីធានាថា ជនសង្ស័យមានវត្តមាន មិនបានទទួលលទ្ធផល"[68]។ នៅក្នុងការធ្វើសេចក្តីសន្និដ្ឋាននេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ជាបឋម បានពិចារណាថា វិធាន ៥៧ នៃវិធានផ្ទៃក្នុង មិនបានដាក់បុរេលក្ខខណ្ឌថា ជនសង្ស័យត្រូវបង្ហាញខ្លួនលើកដំបូង ដើម្បីឱ្យមានការដាក់ជនសង្ស័យនោះឱ្យស្ថិតក្រោមការពិនិត្យឡើយ ប៉ុន្តែ បានសន្និដ្ឋានថា វិធានផ្ទៃក្នុងមិនបានចែងអំពីនីតិវិធីក្នុងការដាក់ឱ្យស្ថិតក្រោមការពិនិត្យទៅលើជនសង្ស័យណា ដែលបានបដិសេធមិនចូលបង្ហាញខ្លួនលើកដំបូង ហើយក៏មិនអាចឱ្យចូលបង្ហាញខ្លួនតាមមធ្យោបាយបង្ខំនោះឡើយ[69]។ បើងាកទៅច្បាប់កម្ពុជាវិញ[70] សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានសន្និដ្ឋានថា ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាពុំមានបទប្បញ្ញត្តិ ដែលចែងច្បាស់លាស់អំពីការដាក់ឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ*ឡើយ[71]។ ដូច្នេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានសម្រេចស្វែងរកការណែនាំនៅក្នុងវិធានស្តីពីនីតិវិធី ដែលបានបង្កើតឡើងនៅកម្រិតអន្តរជាតិ អនុលោមតាមមាត្រា ១២(១) នៃកិច្ចព្រមព្រៀង មាត្រា ២៣*ថ្មី* នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធាន ២ នៃវិធានផ្ទៃក្នុង[72]។ នៅក្នុងការសម្រេចដូច្នេះ គាត់បានសន្និដ្ឋានថា "កិច្ចដំណើរការនីតិវិធី*ដោយកំបាំងមុខ* អាចទទួលយកតាមច្បាប់សិទ្ធិមនុស្ស នៅក្នុងកាលៈទេសៈមួយចំនួន ដូចជា ជនដែលអាចស្ថិតនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ បានបដិសេធមិនចូលបង្ហាញខ្លួននៅចំពោះមុខតុលាការមានសមត្ថកិច្ច"[73] ហើយថា "វិធានស្តីពីនីតិវិធីដែលបានបង្កើតឡើងនៅកម្រិតអន្តរជាតិ អនុញ្ញាតឱ្យមានកិច្ចដំណើរការនីតិវិធី*ដោយកំបាំងមុខ* នៅពេលដែលជនណាម្នាក់ បានបង្ហាញយ៉ាងច្បាស់ និងមានជាលាយលក្ខណ៍អក្សរថាបានលះបង់សិទ្ធិមានវត្តមានរបស់គាត់ ឬនៅពេលដែលវិធានការសមហេតុផល

[68] ដីកាសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៥៨។

[69] ដីកាសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៤០។

[70] ដីកាសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៤១-៤២។

[71] ដីកាសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៤៣-៤៥។

[72] ដីកាសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៤៦។

[73] ដីកាសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៥៧(ក)។



E.C.C.C • C.E.T.C
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

ទាំងអស់ត្រូវបានអនុវត្ត រួចហើយដើម្បីធានានូវការចូលបង្ហាញខ្លួនរបស់គាត់នៅចំពោះមុខតុលាការមានសមត្ថកិច្ច និងដើម្បីជូនដំណឹងដល់គាត់អំពីបទចោទប្រកាន់ ប៉ុន្តែកិច្ចខិតខំប្រឹងប្រែងទាំងនេះ មិនទទួលបានជោគជ័យ”[74]។

7. បន្ទាប់មក សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសន្និដ្ឋានថា លក្ខខណ្ឌតម្រូវផ្លូវច្បាប់ដើម្បី “ដាក់ អ៊ឹម ចែម ឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ*” ត្រូវបានបំពេញ នៅក្នុងរឿងក្តីនេះ ដោយសារថា i) អ៊ឹម ចែម បានដឹងឮពីកាលបរិច្ឆេទ និងពេលវេលានៃការបង្ហាញខ្លួនលើកដំបូង ប៉ុន្តែមានចេតនាមិនចូលបង្ហាញខ្លួន ដូច្នេះគាត់លះបង់សិទ្ធិរបស់គាត់ក្នុងការមានវត្តមានក្នុងការបង្ហាញខ្លួនលើកដំបូង[75] ii) អ៊ឹម ចែម បានបង្ហាញថាគាត់មិនមានចេតនាចូលបង្ហាញខ្លួននៅចំពោះមុខ អ.វ.ត.ក នៅថ្ងៃណាមួយផ្សេងទៀតនោះទេ[76] និង iii) “វិធានការសមហេតុផលទាំងអស់ត្រូវបានអនុវត្តរួចហើយដើម្បីធានាឱ្យការចូលបង្ហាញខ្លួនរបស់ អ៊ឹម ចែម នៅចំពោះមុខ អ.វ.ត.ក សម្រាប់ការបង្ហាញខ្លួនលើកដំបូង អនុលោមតាមវិធាន ៥៧ នៃវិធានផ្ទៃក្នុង”[77]។ ផ្អែកទៅលើចំណុចចុងក្រោយនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានប្រកាសថា គាត់ជឿជាក់ថា “អ៊ឹម ចែម មិនលាក់ខ្លួនទេ, នគរបាលយុត្តិធម៌ដឹងពីទីកន្លែងដែល អ៊ឹម ចែម ស្នាក់នៅ, នគរបាលយុត្តិធម៌មានមធ្យោបាយជាក់ស្តែងដើម្បីអនុវត្តដីកានាំខ្លួន ហើយនគរបាលយុត្តិធម៌ មិនបានបំពេញការទទួលខុសត្រូវ ដែលបានកំណត់ដោយកិច្ចព្រមព្រៀង អ.វ.ត.ក ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុង”[78]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានសន្និដ្ឋានបន្ថែមទៀតថា ការដាក់ អ៊ឹម ចែម ឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ* គឺជាវិធីតែមួយគត់ដើម្បីធានានូវការអនុវត្តកិច្ចដំណើរការនីតិវិធីដោយយុត្តិធម៌ និងឱ្យបានឆាប់រហ័ស ពិសេសជាងនេះទៀត គឺដើម្បីបញ្ចៀសកុំឱ្យកិច្ចដំណើរការនីតិវិធី “ជាប់គាំង”[79] និងដើម្បីអនុញ្ញាតឱ្យ អ៊ឹម ចែម អនុវត្តសិទ្ធិនានាដែល

---

[74] ដីកាសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៥៧ (ឃ)។ *សូមមើល* ផងដែរ កថាខណ្ឌ ៥០-៥៦។

[75] ដីកាសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៥៩-៦២។

[76] ដីកាសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៦១-៦២។

[77] ដីកាសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៦៧។

[78] ដីកាសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៦៧។ *សូមមើល* ផងដែរ កថាខណ្ឌ ៦៣-៦៦ ដែលពិពណ៌នាអំពីវិធានការនានាដែលត្រូវបានអនុវត្តដើម្បីធានានូវកិច្ចសហការរបស់នគរបាលយុត្តិធម៌។

[79] ដីកាសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៧០។

វិធានផ្ទៃក្នុងបានផ្ដល់យ៉ាងជាក់លាក់ទៅឱ្យ "ជនត្រូវចោទ" នៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ[80]។ ដូច្នេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេច "ដាក់ អ៊ឹម ចែម ឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ*" និងបានជូនដំណឹងគាត់អំពីបទចោទប្រកាន់ តាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរដែលបានប្រគល់ទៅឱ្យសហមេធាវីរបស់គាត់។

8. សហមេធាវីអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសផ្នែកអង្គច្បាប់ និងបានអនុវត្តហួសពីអំណាចរបស់គាត់នៅក្នុងការដាក់ អ៊ឹម ចែម ឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ*[81]។ ទីមួយ សហមេធាវីអះអាងថា វិធានផ្ទៃក្នុងចែងយ៉ាងច្បាស់មិនអនុញ្ញាតឱ្យមានការដាក់ជនសង្ស័យឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ*ទេ[82] ពីព្រោះវិធាន ៥៧ នៃវិធានផ្ទៃក្នុង តម្រូវឱ្យជនសង្ស័យមានវត្តមានដោយផ្ទាល់ នៅពេលចូលបង្ហាញខ្លួនលើកដំបូង ដើម្បីធ្វើការចោទប្រកាន់គាត់[83] កត់ត្រាអត្តសញ្ញាណរបស់គាត់ និងសួរចម្លើយគាត់ ប្រសិនបើគាត់យល់ព្រមឆ្លើយ[84]។ បន្ទាប់មកទៀត សហមេធាវីអះអាងថា មាត្រា ១៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាស្រដៀងគ្នាទៅនឹងវិធាន ៥៧ នៃវិធានផ្ទៃក្នុងដែរ ចែងអំពីនីតិវិធីក្នុងការចោទប្រកាន់ជនសង្ស័យ និងតម្រូវឱ្យមានវត្តមានរបស់គាត់ផ្ទាល់ នៅពេលបង្ហាញខ្លួនលើកដំបូង[85] ហើយថា មាត្រា ៣៣៣, ៣៥១, ៣៦១ និង ៣៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មិនជាប់ពាក់ព័ន្ធគ្នាទេ ពីព្រោះមាត្រាទាំងនេះអនុវត្តបានតែនៅក្នុងដំណាក់កាលជំនុំជម្រះប៉ុណ្ណោះ[86]។ សហមេធាវីលើកឡើងបន្ថែមទៀតថា ស្រដៀងគ្នានេះដែរ ច្បាប់បារាំងមិនអនុញ្ញាតឱ្យមានការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ*ដោយកំបាំងមុខ*ទេ[87]។

---

[80] ដីកាសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៧១។

[81] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៣។

[82] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៣១-៤៣។

[83] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៣៣។

[84] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៣៦។

[85] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៤៤-៤៦។

[86] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៤៧។

[87] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៥០-៥៣។

9. ទីពីរ សហមេធាវីអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបញ្ចៀសការប្រើច្បាប់ដែលមានជាធរមាននៅចំពោះមុខ អ.វ.ត.ក នៅក្នុងការស្វែងរកការណែនាំនៅក្នុងវិធាននានាដែលបានបង្កើតឡើងនៅកម្រិតអន្តរជាតិ និងការបង្កើតនីតិវិធី*ដោយកំបាំងមុខ*ថ្មី ដោយផ្អែកលើវិធាននានាពីតុលាការអន្តរជាតិដទៃទៀត ដែលមិនអាចយកមកអនុវត្តបាននៅ អ.វ.ត.ក[88]។ ជាពិសេស សហមេធាវីជំទាស់ថា វិធានស្ដីពីនីតិវិធីរបស់តុលាការពិសេសសម្រាប់ប្រទេសលីបង់ ("តុលាការ STL") មិនអាចយកមកអនុវត្តបានទេនៅ អ.វ.ត.ក ពីព្រោះតុលាការ STL គឺជាតុលាការមួយដែលបានបង្កើតឡើងដើម្បីតម្រូវតាមកិច្ចដំណើរការនីតិវិធី*ដោយកំបាំងមុខ* នៅដំណាក់កាលបុរេជំនុំជម្រះ[89]។ វិធានរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ("តុលាការ ICTY") តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រវ៉ាន់ដា ("តុលាការ ICTR") និងតុលាការព្រហ្មទណ្ឌអន្តរជាតិ ("តុលាការ ICC") ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានស្វែងរកការណែនាំនោះ ក៏មិនអាចយកមកអនុវត្តបានដែរនៅទីនេះ ពីព្រោះវិធានទាំងនោះអនុវត្តចំពោះដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីផ្សេងៗគ្នា[90]។ សហមេធាវីលើកឡើងបន្ថែមទៀតថា នៅកម្រិតអន្តរជាតិ កិច្ចដំណើរការនីតិវិធី*ដោយកំបាំងមុខ* អាចអនុញ្ញាតបានតែក្នុងករណីដែលជនជាប់ចោទរត់គេចខ្លួនប៉ុណ្ណោះ[91] ឬក្នុងករណីដែល "ការព្យាយាមសមហេតុផល" ត្រូវបានអនុវត្តរួចហើយ ដើម្បីជូនដំណឹងជាផ្លូវការអំពីបទចោទប្រកាន់ដល់ជនជាប់ចោទ ដែលរួមមានការព្យាយាមជូនដំណឹងនៅឯទីកន្លែងដែលគេស្គាល់ចុងក្រោយបំផុតរបស់ជនជាប់ចោទ ការជូនដំណឹងតាមរយៈកន្លែងធ្វើការរបស់គាត់ ការប្រើប្រាស់អាសយដ្ឋានគ្រួសារ និងការផ្សព្វផ្សាយយ៉ាងទូលំទូលាយនៅក្នុងប្រព័ន្ធសារព័ត៌មាន[92]។ សហមេធាវីជំទាស់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិខកខានមិនបានបំពេញតាមលក្ខខណ្ឌតម្រូវទាំងនេះ ពីព្រោះគាត់មិនបានចាត់គ្រប់វិធានការសមហេតុផលទាំងអស់ ដើម្បីជូនដំណឹងដល់ អ៊ឹម ចែម អំពីបទចោទប្រកាន់ប្រឆាំងនឹង អ្នកស្រីដោយ

---

[88] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ២។

[89] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៥៨ ដែលយោងទៅលើវិធានស្ដីពីនីតិវិធីនិងភស្តុតាងរបស់តុលាការ STL វិធាន ១០៥*ស្ទួន* និង ៧៦*ស្ទួន*។

[90] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៦២-៦៨។

[91] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៦៧។

[92] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៦០-៦១។



ECCC • CETC PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

ផ្ទាល់ ទោះបីជាគាត់ដឹងទីកន្លែងដែលអ្នកស្រីរស់នៅក៏ដោយ[93] ឬក៏តាមរយៈការផ្សព្វផ្សាយនៅក្នុងប្រព័ន្ធសារព័ត៌មានឡើយ[94]។ សហមេធាវីអះអាងបន្ថែមទៀតថា "ចៅក្រម Harmon ក៏មិនបានពិនិត្យពិច័យលើជម្រើសក្នុងការចោទប្រកាន់អ្នកស្រី អ៊ឹម ចែម នៅឯភូមិកំណើតរបស់ អ្នកស្រីដូចដែលលោកចៅក្រមបានធ្វើចំពោះលោក អោ អាន នោះទេ"[95]។ ដូច្នេះ សហមេធាវីស្នើសុំឱ្យអង្គបុរេជំនុំជម្រះ **ក.** ច្រានចោលកថាខណ្ឌ ៣៩, ៤០, ៤២-៤៦, ៥៧-៥៨ និងផ្នែកខ្លះនៃកថាខណ្ឌ ៧៣ និងកថាខណ្ឌ ៧៦ ដែលទាក់ទងនឹងការចោទប្រកាន់ អ៊ឹម ចែម នៅក្នុងដីកាសម្រេចដែលរងការជំទាស់ ដែលជាដីកាសម្រេចមានកំហុសអង្គច្បាប់ និង **ខ.** ទុកជាមោឃៈនូវការជូនដំណឹងអំពីបទចោទប្រកាន់ដែល *ហួសពីដែនអំណាច*[96] ដូចដែលបានរៀបរាប់ខាងលើ។

10. សហព្រះរាជអាជ្ញាអន្តរជាតិឆ្លើយតបថា ការខកខានរបស់ អ៊ឹម ចែម មិនបានប្រតិបត្តិតាមដីកាកោះមួយដែលភ្ជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ និងការខកខានមិនបានអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួនបង្កើតនូវបញ្ហាមួយដែល "ផ្ទុយទៅនឹងស្ថានភាពអង្គហេតុដោយផ្ទាល់ ដែលត្រូវបានប្រមើលមើលទុកជាមុនដោយវិធានផ្ទៃក្នុង"[97] ដែលប្រមើលថា ដីកាកោះនឹងត្រូវបានប្រតិបត្តិតាម[98] ហើយដីកាបង្គាប់ឱ្យនាំខ្លួន ត្រូវបានអនុវត្ត[99]។ ស្រដៀងគ្នានេះដែរ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថាពុំមាននីតិវិធីជាធរមាននៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលដោះស្រាយចំពោះស្ថានភាពអង្គហេតុបច្ចុប្បន្ននេះឡើយ[100]។ ដូច្នេះ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា វាជាការសមស្របសម្រាប់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងការពិចារណាទៅលើវិធានស្តីពីនីតិវិធី ដែលបានបង្កើតឡើងនៅកម្រិតអន្តរជាតិ[101]។ ទាក់ទិននឹងបញ្ហានេះ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថាដោយសារតែការចូលរួមយ៉ាងសកម្មរបស់គាត់នៅក្នុងកិច្ចដំណើរការនីតិវិធី តាមរយៈក្រុមមេធាវី

---

[93] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៦១ និង ៦៧។

[94] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៦១។

[95] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៦១។

[96] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២។

[97] ចម្លើយតប កថាខណ្ឌ ១៣-១៦។

[98] ចម្លើយតប កថាខណ្ឌ ១៤។

[99] ចម្លើយតប កថាខណ្ឌ ១៥ *ដែលយោងទៅលើវិធាន* ៤៥(២)នៃវិធានផ្ទៃក្នុង។

[100] ចម្លើយតប កថាខណ្ឌ ១៧-១៨។

[101] ចម្លើយតប កថាខណ្ឌ ១៨។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C • C.E.T.C

ការពារក្តីដែលគាត់បានជ្រើសរើសដោយផ្ទាល់នោះ អ៊ឹម ចែម ត្រូវបានចាត់ទុកថាបានចូលបង្ហាញខ្លួននៅក្នុងកិច្ចដំណើរការនីតិវិធីទាំងនេះរួចជាស្រេចហើយ ឬបានលះបង់សិទ្ធិរបស់គាត់ក្នុងការមានវត្តមាន អនុលោមតាមវិធានជាធរមាននៅចំពោះមុខតុលាការ STL និងច្បាប់សិទ្ធិមនុស្ស។ ដូច្នេះ ការចោទប្រកាន់លើរូបគាត់ មិនត្រូវបានចាត់ទុកថា "*ដោយកំបាំង មុខ*"ឡើយ[102]។ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា សវនាការស្តីអំពីការបញ្ជាក់ពីបទចោទ ប្រកាន់នៅតុលាការ ICC ដែលស្រដៀងគ្នាទៅនឹងការជូនដំណឹងអំពីបទចោទប្រកាន់នៅ អ.វ.ត.ក អាចត្រូវបានធ្វើឡើង *ដោយកំបាំងមុខ* អនុលោមតាមមាត្រា ៦១ នៃលក្ខន្តិកៈទីក្រុងរ៉ូម ប្រសិនបើវិធានការសមហេតុផលទាំងអស់ ត្រូវបានអនុវត្តរួចហើយ ដើម្បីធានានូវការចូលបង្ហាញខ្លួនរបស់ជនសង្ស័យដោយផ្ទាល់នោះ។ សហព្រះរាជអាជ្ញាអន្តរជាតិសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពិចារណាយ៉ាងត្រឹមត្រូវទៅលើវិធានស្តីពីនីតិវិធីពាក់ព័ន្ធនៅកម្រិតអន្តរជាតិ[103]។

11. សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា អ៊ឹម ចែម បានលះបង់យ៉ាងច្បាស់ក្រឡែតនូវសិទ្ធិរបស់គាត់ក្នុងការមានវត្តមាននៅក្នុងអំឡុងកិច្ចដំណើរការនីតិវិធី ពីព្រោះគាត់បានធ្វើសេចក្តីថ្លែងជាសាធារណៈជាច្រើនទៅកាន់សារព័ត៌មាននានា ដោយបញ្ជាក់អំពីចេតនារបស់គាត់ក្នុងការមិនចូលបង្ហាញខ្លួននៅចំពោះមុខ អ.វ.ត.ក ដែលប្រការនេះបង្ហាញថា គាត់អវត្តមានដោយស្ម័គ្រចិត្ត[104]។ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចាត់វិធានការសមហេតុផលទាំងអស់ដើម្បីជូនដំណឹងដល់ អ៊ឹម ចែម ដោយផ្ទាល់ ប៉ុន្តែមិនទទួលបានជោគជ័យ ហើយក៏បានជូនដំណឹងដល់គាត់អំពីបទចោទប្រកាន់ តាមរយៈមេធាវីការពារក្តីរបស់គាត់[105] ដែលបំពេញជាក់ស្តែងនូវលក្ខខណ្ឌដើម្បីបន្តដំណើរការសវនាការបញ្ជាក់អំពីបទចោទប្រកាន់ *ដោយកំបាំងមុខ*នៅ តុលាការព្រហ្មទណ្ឌអន្តរជាតិ។ សហព្រះរាជអាជ្ញាអន្តរជាតិសន្និដ្ឋានថា ទោះបីជាកំហុសមួយបានកើតមាននៅក្នុងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងការបន្តដំណើរការនីតិវិធី*ដោយកំបាំងមុខ*ក៏ដោយ ក៏កំហុសនោះមិនបង្កឲ្យមានការប៉ះពាល់ដល់ អ៊ឹម ចែម ដែលបណ្តាលមកពីដីកាសម្រេចដែលរងការជំទាស់នោះឡើយ ពីព្រោះបច្ចុប្បន្ននេះ គាត់មាន

---

102 ចម្លើយតប កថាខណ្ឌ ១៩-៣១។

103 ចម្លើយតប កថាខណ្ឌ ៣៤។

104 ចម្លើយតប កថាខណ្ឌ ២៩ និង ៣១។

105 ចម្លើយតប កថាខណ្ឌ ៣២-៣៣។

សិទ្ធិចូលរួមក្នុងការស៊ើបអង្កេត និងមានសិទ្ធិចូលពិនិត្យមើលសំណុំរឿង[106]។ ដូច្នេះ សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំឱ្យបដិសេធចោលបណ្តឹងឧទ្ធរណ៍នេះលើអង្គសេចក្តី។

12. សហមេធាវីឆ្លើយតបថា ការមិនធ្វើកិច្ចសហការ ត្រូវបានប្រមើលមើលជាមុន នៅពេលរៀបចំតាក់តែងកិច្ចព្រមព្រៀង ហើយផែនការជាយថាហេតុមួយ ដែលមិនអនុញ្ញាតឱ្យមានការអនុម័តនូវការពង្រីកអំណាចក្នុងការចោទប្រកាន់ ត្រូវបានបង្កើតឡើង ដែលមិនដាក់បញ្ចូលនូវកិច្ចដំណើរការ នីតិវិធី*ដោយកំបាំងមុខ* ឡើយ[107]។ សហមេធាវីអះអាងថា គ្មានបញ្ហាចោទណាមួយ ត្រូវបានបន្សល់ទុកដោយមិនបានដោះស្រាយនោះទេ អនុលោមតាមច្បាប់កម្ពុជា ពីព្រោះក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ចែងអំពីនីតិវិធីដែលត្រូវអនុវត្ត នៅពេលដែលនគរបាលយុត្តិធម៌ ជួបឧបសគ្គផ្សេងៗនៅក្នុងការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន[108]។ លើសពីនេះទៀត សហមេធាវីឆ្លើយតបថា ការខកខានរបស់ អ៊ឹម ចែម មិនចូលបង្ហាញខ្លួនលើកដំបូង មិនអាចត្រូវបានបកស្រាយថាជាការលះបង់សិទ្ធិរបស់គាត់ ក្នុងការចូលបង្ហាញខ្លួននោះឡើយ ពីព្រោះប្រការនេះតម្រូវថា គាត់ "បានដឹងគ្រប់គ្រាន់" អំពីកិច្ចដំណើរការនីតិវិធី តាមរយៈការជូនដំណឹងត្រឹមត្រូវ[109]។ ចុងក្រោយ សហមេធាវីអះអាងថា បទដ្ឋាននៃការពិនិត្យឡើងវិញដែលត្រូវអនុវត្តនោះ គឺនៅត្រង់ថាតើមូលហេតុនៃការដាក់ឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ* មានកំហុសអង្គច្បាប់ ដែលនាំឱ្យមោឃៈដីកាសម្រេចដែលរងការជំទាស់នោះ ដែរឬទេ[110] ដូច្នេះហើយវាមិនពាក់ព័ន្ធឡើយថាតើ អ៊ឹម ចែម បានទទួលរងនូវផលប៉ះពាល់ ឬយ៉ាងណានោះ។

## ក. សេចក្តីសង្កេតបឋម

13. ចៅក្រមដែលបានចុះហត្ថលេខាកត់សម្គាល់ឃើញថា ពាក្យ "ការដាក់ឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ*" នៅក្នុងដីកាសម្រេចដែលត្រូវបានជំទាស់ អាចនាំឱ្យមានការភ័ន្តច្រឡំ។ *ដោយ*

[106] ចម្លើយតប កថាខណ្ឌ ៣៤-៣៧។

[107] ការឆ្លើយតប កថាខណ្ឌ ២ និង ៩-១៤ *ដែលយោងទៅលើ*មាត្រា ២៨ នៃកិច្ចព្រមព្រៀង។ របាយការណ៍របស់អគ្គលេខាធិការស្តីពីសាលាក្តីខ្មែរក្រហម ឯកសាររបស់អង្គការសហប្រជាជាតិ A/57/769 ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ កថាខណ្ឌ ១៥។

[108] ការឆ្លើយតប កថាខណ្ឌ ១៥ *ដែលយោងទៅលើ*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ១៩២។

[109] ការឆ្លើយតប កថាខណ្ឌ ១៩។

[110] ការឆ្លើយតប កថាខណ្ឌ ២២។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

*កំបាំងមុខ* មានន័យថា "ដោយគ្មានវត្តមាន"។ ក្នុងច្បាប់ ពាក្យឡាតាំងមួយនេះត្រូវបានប្រើជាទូទៅ ដើម្បីសម្គាល់ "ការជំនុំជម្រះ *ដោយកំបាំងមុខ*" ដូចជាការសម្រេចអំពីពិរុទ្ធភាព ឬភាពគ្មានទោស របស់ជនជាប់ចោទ និងការដាក់ទោស នៅពេលអវត្តមានជនជាប់ចោទ។ ជាបឋមគួរបញ្ជាក់ថា កិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿងបច្ចុប្បន្ន កំពុងស្ថិតនៅដំណាក់កាលមុនការជំនុំជម្រះ ហើយនីតិវិធីនៃការដាក់ឲ្យស្ថិតក្រោមការពិនិត្យ តាមវិធាន ៥៥(៤) នៃវិធានផ្ទៃក្នុង ពុំពាក់ព័ន្ធ ការសម្រេចអំពីពិរុទ្ធភាព ឬភាពគ្មានទោសឡើយ[111]។ ហេតុនេះ ការលើកឡើងអំពីវិធាននីតិវិធី ណាមួយដែលមានចែងអំពី *ការជំនុំជម្រះដោយកំបាំងមុខ* ត្រូវតែធ្វើដោយប្រុងប្រយ័ត្ន ដោយ ពិចារណាអំពីភាពខុសគ្នានៃកិច្ចដំណើរនីតិវិធីនៅដំណាក់កាលនេះ និងផលវិបាករបស់ចុងចោទ។ ទីពីរ ការប្រើប្រាស់ពាក្យ "*ដោយកំបាំងមុខ*" ត្រឹមប៉ុណ្ណឹងនៅក្នុងករណីនាពេលបច្ចុប្បន្ន ពុំ សមស្របឡើយ ហើយយើងនឹងបកស្រាយពន្យល់ដូចខាងក្រោមនេះ។

14. នៅក្រោមច្បាប់កម្ពុជាដែលអនុញ្ញាតឲ្យចេញសាលក្រម ពេលអវត្តមានជនជាប់ចោទ ការជំនុំជម្រះពុំត្រូវបានចាត់ទុកជាការជំនុំជម្រះ *ដោយកំបាំងមុខ* ឡើយ ខណៈដែលជនជាប់ចោទបានដឹង អំពីកិច្ចដំណើរការនីតិវិធីនោះ[112]។ ត្រង់ប្រការនេះ មាត្រា ៣៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះ រាជាណាចក្រកម្ពុជាចែងថា៖

---

[111] សំណុំរឿង *រដ្ឋអាជ្ញា ទល់នឹង Rajic,* IT-95-12-R61, ការពិនិត្យឡើងវិញអំពីដីកាបញ្ជូនរឿងទៅជំនុំជម្រះអនុលោមតាមវិធាន ៦១ នៃវិធានស្តីពីនីតិវិធី និងភស្តុតាង អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ១៩៩៦ កថាខណ្ឌ ៣៖ "កិច្ចដំណើរការនីតិវិធី ស្របតាមវិធាន ៦១ មិនមែនជាសវនាការដោយកំបាំងមុខឡើយ។ ពុំមានការសន្និដ្ឋានអំពីពិរុទ្ធភាពឡើយ នៅក្នុងកិច្ចដំណើរការនីតិវិធីនេះ [...]។ ពុំមានការដាក់ទោសទណ្ឌទៅលើជនជាប់ចោទទេនៅក្នុងកិច្ចដំណើរការនីតិវិធីស្របតាមវិធាន ៦១"។

[112]គោលការណ៍នេះគឺដូចគ្នានៅក្នុងចំណោមប្រទេសជាច្រើនដូចជា អ៊ីតាលី ប៊ុលហ្គារី និងស្វីស។ *សូមមើល* តុលាការសិទ្ធិមនុស្សអឺរ៉ុប, សំណុំរឿង *Sejdovic ទល់នឹង Italy,* ពាក្យសុំលេខ 56581/00, សាលក្រម, ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៤, កថាខណ្ឌ ២៤, *ដោយយោង*មាត្រា ១៧៥(២) នៃក្រមព្រហ្មទណ្ឌអ៊ីតាលី ដែលចែងថាបុគ្គលដែលត្រូវបានបដិសេធមិនប្រាប់អំពីវិធានការនានាដែលបានអនុវត្តនៅក្នុងកិច្ចដំណើរការនីតិវិធី ពុំមានសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍ដែលខុសពេលឡើយ ដោយហេតុថាសិទ្ធិនេះត្រូវបានផ្តល់សម្រាប់ជនដែលត្រូវបានផ្តន្ទាទោស*ដោយកំបាំងមុខ*។ តុលាការសិទ្ធិមនុស្សអឺរ៉ុប សំណុំរឿង *Demebuka ទល់នឹង Bulgaria,* ពាក្យសុំលេខ 68020/01, សាលក្រមចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៨, កថាខណ្ឌ ៣០-៣១ *ដោយយោង* មាត្រា ៤២៣(១) នៃក្រមនីតិវិធីព្រហ្មទណ្ឌប៊ុលហ្គារីឆ្នាំ ២០០៦ ដែលអនុញ្ញា[illegible]ព្រហ្មទណ្ឌ

> ប្រសិនបើជនជាប់ចោទមិនចូលមកបង្ហាញខ្លួននៅពេលសវនាការទេ ប៉ុន្តែសាម៉ីខ្លួនបានដឹងអំពីដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬបានដឹងពីការកោះហៅហើយនោះ សាលក្រមត្រូវចាត់ទុកថាជាសាលក្រមចំពោះមុខជនជាប់ចោទ។ សាលក្រមដែលចាត់ទុកថាចំពោះមុខនេះ ត្រូវឱ្យដំណឹងដល់ជនជាប់ចោទ។ សាលក្រមនេះអាចត្រូវប្តឹងឧទ្ធរណ៍បាន។

បញ្ច្រាសមកវិញ មាត្រា ៣៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាចែងថា៖

> ប្រសិនបើជនជាប់ចោទមិនចូលបង្ហាញខ្លួននៅពេលសវនាការទេ ហើយនិងប្រសិនបើគ្មានភស្តុតាងបង្ហាញឱ្យឃើញថាសាម៉ីខ្លួនបានដឹងពីដីកាបញ្ជូនទៅជំនុំជម្រះ ឬបានដឹងអំពីការកោះហៅនោះទេ សាលក្រមត្រូវប្រកាសដោយកំបាំងមុខជនជាប់ចោទ។ សាលក្រមកំបាំងមុខជនជាប់ចោទ ត្រូវឱ្យដំណឹងដល់ជនជាប់ចោទនេះ។ សាលក្រមនេះអាចត្រូវប្តឹងទាស់បាន (សូមមើល មាត្រា ៣៦៥)។

15. អ្វីដែលបានរៀបរាប់ខាងលើក៏មាននៅក្នុងកម្រិតអន្តរជាតិផងដែរ។ នៅតុលាការពិសេសសម្រាប់លីបង់ដែលជាតុលាការឧក្រិដ្ឋកម្មអន្តរជាតិតែមួយគត់ ដែលអនុញ្ញាតឱ្យធ្វើការជំនុំជម្រះ *ដោយកំបាំងមុខ* កិច្ចដំណើរការនីតិវិធីទាំងនេះពុំត្រូវបានចាត់ទុកជាកិច្ចដំណើរការនីតិវិធី *ដោយកំបាំងមុខ* ឡើយ នៅពេលជនជាប់ចោទបានតែងតាំងមេធាវីតំណាង[113]។

---

ឡើងវិញ ដែលសវនាការត្រូវបានធ្វើ *ដោយកំបាំងមុខ* ប៉ុន្តែដូចបញ្ជាក់នៅក្នុងសំណុំរឿងក្នុងស្រុក решение № 882 от 07.11.2006 г. по н.д.№ 331/2006 г., I н.о. на ВКС ពុំអនុវត្តចំពោះជនដែលបានដឹងអំពីកិច្ចដំណើរការនីតិវិធីប្រឆាំងសាម៉ីខ្លួន ប៉ុន្តែសម្រេចពុំព្រមចូលរួម, តុលាការសិទ្ធិមនុស្សអឺរ៉ុប, *សំណុំរឿង Medenica ទល់នឹង Switzerland,* ពាក្យសុំលេខ 20491/92 សាលក្រម ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០១, កថាខណ្ឌ ៤២ *ដោយយោង* មាត្រា ៣៣១ នៃក្រមនីតិវិធីព្រហ្មទណ្ឌរបស់សាធារណរដ្ឋកង់តុងហ្សឺណែវ ដែលជនណាដែលត្រូវបានផ្តន្ទាទោស *ដោយកំបាំងមុខ* អាចស្នើសុំឱ្យដកចេញការផ្តន្ទាទោសខ្លួន ប្រសិនបើបុគ្គលរូបនោះបង្ហាញថាវាមិនមែនជាកំហុសរបស់ខ្លួនឡើយដែលមិនបានដឹងអំពីដីកាកោះឱ្យចូលបង្ហាញខ្លួន ឬមិនអាចចូលរួមសវនាការបាន។

[113] វិធានស្តីពីនីតិវិធី និងភស្តុតាងនៃតុលាការពិសេសសម្រាប់លីបង់, STL-BD-2009-01-វិធានសោធនកម្មលើកទី ៦-កំណែទី ១ (ឆ្នាំ ២០០៩) (“វិធានស្តីពីនីតិវិធី និងភស្តុតាងនៃតុលាការ STL”) មាត្រា ១០៤។

16. ដូចគ្នានេះក្រោមច្បាប់សិទ្ធិមនុស្ស ជនជាប់ចោទដែលខកខានពុំបានបង្ហាញខ្លួននៅសវនាការត្រូវចាត់ទុកថាបានលះបង់សិទ្ធិមានវត្តមានរបស់ខ្លួន កាលណាសាមីខ្លួន i) បានទទួលព័ត៌មានត្រឹមត្រូវអំពីកិច្ចដំណើរការនីតិវិធី[114] ii) បានទទួលដំណឹងអំពីកិច្ចដំណើរការនីតិវិធីនៅដំណាក់កាលដំបូង ប៉ុន្តែនៅពេលក្រោយមកទៀត ជនជាប់ចោទបានបង្កើតស្ថានភាពមួយដែលធ្វើឱ្យខ្លួនមិនអាចទទួលបានព័ត៌មាន និងចូលរួមកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ[115] ឬ iii) ត្រូវបានតំណាងដោយមេធាវីដែលជនជាប់ចោទបានជ្រើសរើស[116]។ នៅពេលជនជាប់ចោទត្រូវបានចាត់ទុកថាបានលះបង់សិទ្ធិ

---

[114] គណកម្មាធិការសិទ្ធិមនុស្ស, *Mbenge v. Zaire,* ការប្រាស្រ័យទាក់ទង 16/1977, ឯកសារ អ.ស.ប CCPR/C/OP/2, ទំព័រ ៧៦ (ឆ្នាំ ១៩៩០), កថាខណ្ឌ ១៤.១ (ដែលបានសម្រេចថាសិទ្ធិមានវត្តមានពុំត្រូវបានរំលោភឡើយ "នៅពេលជនជាប់ចោទបដិសេធអនុវត្តសិទ្ធិមានវត្តមានរបស់ខ្លួន បើទោះជាជនជាប់ចោទបានទទួលព័ត៌មានគ្រប់គ្រាន់ជាមុនអំពីកិច្ចដំណើរការនីតិវិធីក៏ដោយ), តុលាការសិទ្ធិមនុស្សអឺរ៉ុប, សំណុំរឿង *Medenica ទល់នឹង Switzerland,* ពាក្យសុំលេខ 20491/92, សាលក្រម, ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០១, កថាខណ្ឌ ៥៦-៥៩ (តុលាការសិទ្ធិមនុស្សអឺរ៉ុបពុំសម្រេចថាមិនមានការរំលោភទៅលើសិទ្ធិមានវត្តមាននៅសវនាការឡើយ នៅពេលដែលអ្នកដាក់ពាក្យសុំ ដែលបានដឹងអំពីកិច្ចដំណើរការនីតិវិធី និងមានមេធាវីតំណាងនៅសវនាការដែលមេធាវីនោះត្រូវបានតែងតាំងដោយអ្នកដាក់ពាក្យសុំ "បានរួមចំណែកជំទេងដល់ការនាំមកនូវស្ថានភាពមួយដែលរារាំងគាត់មិនឱ្យមកបង្ហាញខ្លួន"។ នៅក្នុងសំណុំរឿងនោះ អ្នកដាក់ពាក្យសុំ ដែលបានអះអាងថាគាត់ពុំអាចចូលមកបង្ហាញខ្លួននៅសវនាការនៅប្រទេសស្វីស ដោយហេតុថាគាត់ស្ថិតក្រោមដីកាបង្គាប់ដែលរារាំងមិនឱ្យគាត់ចាកចេញពី សហរដ្ឋអាមេរិក "បានកុហកតុលាការអាមេរិកតាមរយៈការផ្តល់ចម្លើយមិនជាក់លាក់និងមិនត្រឹមត្រូវដោយចេតនាពិសេសអំពី នីតិវិធីស្វីស-ក្នុងបំណងទទួលបានសេចក្តីសម្រេចមួយដែលធ្វើឱ្យគាត់មិនអាចមកបង្ហាញខ្លួននៅសវនាការ"។ តុលាការបានសម្រេចថាស្ថានភាពនេះត្រូវបានរៀបចំដោយជនជាប់ចោទ ដើម្បីធ្វើឱ្យមានរូបអវត្តមានរបស់គាត់នៅសវនាការ និងស្នើសុំបន្តអវត្តមាន), តុលាការសិទ្ធិមនុស្ស, សំណុំរឿង *Lala ទល់នឹង The Netherlands,* ពាក្យសុំលេខ 14861/89, សាលក្រម,ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៤, កថាខណ្ឌ ៣០ (ដោយបានបញ្ជាក់ថាអ្នកដាក់ពាក្យសុំដែលបានដឹងអំពីកិច្ចដំណើរការនីតិវិធី និងមានមេធាវីតំណាង "មិនបានប្រើប្រាស់សិទ្ធិរបស់ខ្លួនដើម្បីចូលរួមសវនាការ")។

[115] តុលាការសិទ្ធិមនុស្សអឺរ៉ុប, សំណុំរឿង *Demebukov ទល់នឹង Bulgaria,* ពាក្យសុំលេខ 6802/01, ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៨, កថាខណ្ឌ ៥៦ និង ៥៩ (ដែលបានសម្រេចថា "អ្នកដាក់ពាក្យសុំបាននាំមកនូវស្ថានភាពមួយដែលធ្វើឱ្យគាត់មិនអាចដឹង ឬចូលរួមកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌក្នុងដំណាក់កាលជំនុំជម្រះ" ដោយហេតុថាអ្នកដាក់ពាក្យសុំបានទទួលដំណឹងអំពីការចោទប្រកាន់រូបគាត់ បានតែងតាំងមេធាវីតំណាង ស្ថិតក្រោមដីកាកំហិតការផ្លាស់ទីកន្លែង ប៉ុន្តែបានផ្លាស់ទីកន្លែងដោយមិនជូនដំណឹងអាជ្ញាធរ ភ្លាមៗបន្ទាប់ពីបានដឹងលទ្ធផលនៃកិច្ចស៊ើបសួរបឋម)។

[116] *សូមមើល* តុលាការសិទ្ធិមនុស្សអឺរ៉ុប, សំណុំរឿង *Medenica ទល់នឹង Switzerland,* ពាក្យសុំលេខ 20491/92, សាលក្រម, ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០១, កថាខណ្ឌ ៥៦, កថាខណ្ឌ ៥៩។ តុលាការសិទ្ធិមនុស្សអឺរ៉ុប, សំណុំរឿង *Lala ទល់នឹង The Netherlands,* ពាក្យសុំលេខ 14861/89, សាលក្រម, ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៤, កថាខណ្ឌ ៣០។



E.C.C.C. • C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE

មានវត្តមាន កិច្ចដំណើរការនីតិវិធីពុំត្រូវបានចាត់ទុកជាកិច្ចដំណើរការនីតិវិធី *ដោយកំបាំងមុខ* ឡើយ ហើយហេតុដូច្នេះ យើងពុំចាំបាច់ផ្តល់ចូលរួមសវនាការជាថ្មីឱ្យជនជាប់ចោទដើម្បីឱ្យស្រប តាមមាត្រា៦(៣)(គ) នៃកតិកាសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ឬមាត្រា ១៤(៣)(ឃ) នៃវិធាននីតិវិធី នៃតុលាការព្រហ្មទណ្ឌអន្តរជាតិឡើយ។

17. នៅក្នុងសំណុំរឿងបច្ចុប្បន្ន តាមច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ មានន័យថា នីតិវិធីនៃការដាក់ឱ្យស្ថិតក្រោមការពិនិត្យពុំត្រូវបានធ្វើដោយ "អវត្តមាន" អ៊ឹម ចែម ឡើយ។ អ៊ឹម ចែម ត្រូវបានតំណាងដោយមេធាវីដែលគាត់បានតែងតាំង និងបានទទួលដំណឹងត្រឹមត្រូវអំពីការកោះហៅគាត់ឱ្យមកបង្ហាញខ្លួនលើកដំបូង ប៉ុន្តែគាត់បានបង្ហាញចេតនាមិនចង់មកបង្ហាញខ្លួនតាមរយៈសហមេធាវីរបស់គាត់ និងដោយផ្ទាល់តាមរយៈប្រព័ន្ធផ្សព្វផ្សាយ ដូចដែលយើងនឹងបញ្ជាក់លម្អិតខាងក្រោមនេះ។ លើសពីនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចដាក់ អ៊ឹម ចែម ឱ្យស្ថិតក្រោមការពិនិត្យដោយគ្មានការធ្វើសវនាការបង្ហាញខ្លួនលើកដំបូងដោយមានវត្តមានគាត់ និងបានជូនដំណឹងទៅគាត់អំពីការចោទប្រកាន់នានា តាមរយៈលិខិតជូនដំណឹងដែលប្រគល់ទៅសហមេធាវីរបស់គាត់។ ពុំមានសវនាការណាមួយបានធ្វើនៅពេលអវត្តមានជនជាប់ចោទឡើយ។

18. ក្នុងបរិបទនេះ ចៅក្រមដែលបានចុះហត្ថលេខាពិចារណាឃើញថា កាលៈទេសៈបច្ចុប្បន្នតម្រូវឱ្យពិនិត្យ*ដាក់ ស្តែង* អំពីនីតិវិធីនៃការដាក់ជនជាប់ចោទឱ្យស្ថិតក្រោមការពិនិត្យរបស់សហចៅក្រមស៊ើបអង្កេត។ នីតិវិធីនេះមានពីរត្រួត៖ ទីមួយ សហចៅក្រមស៊ើបអង្កេតបានចេញសេចក្តីសម្រេចដាក់ អ៊ឹម ចែម ឱ្យស្ថិតក្រោមការពិនិត្យ តាមវិធាន ៥៥(៤) នៃវិធានផ្ទៃក្នុង ហើយបន្ទាប់មកគាត់បានជូនដំណឹង អ៊ឹម ចែម អំពីការចោទប្រកាន់តាមរយៈលិខិតជូនដំណឹងជាផ្លូវការទៅសហមេធាវីរបស់ អ៊ឹម ចែម និងដោយគ្មានសវនាការនៃការចូលមកបង្ហាញខ្លួនលើកដំបូង តាមវិធាន ៥៧ នៃវិធានផ្ទៃក្នុងឡើយ។ ចៅក្រមដែលបានចុះហត្ថលេខា នឹងពិនិត្យថាតើសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានប្រព្រឹត្តកំហុសអង្គច្បាប់នៅក្នុងដំណើរការនេះដែរ ឬទេ ដោយមិនពិចារណាអំពីការយោងទៅលើ "ដីកាសម្រេចដាក់ អ៊ឹម ចែម ឱ្យស្ថិតក្រោម ការពិនិត្យ *ដោយកំបាំងមុខ*" ឡើយ។ ជាក់លាក់ជាងនេះទៅទៀត ចៅក្រមដែលបានចុះហត្ថលេខានឹងពិនិត្យមុនគេថាតើសហ

---

តុលាការសិទ្ធិមនុស្សអឺរ៉ុប, សំណុំរឿង *Demebukov ទល់នឹង Bulgaria,* ពាក្យសុំលេខ 6802/01, ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៨, កថាខណ្ឌ ៥៧។



E.C.C.C * C.E.T.C
PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE

ចៅក្រមស៊ើបអង្កេតអន្តរជាតិបានប្រព្រឹត្តកំហុសអង្គច្បាប់ នៅពេលដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចថា ការចូលមកបង្ហាញខ្លួនលើកដំបូង ពុំមែនជាបុរេលក្ខខណ្ឌមួយសម្រាប់ដាក់ជនសង្ស័យឱ្យស្ថិតក្រោមការពិនិត្យ តាមវិធានផ្ទៃក្នុង អ.វ.ត.ក ឡើយ និងការ ដែលគាត់បានសម្រេចថា ក្រមងឯកសារច្បាប់នៅ អ.វ.ត.ក ពុំមានចែងអំពីនីតិវិធីនៃការដាក់ឱ្យជនសង្ស័យស្ថិតក្រោមការពិនិត្យ នៅពេលជនសង្ស័យមិនមានវត្តនៅក្នុងសវនាការនៃការបង្ហាញខ្លួនលើកដំបូង។ បន្ទាប់មក ចៅក្រមដែលបានចុះហត្ថលេខានឹងពិនិត្យថាតើសហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការស្វែងរកការណែនាំនៅក្នុងវិធាន ដែលមានចែងក្នុងក្របខ័ណ្ឌអន្តរជាតិដែរឬទេ និងការបកស្រាយរបស់សហចៅក្រមស៊ើបអង្កេតលើវិធានទាំងនោះ។ ជាចុងក្រោយ ចៅក្រមដែលបានចុះហត្ថលេខានឹងពិចារណាថាតើសហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសឬយ៉ាងណា ក្នុងការសម្រេចថាកាលៈទេសៈនៃសំណុំរឿងបច្ចុប្បន្ន អនុញ្ញាតឱ្យគាត់ចេញដីកាសម្រេចដាក់ អ៊ឹម ចែម ឱ្យស្ថិតក្រោមការពិនិត្យ ដោយមិនបាច់មានការមកបង្ហាញខ្លួនលើកដំបូង និងដោយគ្មានជូនដំណឹងដល់ អ៊ឹម ចែម អំពីការចោទប្រកាន់ តាមរយៈមេធាវីរបស់គាត់។

## ខ. កំហុសដែលត្រូវបានចោទប្រកាន់នៅក្នុងការបកស្រាយវិធានផ្ទៃក្នុង និងច្បាប់កម្ពុជា

19. អនុលោមតាមវិធាន៥៥(៤) នៃវិធានផ្ទៃក្នុង "សហចៅក្រមស៊ើបអង្កេតមានអំណាចបើកការស៊ើបសួរប្រឆាំងនឹងជនទាំងឡាយណា ដែលមានឈ្មោះនៅក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរ"។ វិធាន ៥៥(៤) ចែងទៀតថា សហចៅក្រមស៊ើបអង្កេត "អាចបើកកិច្ចស៊ើបសួរផងដែរចំពោះបុគ្គលគ្រប់រូបដែលមានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់បញ្ជាក់ថា បុគ្គលនោះអាចជាអ្នកទទួលខុសត្រូវក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋ ដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម បើទោះបីជាបុគ្គលទាំងនោះមិនមានឈ្មោះក្នុងដីកាក៏ដោយ។ ក្នុងករណីចុងក្រោយនេះ សហចៅក្រមស៊ើបអង្កេតត្រូវសួរយោបល់សហព្រះរាជអាជ្ញា មុននឹងដាក់បុគ្គលនោះឱ្យស្ថិតនៅក្រោមការពិនិត្យ"។ វិធានផ្ទៃក្នុងពុំកំណត់បុរេលក្ខខណ្ឌសម្រាប់សហចៅក្រមស៊ើបអង្កេតសម្រេចដាក់ជនសង្ស័យឱ្យស្ថិតក្រោមការពិនិត្យ ដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬត្រូវអនុវត្តចំណាត់ការនីតិវិធីណាមួយមុនចេញដីកាដាក់ជនសង្ស័យឱ្យស្ថិតក្រោមការពិនិត្យឡើយ។ ត្រង់ប្រការនេះ មានការកត់សម្គាល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចពីពេលមុនថា ជាបឋម គាត់ត្រូវតែមានការជឿជាក់ថាមានភស្តុតាងគ្រប់

គ្រាន់ មុនពេលសម្រេចដាក់ជនសង្ស័យឱ្យស្ថិតក្រោមការពិនិត្យ ទោះបីជាជនសង្ស័យនោះមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក៏ដោយ[117]។ ទោះជាយ៉ាងណា ភាពច្បាស់លាស់គឺថា ការសម្រេចនេះនឹងត្រូវធ្វើ *ដោយភាគីតែម្ខាង* ហើយជនសង្ស័យនឹងបានត្រឹមតែចូលរួមក្នុងកិច្ចដំណើរការនីតិវិធី បន្ទាប់ពីត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យជាផ្លូវការ នៅក្នុងពេលចូលបង្ហាញខ្លួនលើកដំបូង[118]។

20. តាមលំដាប់លំដោយ វិធាន ៥៧ នៃវិធានផ្ទៃក្នុងចែងថា ជនត្រូវចោទត្រូវបាន *ប្រាប់* អំពីបទចោទប្រកាន់ នៅពេលជនត្រូវចោទចូលបង្ហាញខ្លួននៅចំពោះមុខសហចៅក្រមស៊ើបអង្កេតជាលើកដំបូង៖

១. នៅពេលជនត្រូវចោទចូលបង្ហាញខ្លួន ចំពោះមុខសហចៅក្រមស៊ើបអង្កេតជាលើកដំបូង សហចៅក្រមស៊ើបអង្កេតត្រូវកត់ត្រាទុកនូវអត្តសញ្ញាណរបស់ជននោះ និងប្រាប់ជននោះអំពីបទចោទប្រកាន់ និងអំពីសិទ្ធិមានមេធាវី និងសិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយនឹងសំណួរ។ ជនត្រូវចោទមានសិទ្ធិពិគ្រោះជាមួយមេធាវី មុនពេលដែលខ្លួនត្រូវបានសួរចម្លើយ និងមានមេធាវីអមជាមួយក្នុងពេលសួរចម្លើយ។ ប្រសិនបើជនត្រូវចោទយល់ព្រមឆ្លើយនោះ សហចៅក្រមស៊ើបអង្កេតត្រូវធ្វើការសួរចម្លើយនោះភ្លាម។ កំណត់ហេតុសួរចម្លើយត្រូវដាក់ចូលក្នុងសំណុំរឿង។

២. នៅពេលដែលជនត្រូវចោទត្រូវបានឃុំខ្លួន ជននោះត្រូវមានសិទ្ធិលើកឡើងនូវបញ្ហាពាក់ព័ន្ធទៅនឹងការអនុវត្តបទប្បញ្ញត្តិ ឬនីតិវិធីឱ្យបានត្រឹមត្រូវពាក់ព័ន្ធទៅនឹងការឃុំខ្លួនបណ្ដោះអាសន្ន។

---

[117] *សូមមើល ឧទាហរណ៍* សំណុំរឿង០០៤ (អបជ ០៥) សេចក្ដីសម្រេចលើសំណើក្រុមការពារក្ដី តា អាន សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេត, ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៣, ឯកសារ D121/4, កថាខណ្ឌ ៤៤។

[118] *សូមមើល ឧទាហរណ៍* ដូចឯកសារយោងខាងលើ, កថាខណ្ឌ ២៦, ដែលសហចៅក្រមស៊ើបអង្កេតបានធ្វើការកត់សម្គាល់ថា "វិធានផ្ទៃក្នុងបែងចែកយ៉ាងច្បាស់រវាងជនសង្ស័យ និងជនត្រូវចោទ ហើយផ្ដល់ជូនជនត្រូវចោទនូវសិទ្ធិកាន់តែទូលំទូលាយ"។ នៅកថាខណ្ឌ ៥៩ សហចៅក្រមស៊ើបអង្កេតបន្តគូសបញ្ជាក់អំពីសិទ្ធិរបស់ជនសង្ស័យ ដែលកំហិតត្រឹមការមានមេធាវីតំណាង ការជូនដំណឹងអំពីបទប្រកាន់ប្រឆាំងនឹងជនសង្ស័យ និងសិទ្ធិនៅស្ងៀមមិនឆ្លើយតប ដោយជនសង្ស័យពុំត្រូវបានអនុញ្ញាតឱ្យមានសិទ្ធិចូលរួមកិច្ចស៊ើបសួរឡើយ លុះត្រានៅពេលសហចៅក្រមស៊ើបអង្កេតដាក់ជនសង្ស័យឱ្យស្ថិតក្រោមការពិនិត្យជាផ្លូវការ។



PRE-TRIAL CHAMBER • E.C.C.C. • C.E.T.C. • CHAMBRE PRÉLIMINAIRE

៣. កាលណាជនត្រូវចោទមិនត្រូវបានឃុំខ្លួន ក្រោយពេលចូលបង្ហាញខ្លួនលើកដំបូងនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ជនត្រូវចោទនេះត្រូវជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេតអំពីអាសយដ្ឋានរបស់ខ្លួន។ ជនត្រូវចោទត្រូវទទួលការជូនដំណឹងដូចខាងក្រោមថា៖

ក) ខ្លួនត្រូវជូនព័ត៌មានដល់សហចៅក្រមស៊ើបអង្កេតនៅពេលណាមានការផ្លាស់ប្តូរអាសយដ្ឋាន

ខ) រាល់ការបញ្ជូនដីកា ឬការជូនដំណឹងទាំងអស់ដែលធ្វើឡើងចំពោះអាសយដ្ឋានចុងក្រោយដែលត្រូវបានផ្តល់ឱ្យ ត្រូវចាត់ទុកថាមានសុពលភាព។

៤. ការជូនដំណឹងនេះត្រូវកត់ត្រាទុកនៅក្នុងសំណុំរឿង។

វិធាន ៥៧ នៃវិធានផ្ទៃក្នុងចែងអំពីគោលការណ៍ថា ជនសង្ស័យគួរត្រូវបានប្រាប់អំពីបទចោទប្រកាន់ប្រឆាំងនឹងខ្លួន នៅពេលដែលជនសង្ស័យចូលបង្ហាញខ្លួនជាលើកដំបូង នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត *ដូចជា* នៅក្នុងការចូលបង្ហាញខ្លួនជាលើកដំបូងរបស់ជនសង្ស័យ។ ចៅក្រមដែលបានចុះហត្ថលេខាឯកភាពជាមួយសហមេធាវី ដែលថាការចូលបង្ហាញខ្លួនជាលើកដំបូងត្រូវធ្វើដោយមានវត្តមានរបស់ជនសង្ស័យ។ ប៉ុន្តែចំណុចនេះមិនមានអានុភាពលើបញ្ហាដែលយើងពិភាក្សានេះបានទេ។ នៅក្នុងសំណុំរឿងនាពេលបច្ចុប្បន្ន សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំបានធ្វើសវនាការនៃការចូលបង្ហាញខ្លួនលើកដំបូងរបស់ជនសង្ស័យ នៅពេលអវត្តមាន អ៊ឹម ចែម ឡើយ ប៉ុន្តែជំនួសមកវិញ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានសម្រេចថា ការធ្វើសវនាការនៃការចូលបង្ហាញខ្លួនលើកដំបូង ពុំមែនជាបុរេលក្ខខណ្ឌសម្រាប់ការដាក់ អ៊ឹម ចែម ឱ្យស្ថិតក្រោមការពិនិត្យ អនុលោមតាមវិធានផ្ទៃក្នុង និងប្រាប់ អ៊ឹម ចែម អំពីបទចោទប្រកាន់ តាមមធ្យោបាយផ្សេងៗ។ ហេតុដូច្នេះ ចៅក្រមដែលបានចុះហត្ថលេខាត្រូវពិនិត្យថាតើដំណើរការនេះផ្ទុយពីវិធានផ្ទៃក្នុងដែរឬយ៉ាងណា។

21. វិធានផ្ទៃក្នុងពុំបានចែងថា ការចូលបង្ហាញខ្លួនលើកដំបូង គឺជាបុរេលក្ខខណ្ឌសម្រាប់សហចៅ ក្រមស៊ើបអង្កេត *សម្រេច* ដាក់ជនសង្ស័យឱ្យស្ថិតក្រោមការពិនិត្យឡើយ ហើយវិធានផ្ទៃក្នុង បញ្ជាក់ច្បាស់លាស់ថា ការសម្រេចនេះគឺដាច់ដោយឡែកពីការជូនដំណឹងជាក់ស្តែងអំពីបទចោទប្រកាន់

ដែលធ្វើនៅពេលបន្ទាប់។ តាមរយៈវិធាន ៥៥(៤) និងវិធាន ៥៧ នៃវិធានផ្ទៃក្នុង ភាពច្បាស់លាស់គឺថា ការសម្រេចដាក់ជនសង្ស័យឱ្យស្ថិតក្រោមការពិនិត្យដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ត្រូវបានធ្វើ *ដោយភាគីតែម្ខាង* គឺភាគីសហចៅក្រមស៊ើបអង្កេត ឬសហចៅក្រមស៊ើបអង្កេតមួយរូបក្នុងចំណោមសហចៅក្រមស៊ើបអង្កេតទាំងអស់ ក្នុងករណីមានការខ្វែងយោបល់គ្នាក្នុងចំណោមសហចៅក្រមស៊ើបអង្កេត។ ជនសង្ស័យគ្មានសិទ្ធិថ្លែងប្រាស្រ័យមុនពេលមានដីកាសម្រេចឡើយ។ ក្នុងការចូលបង្ហាញខ្លួនលើកដំបូង ជនសង្ស័យគ្រាន់តែត្រូវបាន *ប្រាប់* អំពីបទចោទប្រកាន់ប៉ុណ្ណោះ។ ត្រង់ប្រការនេះ ចៅក្រមដែលបានចុះហត្ថលេខាខាកត់សម្គាល់ឃើញថា ឱកាសរបស់ "ជនត្រូវចោទ" ដើម្បីផ្តល់ចម្លើយ ពុំតម្រូវថា ជនត្រូវចោទអាចត្រូវបានស្តាប់ចម្លើយ មុនពេលមានដីកាសម្រេចដាក់ជនសង្ស័យឱ្យស្ថិតក្រោមការពិនិត្យឡើយ។ ផ្ទុយសមកវិញការបញ្ជាក់នៅក្នុងកថាខណ្ឌ ១ នៃវិធាន ៥៧ នៃវិធានផ្ទៃក្នុង គឺជាឱកាសដំបូងរបស់ជនត្រូវចោទដើម្បីបង្ហាញព័ត៌មានរបស់ខ្លួនជាផ្នែកមួយនៃកិច្ចស៊ើបសួរ។ ចៅក្រមដែលបានចុះហត្ថលេខាកត់សម្គាល់ឃើញថា វិធានផ្ទៃក្នុងឆ្លុះបញ្ចាំងច្បាប់កម្ពុជា[119] និងក្រមនីតិវិធីព្រហ្មទណ្ឌបារាំង[120]។ ការសន្និដ្ឋានបែបនេះគាំទ្រដោយទម្លាប់ជាប្រចាំរបស់ អ.វ.ត.ក រួមទាំងនៅក្នុងករណីនេះ ដែលជនជាប់ចោទដែលចូលបង្ហាញខ្លួនជាលើកដំបូងនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត (ឬសហចៅក្រមស៊ើបអង្កេតមួយរូបក្នុងចំណោមសហចៅក្រមស៊ើបអង្កេតទាំងអស់) ត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌមួយចំនួន ហើយបន្ទាប់មក ត្រូវបានស្នើសុំឱ្យផ្តល់ចម្លើយដោយគ្មានការពិភាក្សាដេញដោលថាតើជនចោទចោទគួរត្រូវបានចោទប្រកាន់ ឬអត់ឡើយ[121]។ ជា

---

[119] ស្រដៀងទៅនឹងវិធានផ្ទៃក្នុង មាត្រា ១២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាផ្តល់អំណាចទៅចៅក្រមស៊ើបអង្កេតដើម្បីដាក់ជនសង្ស័យឱ្យស្ថិតក្រោមការពិនិត្យ ដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានរឿងឱ្យស៊ើបសួរ និងមាត្រា ១៤៣ ចែងអំពីការជូនដំណឹងអំពីបទចោទប្រកាន់ក្នុងអំឡុងការចូលបង្ហាញខ្លួនលើកដំបូង។

[120] យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌបារាំង (មាត្រា ១១៦ វាក្យខណ្ឌ ៤ និង ៥) ក្នុងអំឡុងការចូលបង្ហាញខ្លួនជាលើកដំបូង ចៅក្រមស៊ើបអង្កេតប្រាប់ជននោះអំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរ សិទ្ធិផ្តល់ចម្លើយ ឬសិទ្ធិទទួលបានការសួរចម្លើយ។ បន្ទាប់ពីចៅក្រមស៊ើបអង្កេតប្រាប់ហើយ មិនថាជននោះនៅស្ងៀមមិនឆ្លើយតប ឬផ្តល់ចម្លើយ ឬត្រូវបានសួរចម្លើយពេញលេញឡើយ ចៅក្រមស៊ើបអង្កេតប្រាប់អំពីការសម្រេចរបស់គាត់ថាត្រូវដាក់ជននោះឱ្យស្ថិតក្រោមការពិនិត្យ ឬអត់។

[121] *សូមមើលឧទាហរណ៍* កំណត់ហេតុនៃការចូលខ្លួនដំបូងរបស់ កាំង ហ្គេកអ៊ាវ, ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៧, ឯកសារ E3/915, កំណត់ហេតុនៃការចូលខ្លួនដំបូងរបស់ នួន ជា, ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៧, ឯកសារ E3/54, កំណត់ហេតុនៃការចូលខ្លួនដំបូងរបស់ អៀង សារី, ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៧, ឯកសារ E3/92, កំណត់ហេតុនៃការចូលខ្លួនដំបូងរបស់



E.C.C.C. C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

ចុងក្រោយ ចៅក្រមដែលបានចុះហត្ថលេខាកត់សម្គាល់ឃើញថា សហមេធាវីពុំអះអាងថា អ៊ឹម ចែម គួរបានទទួលព័ត៌មានមុនពេលសម្រេចដាក់គាត់ឱ្យស្ថិតក្រោមការពិនិត្យឡើយ។ ជំនួសមកវិញ ពួកគាត់ផ្តោតទឡ្ហីករណ៍របស់ពួកគាត់ទៅលើដំណើរការនៃការជូនដំណឹងអំពីបទចោទប្រកាន់ដែលចៅក្រមដែលបានចុះហត្ថលេខានឹងធ្វើការបញ្ជាក់ជូននៅពេលនេះ។

22. ចៅក្រមដែលបានចុះហត្ថលេខា យល់ស្របជាមួយសហចៅក្រមស៊ើបអង្កេតដែលថា វិធាននីតិវិធីនៅ អ.វ.ត.ក ពុំចែងអំពីនីតិវិធីនៃការដាក់ជនសង្ស័យឱ្យស្ថិតក្រោមការពិនិត្យ ក្នុងករណីជនសង្ស័យបដិសេធមិនចូលបង្ហាញខ្លួនចំពោះមុខតុលាការ និងដែលវត្តមានរបស់គាត់មិនអាចធានាបានតាមរយៈវិធានការចាប់បង្ខំ[122] ត្រង់ផ្នែកដែលការសន្និដ្ឋានដូច្នេះទាក់ទង*ការជូនដំណឹង*អំពី បទចោទប្រកាន់។ វិធានផ្ទៃក្នុងចែងថា សហចៅក្រមស៊ើបអង្កេតអាចធានាបានវត្តមានរបស់ជនសង្ស័យ នៅក្នុងការចូលបង្ហាញខ្លួនលើកដំបូង តាមរយៈការចេញដីកាកោះ ដីកាបង្គាប់ឱ្យនាំខ្លួន ឬដីកាបង្គាប់ឱ្យចាប់ខ្លួន និងដីកាបង្គាប់ឱ្យឃុំខ្លួន[123]។ វិធានផ្ទៃក្នុងចែងទៀតថា ដីកាកោះ និងដីកាបង្គាប់ឱ្យនាំខ្លួនត្រូវអនុវត្ត[124] ដោយនគរបាលយុត្តិធម៌[125]។ អនុលោមតាមវិធាន ៤៥(៣) នៃវិធានផ្ទៃក្នុង "នគរបាលយុត្តិធម៌ត្រូវផ្តល់ព័ត៌មានដល់សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះអំពីបញ្ហាលំបាក ដែលខ្លួនជួបប្រទះក្នុងការបំពេញមុខងាររបស់ខ្លួន"។ ជាចុងក្រោយ កិច្ចព្រមព្រៀង និងច្បាប់ អ.វ.ត.ក ចែងថា រាជរដ្ឋាភិបាលកម្ពុជាត្រូវផ្តល់ការជួយជ្រោមជ្រែងទៅសហចៅក្រមស៊ើបអង្កេត ដើម្បីអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន[126] *ក្នុងចំណោមដីកាផ្សេងៗ*។ ពុំមានបញ្ញត្តិណា

---

អៀង ធីរិទ្ធ, ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៧, ឯកសារ E3/664, កំណត់ហេតុនៃការចូលខ្លួនដំបូងរបស់ ខៀវ សំផន, ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧, ឯកសារ D42, កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ អោ អាន, ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៥, ឯកសារ D242៖ ដែលក្នុងនោះអត្តសញ្ញាណរបស់ជនសង្ស័យត្រូវបានបញ្ជាក់អះអាង, បទចោទប្រឆាំងនឹងជនសង្ស័យត្រូវបានអាន និងបញ្ជាក់អះអាង ហើយ "ជនត្រូវចោទ" ត្រូវបានស្នើសុំឱ្យផ្តល់ចម្លើយជាលើកដំបូង។

[122] ដីកាសម្រេចដែលត្រូវបានជំទាស់, កថាខណ្ឌ ៤០។

[123] *សូមមើល* វិធាន ៤១, ៤២, ៤៤ និង ៥៥(៥) នៃវិធានផ្ទៃក្នុង។

[124] *សូមមើល* វិធាន៤១(៤)នៃវិធានផ្ទៃក្នុង។

[125] *សូមមើល* វិធាន៤៥(២) នៃវិធានផ្ទៃក្នុង។

[126] មាត្រា២៥(គ)នៃកិច្ចព្រមព្រៀង, មាត្រា២៣ថ្មីនៃច្បាប់ អ.វ.ត.ក។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. • C.E.T.C.

ទៀតដែលចែងអំពីកាលៈទេសៈដែលដីកាបង្គាប់ឱ្យនាំខ្លួនពុំត្រូវបានអនុវត្ត តាមរយៈការជួយជ្រោមជ្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាឡើយ។

23. ផ្ទុយមកវិញ គ្មានការមន្ទិលសង្ស័យដែលថា លទ្ធភាពនៃការបង្ហាញខ្លួនលើកដំបូង អនុលោមតាមវិធាន ៥៧ នៃវិធានផ្ទៃក្នុង នឹងបញ្ឈប់កិច្ចដំណើរការនីតិវិធីឡើយ។ តាមវិធានផ្ទៃក្នុង វាមានភាពច្បាស់លាស់ដែលថា សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចដើម្បីបំពេញកិច្ចស៊ើបសួរ នៅពេលទទួលបានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[127] និងសន្និដ្ឋានថាត្រូវលើកលែងការចោទប្រកាន់ ឬត្រូវបញ្ជូនរឿងទៅជំនុំជម្រះ[128]។ ហេតុនេះ អវត្តមាននៃមធ្យោបាយមួយផ្សេងទៀតដើម្បីបន្តកិច្ចដំណើរការនីតិវិធី នៅពេលដែលការចូលបង្ហាញខ្លួនលើកដំបូងមិនអាចធ្វើទៅបាន ពុំបង្ហាញថា ការបង្ហាញខ្លួនលើកដំបូងគឺជាមធ្យោបាយស្របច្បាប់តែមួយគត់ដើម្បីជូនដំណឹងអំពីបទចោទប្រកាន់។ ប៉ុន្តែចន្លោះប្រហោងមួយនេះនៅក្នុងវិធានផ្ទៃក្នុងតម្រូវឱ្យមានការពិនិត្យទៅលើច្បាប់កម្ពុជា[129]។

24. ក្នុងច្បាប់កម្ពុជា នៅពេលចៅក្រមស៊ើបអង្កេតពុំអាចធានាបានវត្តមានរបស់ជនសង្ស័យនៅក្នុងការចូលបង្ហាញខ្លួនលើកដំបូង តាមរយៈដីកាបង្គាប់ឱ្យចូលខ្លួន[130] ដីកាបង្គាប់ឱ្យនាំខ្លួន[131] (ដូចគ្នាទៅនឹង "ដីកាបង្គាប់ឱ្យនាំខ្លួន" នៅក្នុងវិធាន អ.វ.ត.ក)[132] ឬដីកាបង្គាប់ឱ្យចាប់ខ្លួន[133] (ដូចគ្នាទៅនឹង "ដីកាបង្គាប់ឱ្យចាប់ខ្លួន" នៅក្នុងវិធាន អ.វ.ត.ក)[134] កិច្ចដំណើរការនីតិវិធីបន្តដោយអវត្តមាន

---

[127] វិធាន៥៥(១) នៃវិធានផ្ទៃក្នុង។

[128] វិធាន ៦៧(១) នៃវិធានផ្ទៃក្នុង។

[129] *សូមមើល* សំណុំរឿង ០០២ (អបជ ០៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងដីកាបដិសេធសំណើសុំធ្វើមោឃភាព,ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០៨, ឯកសារ D55/1/8 ត្រង់កថាខណ្ឌ ១៥, ដែលអង្គបុរេជំនុំជម្រះបានសម្រេចថា "បញ្ញត្តិនានានៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាគួរអនុវត្តនៅពេលមានបញ្ហាកើតឡើងដែលគ្មានចែងក្នុងវិធានផ្ទៃក្នុង" ប៉ុន្តែក្នុងករណីមានភាពស្រពិចស្រពិល គួរស្វែងរកការណែនាំជាមុននៅក្នុងក្របខណ្ឌអន្តរជាតិ អនុលោមតាមកិច្ចព្រមព្រៀង អ.វ.ត.ក។

[130] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា, មាត្រា ១៨៥-១៨៨។

[131] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា, មាត្រា ១៨៥, មាត្រា ១៨៩-១៩៤។

[132] វិធាន ៤២ នៃវិធានផ្ទៃក្នុង។

[133] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា, មាត្រា ១៨៥, មាត្រា ១៩៥-២០២។

[134] វិធាន ៤៤ នៃវិធានផ្ទៃក្នុង។

ជនសង្ស័យរហូតដល់ពេលមានសាលក្រម[135]។ ដីកាបង្គាប់ឱ្យចូលខ្លួន ដីកាបង្គាប់ឱ្យនាំខ្លួន និង ដីកាបង្គាប់ឱ្យចាប់ខ្លួន ត្រូវមានការជូនដំណឹងអំពីបទចោទប្រកាន់ដែលស្រដៀងទៅនឹងអ្វីដែលធ្វើក្នុងការចូលបង្ហាញខ្លួនលើកដំបូង[136]។ ចុងចោទត្រូវបានចាត់ទុកជា“ជនត្រូវចោទ” យ៉ាងយូរបំផុតចាប់ពីពេលមានដីកាបង្គាប់ឱ្យនាំខ្លួន[137]។ មិនមានភាពស្រពិចស្រពិលឡើយដែលថា ការបង្ហាញខ្លួនលើកដំបូងពុំចាំបាច់សម្រាប់ជនណាម្នាក់ដែលត្រូវបានចាត់ទុកជា “ជនត្រូវចោទ” ក្រោមច្បាប់កម្ពុជា និងដើម្បីបន្តកិច្ចដំណើរការនីតិវិធី។ ប៉ុន្តែច្បាប់កម្ពុជាពុំសូវមានភាពច្បាស់លាស់ពាក់ព័ន្ធការកំណត់លក្ខខណ្ឌសម្រាប់បន្តកិច្ចដំណើរការនីតិវិធី *ដោយកំបាំងមុខ* ក្រោយពេលមានដីកាបង្គាប់ឱ្យចាប់ខ្លួន។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាចែងថា ដីកាបង្គាប់ឱ្យចាប់ខ្លួនអាចត្រូវបានផ្សព្វផ្សាយទៅតាមអង្គភាពនគរបាល និងកងរាជអាវុធហត្ថ ព្រមទាំងផ្សព្វផ្សាយជាអន្តរជាតិ ក្នុងករណីចាំបាច់[138]។ មាត្រា ១៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាចែងទៀតថាមន្ត្រីនគរបាលយុត្តិធម៌ត្រូវ “ឱ្យដំណឹងដល់ចៅក្រមស៊ើបសួរអំពីការលំបាក ទាំងអស់ក្នុងពេលអនុវត្តសកម្មភាពរបស់ខ្លួន”។ ប្រសិនបើការខកខានអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួន បណ្តាលមកពីកំហុសរបស់មន្ត្រីនគរបាលយុត្តិធម៌ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាចែងអំពីវិធានការខាងវិន័យប្រឆាំងនឹងមន្ត្រីនោះ[139] ប៉ុន្តែពុំចែងអំពីលក្ខខណ្ឌតម្រូវដើម្បីបន្តកិច្ចដំណើរការនីតិវិធីឡើយ។

---

135 *សូមមើល* ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា៣៣៣ (“ការស្វែងរកការពិតក្នុងករណីអវត្តមានរបស់ជនជាប់ចោទ”, មាត្រា ៣៥១ (“អវត្តមានរបស់ជនជាប់ចោទ”), មាត្រា៣៦០ (“សាលក្រមចំពោះមុខ”), មាត្រា៣៦១ (“សាលក្រមដែលត្រូវចាត់ទុកថាចំពោះមុខ”) និងមាត្រា ៣៦២ (“សាលក្រមកំបាំងមុខ”)។

136 មាត្រា ១៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាចែងថាដីកាបង្គាប់ឱ្យនាំខ្លួនត្រូវបញ្ជាក់អំពីបទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ” ចំណែកមាត្រា១៤៣ ចែងថាជនត្រូវចោទត្រូវទទួលការជូនដំណឹងនៅពេលចូលបង្ហាញខ្លួនលើកដំបូងអំពី “រឿងរ៉ាវដែលចោទប្រកាន់ និងឈ្មោះបទល្មើសដែលកំណត់ដោយច្បាប់”។ *សូមមើល* ផងដែរមាត្រា ១៩៨ សម្រាប់ដីកាបង្គាប់ឱ្យចាប់ខ្លួន និងមាត្រា ១៨៧ សម្រាប់ដីកាបង្គាប់ឱ្យចូលខ្លួន។

137 អនុលោមតាមមាត្រា ១៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដីកាបង្គាប់ឱ្យនាំខ្លួនអាចត្រូវចេញទៅលើ “ជនត្រូវចោទ ឬទៅលើបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព”។

138 មាត្រា ១៩៩ និងមាត្រា ២០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

139 មាត្រា ៦៤ និងមាត្រា ៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា តម្រូវឱ្យចៅក្រមស៊ើបអង្កេត ឬព្រះ[illegible]ការណ៍អំពីកំហុសទាំងឡាយដែលប្រព្រឹត្តដោយមន្ត្រីនគរបាលយុត្តិធម៌នៅក្នុងពេលអនុវត្តមុខងាររបស់ខ្លួន [illegible]លោ

25. នៅត្រង់ប្រការនេះ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំងដែលជាគម្រូនៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាផ្តល់ការណែនាំខ្លះៗ។ មាត្រា ១៣៤ ចែងថា ប្រសិនបើដីកាបង្គាប់ឱ្យចាប់ខ្លួនពុំអាចត្រូវបានអនុវត្តទៅបាន "របាយការណ៍ជាផ្លូវការមួយស្តីពីការស៊ើបអង្កេតពុំបានជោគជ័យ ត្រូវផ្ញើទៅចៅក្រមដែលបានចេញដីកានោះ"។ មាត្រា ១៣៤ នេះចែងទៀតថា "សាមីជននោះបន្ទាប់មកត្រូវបានចាត់ទុកថាបានរងការចោទប្រកាន់ថា *មានបំណងបិទការស៊ើបអង្កេត*"[140]។ ស្រដៀងនឹងនីតិវិធីក្រោមច្បាប់កម្ពុជាដែរ កិច្ចដំណើរការនីតិវិធីបន្តដោយមិនមានវត្តមានរបស់ចុងចោទរហូតដល់ពេលចេញសាលក្រម[141]។ នៅក្រោមច្បាប់បារាំង ជនណាក៏ដោយពុំអាចទាមទារសិទ្ធិសម្រាប់ជនត្រូវចោទបានឡើយ កាលណាជននោះបដិសេធពុំចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ[142]។

26. តាមអ្វីដែលបានលើកពីខាងលើ ចៅក្រមដែលបានចុះហត្ថលេខា យល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសន្និដ្ឋានយ៉ាងត្រឹមត្រូវថា ការចូលបង្ហាញខ្លួនលើកដំបូង ពុំមែនជាបុរេលក្ខខណ្ឌសម្រាប់ការដាក់ជនសង្ស័យឱ្យស្ថិតក្រោមការពិនិត្យ នៅចំពោះមុខ អ.វ.ត.ក ឡើយ ប៉ុន្តែវិធានផ្ទៃក្នុងពុំចែងច្បាស់អំពីកាលៈទេសៈដែលមិនអាចឱ្យមានការចូលបង្ហាញខ្លួនលើកដំបូង។

---

ឧទ្ធរណ៍ ដែលអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍អាច i) រាយការណ៍អំពីបញ្ហានេះទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដើម្បី ផ្តើមដំណើរការនីតិវិធីវិន័យ ឬ ii) ហាមឃាត់មិនឱ្យមន្ត្រីនគរបាលយុត្តិធម៌នោះ បំពេញមុខងារជាបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍។

[140] មាត្រា ១៣៤ ចែងថា៖

« L'agent chargé de l'exécution d'un mandat d'amener, d'arrêt et de recherche ne peut s'introduire dans le domicile d'un citoyen avant 6 heures ni après 21 heures. Il en est de même lorsque l'agent est chargé de l'arrestation d'une personne faisant l'objet d'une demande d'extradition ou d'un mandat d'arrêt européen.
Il peut se faire accompagner d'une force suffisante pour que la personne ne puisse se soustraire à la loi. La force est prise dans le lieu le plus proche de celui où le mandat doit s'exécuter et elle est tenue de déférer aux réquisitions contenues dans ce mandat.
Si la personne ne peut être saisie, un procès-verbal de perquisition et de recherches infructueuses est adressé au magistrat qui a délivré le mandat. La personne est alors considérée comme mise en examen pour l'application de l'article 176. »។

[141] មាត្រា ៣៧៩-២ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង។

[142] Crim Cass., Bull. Crim. 2002, លេខ ១១១ ទំព័រ ៣៧២ (ដែលបានបដិសេធបណ្តឹងឧទ្ធរណ៍ថាមិនអាចឱ្យទទួលយកបានដោយសំអាងថាម្ចាស់បណ្តឹងឧទ្ធរណ៍ ដែលបានខកខានមិនបានចូលមកបង្ហាញខ្លួននៅចំពោះមុខតុលាការ ក្រោយពេលមានដីកាបង្គាប់ឱ្យចាប់ខ្លួន ពុំមានឋានៈជា "ជនត្រូវចោទ" ឡើយ)។ Crim. Cass., Bull. Crim. 2002, លេខ ២៣០, ទំព័រ ៨៤៣ (ដែលបានសម្រេចថាជនណាក៏ដោយដែលពុំបានចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ ពុំមានសិទ្ធិស្នើសុំឱ្យមោឃភាពដីកាបង្គាប់ឱ្យចាប់ខ្លួនដែលត្រូវបានចេញប្រឆាំងនឹងខ្លួនបានឡើយ)។

ផ្ទុយពីការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ[143] ច្បាប់កម្ពុជាផ្តល់ការណែនាំខ្លះៗ ត្រង់ប្រការនេះ ត្រង់ចំណុចដែលច្បាប់កម្ពុជាអនុញ្ញាតឲ្យដាក់ជនសង្ស័យក្រោមការពិនិត្យតាមរយៈ ដីកាកោះ ដីកាបង្គាប់ឲ្យនាំខ្លួន ឬដីកាបង្គាប់ឲ្យចាប់ខ្លួន និងការបន្តកិច្ចដំណើរការនីតិវិធីរហូតដល់ ចប់កិច្ចស៊ើបសួរដោយអវត្តមានជនត្រូវចោទ។

27. នៅក្នុងករណីនាពេលបច្ចុប្បន្ននេះ នគរបាលយុត្តិធម៌ពុំបានរាយការណ៍ឡើយអំពីការលំបាកដែល ខ្លួនបានជួបប្រទះក្នុងការអនុវត្តដីកាបង្គាប់ឲ្យចាប់ខ្លួន ឬបានចេញរបាយការណ៍អំពីការស៊ើបអង្កេត ដែលពុំបានជោគជ័យ បើទោះបីជាដីកាបង្គាប់ឲ្យនាំខ្លួនបានចេញជាងមួយឆ្នាំទៅហើយក្តី។ ហេតុនេះ ចៅក្រមដែលបានចុះហត្ថលេខាយល់ឃើញថា ច្បាប់កម្ពុជាពុំអាចជួយសម្រេចថាតើ មានការខិតខំគ្រប់គ្រាន់ហើយ ឬនៅ ដើម្បីធានាឲ្យមានវត្តមានរបស់ អ៊ឹម ចែម នៅក្នុងពេល ចូលបង្ហាញខ្លួនលើកដំបូងនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលបានសម្រេច ប្រាប់ អ៊ឹម ចែម អំពីបទចោទប្រកាន់ជាលាយលក្ខណ៍អក្សរតាមរយៈមេធាវីរបស់គាត់។ *ចំណុច ចន្លោះប្រហោង* មួយនេះនៅក្នុងច្បាប់កម្ពុជា នៅពេលអនុវត្តនៅក្នុងកិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក ឆ្លុះបញ្ចាំងអំពីកាលៈទេសៈជាក់លាក់មួយក្នុងចំណោមកាលៈទេសៈនានា ដែលតុលាការ ឧក្រិដ្ឋកម្មអន្តរជាតុបនីយកម្មបានជួបប្រទះ ដែលតុលាការទាំងនោះខ្វះកម្លាំងក្នុងការអនុវត្តច្បាប់ របស់ខ្លួន និងពឹងផ្អែកលើកិច្ចសហការរបស់រដ្ឋដើម្បីអនុវត្តដីកាបង្គាប់ឲ្យចាប់ខ្លួន។ អនុលោមតាម មាត្រា ១២(១) នៃកិច្ចព្រមព្រៀង មាត្រា២៣ថ្មី នៃច្បាប់ អ.វ.ត.ក និងវិធាន២នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំខុសឆ្គងឡើយក្នុងការស្វែងរកការណែនាំនៅក្នុងវិធាននីតិវិធី ដែលចែងក្នុងកម្រិតអន្តរជាតិ។

28. ចៅក្រមដែលបានចុះហត្ថលេខា យល់ឃើញទៀតថា វាជាការសមស្របដែលសហចៅក្រម ស៊ើបអង្កេតអន្តរជាតិត្រូវពិនិត្យឲ្យបានទូទៅជាងនេះទៀត អំពីវិធាននៃតុលាការអន្តរជាតិទាំង ឡាយស្តីពីវិធានការពិសេស ដើម្បីបន្តកិច្ចដំណើរការនីតិវិធី នៅមុនដំណាក់កាលជំនុំជម្រះ នៅ ពេលដែលដីកាបង្គាប់ឲ្យនាំខ្លួនពុំត្រូវបានអនុវត្ត ឬជនសង្ស័យពុំអាចត្រូវបានប្រាប់អំពីបទចោទ ប្រកាន់ដោយផ្ទាល់។

---

[143] ដីកាសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ៤៦។

## គ. កំហុសដែលត្រូវបានចោទប្រកាន់នៅក្នុងការអនុវត្តច្បាប់សិទ្ធិមនុស្ស និងវិធាននីតិវិធីដែលមានចែងនៅក្នុងកម្រិតអន្តរជាតិ

29. ចៅក្រមដែលបានចុះហត្ថលេខាសូមបញ្ជាក់ថា ក្រៅពី អ.វ.ត.ក គ្មានតុលាការឧក្រិដ្ឋកម្មអន្តរជាតិណាមួយអនុវត្តប្រព័ន្ធច្បាប់នៃការជជីកសួរហេតុផលដោយចៅក្រម និងបំពេញកិច្ចស៊ើបសួរតាមផ្លូវតុលាការឡើយ។ ចៅក្រមដែលបានចុះហត្ថលេខាយល់ស្របជាមួយសហមេធាវីដែលថា ដោយហេតុថា តុលាការអន្តរជាតិនានាពុំមានវិធានការនីតិវិធីសមមូលទៅនឹង *"mise en examen"* (ន័យត្រង់ "ការដាក់ឱ្យស្ថិតក្រោមកិច្ចស៊ើបសួរ") វិធាននៃតុលាការទាំងនេះពុំអាចអនុវត្ត *ក្រោយមានការកែប្រែជាចាំបាច់* នៅ អ.វ.ត.ក បានឡើយ។ ទោះយ៉ាងណា អ.វ.ត.ក អាចស្វែងរកការណែនាំនៅក្នុងគោលការណ៍ទូទៅ ពិសេសត្រង់ផ្នែកដែលគោលការណ៍ទាំងនោះផ្តល់ជម្រើសមួយទៀតដើម្បីបន្តកិច្ចដំណើរការនីតិវិធី នៅពេលដីកាបង្គាប់ឱ្យនាំខ្លួនមិនបានអនុវត្តក្នុងរយៈពេលសមស្រប។ ដោយហេតុថា កិច្ចដំណើរការនីតិវិធីនាពេលបច្ចុប្បន្នពុំបានធ្វើ*ដោយកំបាំងមុខ* ហើយពុំមានសវនាការណាមួយធ្វើនៅក្នុងពេលអវត្តមាន អ៊ឹម ចែម ចៅក្រមដែលបានចុះហត្ថលេខាសូមបញ្ជាក់ថាគោលបំណងនៃការពិនិត្យមើលច្បាប់អន្តរជាតិឡើងវិញនៅត្រង់នេះ គឺពុំមែនដើម្បីពិនិត្យថាតើកិច្ចដំណើរការនីតិវិធី *ដោយកំបាំងមុខ* "អាចអនុញ្ញាតឱ្យធ្វើទៅបាន" *ដោយស្វ័យប្រវត្ត*ឡើយ។ ជំនួសមកវិញ ចៅក្រមដែលបានចុះហត្ថលេខាពិចារណាឃើញថា វិធាននីតិវិធីដែលមានចែងក្នុងកម្រិតអន្តរជាតិ អាចផ្តល់ការណែនាំអំពីលក្ខខណ្ឌនានាសម្រាប់ដាក់ជនសង្ស័យឱ្យស្ថិតក្រោមការពិនិត្យ ដោយគ្មានការចូលបង្ហាញខ្លួនលើកដំបូង និងជម្រើសផ្សេងទៀតដើម្បីជូនដំណឹងពីបទចោទប្រកាន់។

30. នៅឯតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់យូហ្គោស្លាវី តុលាការឧក្រិដ្ឋកម្មអន្តរជាតិនៅរ៉្វាន់ដា និងតុលាការពិសេសនៅសៀរ៉ាឡេអូន និងតុលាការពិសេសសម្រាប់លីបង់ ជាគោលការណ៍ ជនជាប់ចោទត្រូវបានប្រគល់ឱ្យដោយផ្ទាល់ដៃនូវដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅពេលជនជាប់ចោទត្រូវបានដាក់ក្នុងមន្ទីរឃុំឃាំងលើកដំបូង[144] ឬត្រូវបានជួបដោយអាជ្ញាធរមានសមត្ថកិច្ច[145] ហើយ

---

[144] *សូមមើល៖* វិធាននីតិវិធី និងភ័ស្តុតាងនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់យូហ្គោស្លាវី, វិធាន ៥៣ *ស្ទួន*, វិធាននីតិវិធី និងភ័ស្តុតាងនៃតុលាការតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រ៉្វាន់ដា, វិធាន ៥៣ *ស្ទួន*, វិធាននីតិវិធី និងភ័ស្តុតាងនៃតុលាការពិសេសសម្រាប់សៀរ៉ាឡេអូន, វិធាន ៥២។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C • C.E.T.C

បន្ទាប់មកត្រូវបានចោទប្រកាន់ជាផ្លូវការដោយអាជ្ញាធរតុលាការដែលមានសមត្ថកិច្ច នៅពេលជនជាប់ចោទចូលបង្ហាញខ្លួនដំបូងនៅចំពោះសាលាជម្រះក្តី ឬតុលាការ[146]។ ស្រដៀងនេះ នៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិ អាជ្ញាធរមានសមត្ថកិច្ចជាតិអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួន និងត្រូវប្រាប់ជនជាប់ចោទអំពីបទចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទនៅពេលចាប់ខ្លួន[147]។ ជនជាប់ចោទត្រូវបានប្រាប់អំពីបទចោទប្រកាន់ដោយតុលាការនៅពេលចូលបង្ហាញខ្លួនលើកដំបូង[148]។ ការប្រគល់ដីកាចោទប្រកាន់ពុំទាន់ធ្វើទៅឡើយ លុះត្រាតែបទចោទប្រកាន់ត្រូវបានបញ្ជាក់អះអាង ក្រោយពេលជនជាប់ចោទចូលបង្ហាញខ្លួនលើកដំបូង[149]។ អ្វីដែលគួរជាទីចាប់អារម្មណ៍អំពីករណីបច្ចុប្បន្ននេះគឺថា តុលាការព្រហ្មទណ្ឌអន្តរជាតិ តុលាការ ICTY តុលាការ ICTR និងតុលាការ TSL ទាំងអស់សុទ្ធតែចែងអំពីវិធានការពិសេសដើម្បីបញ្ចៀសការជាប់គាំងកិច្ចដំណើរការនីតិវិធី នៅពេលការប្រគល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនអាចធ្វើទៅបានដោយផ្ទាល់ដៃ ដូចមានចែងក្នុងវិធានជាធរមាន ឬនៅពេលដីកាបង្គាប់ឱ្យចាប់ខ្លួនមិនត្រូវបានអនុវត្ត។

31. នៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិ មាត្រា ៦១(២) នៃលក្ខន្តិកៈទីក្រុងរ៉ូម អនុញ្ញាតឱ្យការបញ្ជាក់អះអាងអំពីដីកាបញ្ជូនរឿងទៅជំនុំជម្រះអាចធ្វើទៅបាន ក្នុងពេលអវត្តមានជនសង្ស័យ នៅពេលមិនអាចធានាឱ្យមានវត្តមានរបស់ជនសង្ស័យ។ ដើម្បីបន្តនីតិវិធីនៅពេលអវត្តមានជនសង្ស័យ អង្គបុរេជំនុំជម្រះត្រូវតែជឿជាក់ថា ជនសង្ស័យបាន៖

---

145 វិធាននីតិវិធី និងភស្តុតាងតុលាការពិសេសសម្រាប់លីបង់, វិធាន ៧៦(ខ)។

146 *សូមមើល៖* វិធាននីតិវិធី និងភស្តុតាងនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់យូហ្គោស្លាវី, វិធាន ៦២(ក)(ii), វិធាននីតិវិធី និងភស្តុតាងនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រ្វាន់ដា, វិធាន ៦២(ii), វិធាននីតិវិធី និងភស្តុតាងនៃតុលាការពិសេសសម្រាប់ សៀរ៉ាឡេអូន, វិធាន ៦១(ii), វិធាននីតិវិធី និងភស្តុតាងនៃតុលាការពិសេសសម្រាប់លីបង់, វិធាន ៩៨(ក)(ii)។

147 តាមមាត្រា ៥៩(២) នៃលក្ខន្តិកៈទីក្រុងរ៉ូម៖

"ជនដែលត្រូវបានចាប់ខ្លួន ត្រូវនាំខ្លួនយ៉ាងរហ័សមកកាន់អាជ្ញាធរយុត្តិធម៌មានសមត្ថកិច្ចនៅក្នុងរដ្ឋដែលគ្រប់គ្រងជននោះ ថា៖

(ក) ដីកាអនុវត្តលើជននោះ

(ខ) ជននោះត្រូវចាប់ខ្លួន ស្របតាមដំណើរការត្រឹមត្រូវ និង

(គ) សិទ្ធិរបស់ជននោះត្រូវបានគេគោរព"។

148 លក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ, មាត្រា ៦០(១)។

149 លក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ, មាត្រា ៦១។

(ក) លះបង់សិទ្ធិមានសិទ្ធិមានវត្តមាន ឬ

(ខ) គេចខ្លួន ឬគេចខ្លួនបាត់រកមិនឃើញ ហើយគ្រប់មធ្យោបាយសមហេតុផលទាំងអស់ត្រូវបានប្រើប្រាស់ដើម្បីធ្វើឱ្យគាត់មានវត្តមានចំពោះមុខតុលាការ និងដើម្បីផ្តល់ព័ត៌មានដល់ជននោះអំពីបទចោទប្រកាន់ ហើយថា សវនាការមួយនឹងត្រូវធ្វើឡើងដើម្បីបញ្ជាក់អំពីបទចោទប្រកាន់ទាំងនោះ[150]។

ទាក់ទងលក្ខខណ្ឌទីមួយ គួរកត់សម្គាល់ថា ដើម្បីលះបង់សិទ្ធិរបស់ខ្លួនក្នុងការមានវត្តមាន សាមីជនត្រូវតែ "អាចឱ្យ តុលាការទាក់ទងបាន" និងធ្វើសំណើក្នុងន័យនេះមកអង្គបុរេជំនុំជម្រះ។ អង្គបុរេជំនុំជម្រះត្រូវតែ ជឿជាក់ថា "សាមីជនយល់អំពីសិទ្ធិមានវត្តមាន នៅសវនាការ និងផលវិបាកនៃការលះបង់សិទ្ធិនេះ"[151]។ ទាក់ទងលក្ខខណ្ឌទីពីរ អង្គបុរេជំនុំជម្រះត្រូវធានាបានថា "វិធានការសមស្របទាំងអស់ ត្រូវបានអនុវត្តដើម្បីស្វែងរក និងចាប់ខ្លួនជននោះ"[152]។ ក្នុងអំឡុងពេលនៃដំណើរការនេះ អង្គបុរេជំនុំជម្រះ អាចធ្វើការពិគ្រោះយោបល់ជាមួយរដ្ឋអាជ្ញា ដោយមានវត្តមានរបស់មេធាវីការពារជនជាប់ចោទ ប្រសិនបើជនជាប់ចោទបានតែងតាំងមេធាវី[153]។ អង្គជំនុំជម្រះត្រូវជូនដំណឹងអំពីការសម្រេចរបស់ខ្លួន "ប្រសិនបើធ្វើទៅបាន ទៅសាមីជន ឬមេធាវីរបស់សាមីជន"[154]។

32. នៅតុលាការ ICTY និងតុលាការ ICTR វិធាន ៦១ នៃវិធាននីតិវិធី និងភស្តុតាង ចែងអំពីការធ្វើសវនាការដើម្បី "បញ្ជាក់ជាថ្មីអំពីដីកាបញ្ជូនរឿងទៅជំនុំជម្រះ"[155] ពេលអវត្តមានជនជាប់ចោទ

---

[150] មាត្រា៦១(២) នៃលក្ខន្តិកៈទីក្រុងរ៉ូម។

[151] វិធាន ១២៤ នៃវិធាននីតិវិធី និងភស្តុតាងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ។

[152] វិធាន ១២៣ នៃវិធាននីតិវិធី និងភស្តុតាងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ។

[153] វិធាន ១២៣ នៃវិធាននីតិវិធី និងភស្តុតាងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ។

[154] វិធាន ១២៥(២) នៃវិធាននីតិវិធី និងភស្តុតាងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ។

[155] នៅក្នុង *សំណុំរឿង រដ្ឋអាជ្ញា ទល់នឹង Karadžić និង Mladić* លេខសំណុំរឿង IT-95-5-R61 និង IT-95-18-R61, ការពិនិត្យឡើងវិញអំពីដីកាចោទប្រកាន់អនុលោមតាមវិធាន ៦១ នៃវិធាននីតិវិធី និងភស្តុតាង, ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ១៩៩៦ កថាខណ្ឌ ៣, អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថាគោលបំណងនៃសវនាការតាមវិធាន ... គឺដើម្បីអនុញ្ញាតឱ្យកិច្ចដំណើរការនីតិវិធីបន្ត តាមរយៈការបញ្ជាក់ជាថ្មីអំពីការចោទប្រកាន់នៅពេលអវត្តមាននៃជនជាប់ចោទ។

"នៅពេលដីកាបង្គាប់ឱ្យចាប់ខ្លួនពុំត្រូវបានអនុវត្ត ហើយការប្រគល់ដោយផ្ទាល់នូវដីកាចោទប្រកាន់ពុំមានប្រសិទ្ធភាព"។ ប្រសិនបើជឿជាក់ថាមានមូលដ្ឋានសមស្របដើម្បីជឿថាជនជាប់ចោទបានប្រព្រឹត្តបទល្មើសដែលត្រូវបានចោទប្រកាន់នោះ អង្គជំនុំជម្រះសាលាដំបូងអាចអានដីកាចោទប្រកាន់នៅក្នុងសវនាការដែលគ្មានវត្តមានជនជាប់ចោទ ចេញដីកាបង្គាប់ឱ្យចាប់ខ្លួនជាអន្តរជាតិ និងនៅក្នុងករណីប្រទេសរបស់ជនជាប់ចោទពុំបានសហការ ត្រូវបញ្ជូនបញ្ហានេះទៅក្រុមប្រឹក្សាសន្តិសុខ[156]។ ដើម្បីបន្តនីតិវិធី អង្គជំនុំជម្រះសាលាដំបូងត្រូវតែជឿជាក់ថា៖

i) ក្រឡាបញ្ជី និងរដ្ឋអាជ្ញាបានចាត់វិធានការសមស្របទាំងអស់ដើម្បីធានាឱ្យបានការចាប់ខ្លួនជនជាប់ចោទ រួមទាំងការប្រើប្រាស់សិទ្ធិអំណាចសមស្របរបស់រដ្ឋដែលជាដែនដីរបស់ជនជាប់ចោទ ឬមួយជនជាប់ចោទស្ថិតក្រោមយុត្តាធិការ ឬការគ្រប់គ្រងរបស់រដ្ឋនោះ ដែលជននោះកំពុងតាំងទីលំនៅ ឬបានតាំងលំនៅជាលើកចុងក្រោយ និង

ii) ប្រសិនបើមិនដឹងអំពីទីកន្លែងសំចតរបស់ជនជាប់ចោទ រដ្ឋអាជ្ញា និងក្រឡាបញ្ជីចាត់វិធានការសមស្របទាំងអស់ដើម្បីបញ្ជាក់អំពីទីកន្លែងសំចតទាំងនោះ រួមទាំង តាមរយៈការបោះពុម្ពផ្សព្វផ្សាយ អនុលោមតាមវិធាន ៦០[157]។

អនុលោមតាមវិធាន ៦០៖

តាមសំណើរបស់រដ្ឋអាជ្ញា ទម្រង់មួយនៃការផ្សាយត្រូវបញ្ជូនដោយក្រឡាបញ្ជីទៅ អាជ្ញាធរជាតិរបស់រដ្ឋនានា ដើម្បីផ្សព្វផ្សាយក្នុងសារព័ត៌មាន ឬចាក់ផ្សាយតាមវិទ្យុ និងទូរទស្សន៍ ដោយជូនដំណឹងជាសាធារណៈអំពីអត្ថិភាពនៃដីកាចោទប្រកាន់ និងអំពាវនាវឱ្យជនជាប់ចោទចូលទៅបង្ហាញខ្លួននៅចំពោះមុខតុលាការ និងស្នើសុំឱ្យជនទាំងឡាយណា ដែលដឹងអំពីទីសំចតរបស់ជនជាប់ចោទ ជូនដំណឹងទៅតុលាការ។

33. អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានធ្វើសវនាការដើម្បីបញ្ជាក់ជាថ្មីអំពីដីកាចោទប្រកាន់ ក្នុងករណីដែលអង្គជំនុំជម្រះបានរកឃើញថា ការខកខានមិនបានប្រគល់ដោយផ្ទាល់ប្រកបដោយប្រសិទ្ធភាពនូវដីកាចោទប្រកាន់ គឺដោយសាររដ្ឋនោះបដិសេធមិនសហការជាមួយ

---

156 វិធាន ៦១ (គ-ង) នៃវិធាននីតិវិធី និងភស្តុតាងនៃតុលាការ ICTY។

157 វិធាន៦១(១)(ក) នៃវិធាននីតិវិធី និងភស្តុតាងនៃតុលាការ ICTY។

តុលាការ[158]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណា *ក្នុងចំណោមចំណុចផ្សេងៗ* អំពីភស្តុតាងដែលថា ជនជាប់ចោទបានស្ថិតនៅក្នុងដែនដីរបស់រដ្ឋនោះ ប៉ុន្តែពុំត្រូវបានចាប់ខ្លួន ទោះជាមានសំណើជាច្រើនលើកពីប្រធានតុលាការ ICTY ហើយដីកាចោទប្រកាន់ត្រូវបានចុះផ្សាយនៅលើទំព័រសារព័ត៌មាន ដោយមានការចែកចាយទូលំទូលាយក៏ដោយ[159]។

34. ក្រោមវិធាន២២ នៃលក្ខន្តិកៈតុលាការពិសេសសម្រាប់លីបង់ កិច្ចដំណើរការនីតិវិធី អាចត្រូវបានធ្វើទៅបាន ដោយអវត្តមានជនជាប់ចោទ ប្រសិនបើជនជាប់ចោទ៖

(ក) បានបញ្ជាក់ច្បាស់លាស់ និងបញ្ជាក់ជាលាយលក្ខណ៍អក្សរអំពីការលះបង់សិទ្ធិមានវត្តមានរបស់ខ្លួន

(ខ) ពុំត្រូវបានអាជ្ញាធររដ្ឋពាក់ព័ន្ធប្រគល់ទៅឱ្យតុលាការ

(គ) បានរត់គេចខ្លួន ឬរកមិនឃើញ ហើយវិធានការសមស្របទាំងអស់ត្រូវបានអនុវត្តដើម្បីធានាឱ្យការចូលមកបង្ហាញខ្លួនរបស់ជនជាប់ចោទនៅចំពោះមុខតុលាការ និងផ្តល់ព័ត៌មានទៅជនជាប់ចោទអំពីបទចោទប្រកាន់ដែលបញ្ជាក់ដោយចៅក្រមអង្គបុរេជំនុំជម្រះ[160]។

លក្ខន្តិកៈតុលាការពិសេសសម្រាប់លីបង់ចែងទៀតថានៅពេលធ្វើសវនាការពេលអវត្តមានជនជាប់ចោទ តុលាការត្រូវតែជឿជាក់ថា ជនជាប់ចោទ "ត្រូវបានប្រាប់ ឬប្រគល់ឱ្យនូវដីកាចោទប្រកាន់ ឬការជូនដំណឹងអំពីដីកាចោទប្រកាន់ត្រូវបានធ្វើតាមរយៈការផ្សព្វផ្សាយតាមបណ្តាញផ្សព្វផ្សាយ

---

[158] *រដ្ឋអាជ្ញា ទល់នឹង* ***Karadžić*** និង ***Mladić*** លេខសំណុំរឿង IT-95-5-R61 និង IT-95-18-R61, ការពិនិត្យឡើងវិញអំពីដីកាចោទប្រកាន់អនុលោមតាមវិធាន ៦១ នៃវិធាននីតិវិធី និងភស្តុតាង, ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ១៩៩៦ កថាខណ្ឌ ១០១។ *រដ្ឋអាជ្ញា ទល់នឹង Rajić*, IT-95-12-R61, ការពិនិត្យឡើងវិញអំពីដីកាចោទប្រកាន់អនុលោមតាមវិធាន ៦១ នៃវិធាននីតិវិធី និងភស្តុតាង, ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ១៩៩៦ កថាខណ្ឌ ៧០។

[159] សំណុំរឿង *រដ្ឋអាជ្ញា ទល់នឹង* ***Karadžić*** និង ***Mladić***, IT-95-5-R61 និង IT-95-18-R61, ការពិនិត្យឡើងវិញអំពីដីកាចោទប្រកាន់អនុលោមតាមវិធាន ៦១ នៃវិធាននីតិវិធី និងភស្តុតាង, ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ១៩៩៦, កថាខណ្ឌ ៩៨-៩៩។ *រដ្ឋអាជ្ញា ទល់នឹង Rajic*, IT-95-12-R61, ការពិនិត្យឡើងវិញអំពីដីកាចោទប្រកាន់អនុលោមតាមវិធាន ៦១ នៃវិធាននីតិវិធី និងភស្តុតាង, ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ១៩៩៦,កថាខណ្ឌ ៦៣ និងកថាខណ្ឌ ៦៥-៦៦។

[160] មាត្រា ២២(១) នៃលក្ខន្តិកៈតុលាការពិសេសសម្រាប់លីបង់។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C C.E.T.C

ឬការប្រាស្រ័យទាក់ទងទៅកាន់រដ្ឋដែលជនជាប់ចោទរស់នៅ ឬរដ្ឋដែលជាសញ្ជាតិរបស់ជនជាប់ចោទ"[161]។ វិធាន ៧៦ និង៧៦*ស្ទួន* នៃវិធានផ្ទៃក្នុងអនុញ្ញាតឱ្យការប្រគល់ដីកាចោទប្រកាន់ មានប្រសិទ្ធភាព តាមរយៈការផ្សព្វផ្សាយជាសាធារណៈ[162] ជំនួសឱ្យការប្រគល់ដោយផ្ទាល់ដៃ នៅពេលដែល "ការប៉ុនប៉ងសមស្របត្រូវបានធ្វើដើម្បីប្រគល់ដីកាចោទប្រកាន់"ដោយផ្ទាល់ដៃ[163]។ តុលាការនេះបានបញ្ជាក់លម្អិតនៅក្នុងសំណុំរឿង *រដ្ឋអាជ្ញា ទល់នឹង Ayyash និងអ្នកផ្សេងទៀត*[164] ថា ដើម្បីធ្វើការប្រគល់ដីកាចោទប្រកាន់ តាមរយៈការផ្សព្វផ្សាយជាសាធារណៈ ត្រូវតែមានភស្តុតាងថា ការផ្សព្វផ្សាយនោះអាចដឹងដល់ជនជាប់ចោទ[165]។ សំខាន់សម្រាប់សំណុំរឿងនាពេលបច្ចុប្បន្ននេះ វិធានការនីតិវិធីដូចដែលតម្រូវដោយមាត្រា ២២ ខាងលើ ពុំមានភាពចាំបាច់ឡើយ នៅពេលដែលជនជាប់ចោទបានតែងតាំងមេធាវីតំណាង[166]។

35. ក្នុងវាយតម្លៃថាតើវិធានការសមស្របទាំងអស់ ត្រូវបានអនុវត្តដើម្បីធានាបានការចូលមកបង្ហាញខ្លួនរបស់ជនជាប់ចោទនៅចំពោះមុខតុលាការ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ STL បានសម្រេចថា "និយមន័យនៃ "វិធានការសមស្របទាំងអស់" ពុំអាចមានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ។ វិធានការនេះត្រូវតែកំណត់ទៅតាមកាលៈទេសៈជាក់ស្តែង ដែលមានន័យថា បញ្ហានេះមិនអាចត្រូវបានកំណត់ដោយផ្អែកលើទ្រឹស្តីឡើយ ប៉ុន្តែកំណត់តាមរយៈការ

---

161 មាត្រា២២(២)(ក)នៃលក្ខន្តិកៈតុលាការពិសេសសម្រាប់លីបង់។

162 វិធាន៧៦*ស្ទួន*នៃវិធាននីតិវិធី និងភស្តុតាងតុលាការពិសេសសម្រាប់លីបង់។

163 វិធាន៧៦(ង) នៃវិធាននីតិវិធី និងភស្តុតាងតុលាការពិសេសសម្រាប់លីបង់។

164 STL-11-01/I/TC, សេចក្តីសម្រេចធ្វើសវនាការ*ដោយកំបាំងមុខ*, អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ ២០១២។

165 នៅក្នុងសំណុំរឿងនេះ តុលាការបានសន្និដ្ឋានត្រង់កថាខណ្ឌ ១០៥ ថា "ភស្តុតាងទាំងអស់ដែលអង្គជំនុំជម្រះសាលាដំបូងមានបង្ហាញថាជនជាប់ចោទទាំងបួនរូបពុំទាន់បានចាកចេញពីលីបង់នៅឡើយទេ" ដោយហេតុថាគ្មានចុងចោទណាម្នាក់ "ត្រូវបានឃើញនៅកន្លែង រស់នៅចុងក្រោយបំផុតដែលគេស្គាល់ យ៉ាងហោចណាស់ចាប់តាំងពីខែ មិថុនា ឆ្នាំ ២០១១ នៅពេលដែលឈ្មោះរបស់ពួកគាត់ ត្រូវបានចុះផ្សាយទាក់ទងនឹងដីកាចោទប្រកាន់"។ យ៉ាងណាមិញ តុលាការក៏បានសម្រេចថា "ប្រព័ន្ធផ្សព្វផ្សាយលីបង់បានធ្វើការផ្សព្វផ្សាយយ៉ាងទូលំទូលាយ អំពីដីកាចោទប្រកាន់ និងទំនាក់ទំនង (ជនសង្ស័យ) ជាមួយដីកាចោទប្រកាន់" ដែលជនជាប់ចោទ អាចត្រូវគេគិតថាបានដឹងអំពីកិច្ចដំណើរការនីតិវិធី។

166 វិធាន ១០៤ នៃវិធាននីតិវិធី និងភស្តុតាងនៃតុលាការពិសេសសម្រាប់លីបង់។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C • C.E.T.C

ពិនិត្យអំពីកាលៈទេសៈទូទៅទាំងស្រុង[167]”។ នៅក្នុងសំណុំរឿង *រដ្ឋអាជ្ញា ទល់នឹង Ayyash et al.,* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ STL បានគូសបញ្ជាក់ថាយោងតាមព័ត៌មានទទួលបាន អាជ្ញាធរមូលដ្ឋានបានកំពុងសហការ និងកំពុងប៉ុនប៉ងស្វែងរកជនជាប់ចោទ។ អាជ្ញាធរលីបង់ បានដាក់របាយការណ៍ស្តីពីការវិវត្តន៍បោះជំហាន ក្នុងការស្វែងរកជនជាប់ចោទនៅក្នុងចន្លោះពេល ជាច្រើន។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា វិធានការសមស្របទាំងអស់ ត្រូវបានអនុវត្ត ដើម្បីប្រគល់ដីកាចោទប្រកាន់ទៅជនជាប់ចោទ នៅពេលដែលវិធានការទាំងនេះរួមមាន៖ i) ការ ប៉ុនប៉ងផ្ទួនៗ (ចំនួនចន្លោះពី ៣២ ដល់ ៤៦ ដងសម្រាប់ជនជាប់ចោទម្នាក់ៗ) ក្នុងការប្រគល់ដីកា ចោទប្រកាន់នៅ ឯអាសយដ្ឋានចុងក្រោយដែលគេស្គាល់របស់ជនជាប់ចោទម្នាក់ៗ, អាសយដ្ឋាន កន្លែងការងាររបស់ ពួកគាត់ និងអាសយដ្ឋានសមាជិកគ្រួសារជិតស្និទ្ធ ii) ការប៉ុនប៉ងប្រគល់ដីកា ចោទប្រកាន់ តាមរយៈអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ, iii) បិតដីកាចោទប្រកាន់នៅកន្លែងរស់នៅចុង ក្រោយដែលគេស្គាល់ សម្រាប់ជនជាប់ចោទម្នាក់ៗ iv) ការបោះពុម្ពផ្សាយ “រូបជនដែលតុលាការ ត្រូវការ” នៅលើបណ្តាញផ្សព្វផ្សាយលីបង់ដែលត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ v) ការ បោះពុម្ពផ្សាយ “លិខិតចំហ” មួយទៅជនជាប់ចោទពីសំណាក់ប្រធានតុលាការ STL និង vi) ការប្រគល់តាមមធ្យោបាយស្រដៀងគ្នានូវសេចក្តីសម្រេចរបស់ប្រធានផ្នែកការពារក្តីអំពីការតែង តាំងមេធាវី[168]។ អង្គជំនុំជម្រះសាលាដំបូងបាន ធ្វើសេចក្តីសន្និដ្ឋានមួយស្រដៀងនេះនៅក្នុង សំណុំរឿង *រដ្ឋអាជ្ញា ទល់នឹង Merhi* ដែលវិធានការស្រដៀងគ្នាត្រូវបានអនុវត្ត[169]។

36. យោងតាមការលើកឡើងខាងលើ ចៅក្រមដែលបានចុះហត្ថលេខាយល់ឃើញថាវិធាននីតិវិធីចែង ក្នុងកម្រិតអន្តរជាតិ អនុញ្ញាតឱ្យអនុវត្តវិធានការពិសេសដើម្បីបន្តកិច្ចដំណើរការនីតិវិធីនៅក្នុង ដំណាក់កាលមុនការជំនុំជម្រះនៅពេលដែល៖ i) ជនណាម្នាក់បានលះបង់យ៉ាងច្បាស់លាស់

---

[167] *រដ្ឋអាជ្ញា ទល់នឹង Ayyash* និងអ្នកផ្សេងទៀត STL-11-01/I/TC សេចក្តីសម្រេចធ្វើសវនាការ *ដោយកំបាំងមុខ,* អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ២៨។

[168] *រដ្ឋអាជ្ញា ទល់នឹង Ayyash et al,* STL-11-01/I/TC, សេចក្តីសម្រេចធ្វើសវនាការ *ដោយកំបាំងមុខ,* អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ ២០១២។

[169] *រដ្ឋអាជ្ញា ទល់នឹង Merhi,* STL-13-04/I/TC, សេចក្តីសម្រេចធ្វើសវនាការ *ដោយកំបាំងមុខ,* អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១៣។

និងជាលាយលក្ខណ៍អក្សរនូវសិទ្ធិមានវត្តមានរបស់ខ្លួន ឬ ii) នៅពេលវិធានការសមស្របទាំងអស់ត្រូវបានអនុវត្តដើម្បីធានាឱ្យមានការចូលបង្ហាញខ្លួននៅចំពោះមុខតុលាការមានសមត្ថកិច្ច និងដើម្បីប្រាប់ជននោះអំពីបទចោទប្រកាន់ ប៉ុន្តែវិធានការទាំងនោះបរាជ័យដូចដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានលើកឡើង[170]។

37. ទាក់ទងការលះបង់សិទ្ធិមានវត្តមាន ចៅក្រមដែលបានចុះហត្ថលេខាកត់សម្គាល់ឃើញថា វិធានចែងក្នុងកម្រិត អន្តរជាតិតម្រូវឱ្យជនជាប់ចោទត្រូវបានប្រាប់អំពីកិច្ចដំណើរការនីតិវិធី និងលះបង់សិទ្ធិដោយច្បាស់លាស់ និងជាលាយលក្ខណ៍អក្សរ។ តាមវិធានតុលាការអន្តរជាតិនានា ការលះបង់សិទ្ធិដោយមិនច្បាស់លាស់ពុំគ្រប់គ្រាន់ដើម្បីតុលាការសម្រេចបន្តនីតិវិធីដោយអវត្តមានជនជាប់ចោទឡើយ។ តុលាការ នៅតែត្រូវការអនុវត្តវិធានការសមស្របទាំងអស់ដើម្បីធានាបានវត្តមានរបស់ជនជាប់ចោទ។ មានការបែងចែករវាងលក្ខខណ្ឌនានាដែលវិធានការពិសេស អាចត្រូវបានអនុវត្តក្រោមវិធាននៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិនានា ក្រោយពេលមានការខកខានអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួន ហើយលក្ខខណ្ឌនានាដែលត្រូវបំពេញដើម្បីធានាបានថា សិទ្ធិមានវត្តមាននៅសវនាការ ដែលស្ថិតក្រោមច្បាប់សិទ្ធិមនុស្ស ត្រូវបានគោរព។ លក្ខខណ្ឌខាងដើមតឹងតែងជាងលក្ខខណ្ឌខាងចុង។ ទោះជាដូច្នេះ នៅពេលគ្មានការលះបង់សិទ្ធិច្បាស់លាស់ យុត្តិសាស្ត្រស្ថាប័នសិទ្ធិមនុស្សនៅតែមានប្រយោជន៍ដល់ការសម្រេចថាតើតុលាការបានចាត់វិធានការសមស្របទាំងអស់ដើម្បីប្រាប់ជនជាប់ចោទអំពីកិច្ចដំណើរការនីតិវិធីដែរឬយ៉ាងណា ដែលយើងនឹងពិភាក្សាជាលម្អិតខាងក្រោមនេះ។

38. ទាក់ទងនឹងវិធានការគ្រប់គ្រាន់ដែលបានអនុវត្តដើម្បីធានាឱ្យមានការនាំខ្លួនជនជាប់ចោទ និងជូនដំណឹងគាត់អំពីបទចោទប្រកាន់នោះ ចៅក្រមដែលបានចុះហត្ថលេខាកត់សម្គាល់ថា លក្ខខណ្ឌតម្រូវដែលត្រូវបន្តអនុវត្ត ក្នុងករណីមិនមានវត្តមានរបស់ជនជាប់ចោទ គឺមិនមែនត្រង់ថា អាជ្ញាធរជាតិបានចាត់វិធានការសមហេតុទាំងអស់រួចហើយនោះទេ ប៉ុន្តែ គឺថា សាលាក្តីខ្លួនឯងបានចាត់វិធានការសមហេតុផលទាំងអស់រួចហើយ។ នៅក្នុងបរិបទសាលាក្តីអន្តរជាតិនានា គេទទួលស្គាល់ថា ការលំបាកក្នុងការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួនអាចកើតឡើងដោយសារកង្វះកិច្ចសហការពីរដ្ឋដែលសាមីខ្លួននោះស្នាក់នៅ ឬក៏គេដឹងចុងក្រោយបំផុតថា សាមីខ្លួននោះបានស្ថិតនៅលើដែនដីរ

[170] ដីកាសម្រេចដែលត្រូវបានជំទាស់, កថាខណ្ឌ ៥៧(ឃ)។ *សូមមើលផងដែរ* កថាខណ្ឌ ៥០-៥១។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C • C.E.T.C

បស់រដ្ឋនោះ ឬក៏នៅក្រោមយុត្តាធិការ និងការគ្រប់គ្រងរបស់រដ្ឋនោះ។ វិធានការសមហេតុផលនៅក្នុងកាលៈទេសៈទាំងនេះ រួមមានការព្យាយាមធានាឱ្យមានកិច្ចសហការពីរដ្ឋពាក់ព័ន្ធនោះ ដែលប្រហែលជាមិនអាចទទួលបានកិច្ចសហការជាក់ស្តែងទេ។ ជាពិសេស សាលាក្តីមិនត្រូវបានតម្រូវឱ្យរង់ចាំរបាយការណ៍ផ្លូវការពីអាជ្ញាធរអនុវត្តច្បាប់ថ្នាក់ជាតិដើម្បីបន្តកិច្ចដំណើរការនីតិវិធី។ ប៉ុន្តែ ករណីដែលគ្មានរបាយការណ៍ពីរដ្ឋអំណាចបន្ទាប់ពីមានរយៈពេលមួយសមហេតុផលនោះត្រូវបានចាត់ទុកថាជាការខកខានមិនអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន[171]។

39. មិនមានលក្ខខណ្ឌតម្រូវច្បាស់លាស់តាមច្បាប់អន្តរជាតិ ដើម្បីកំណត់ថាតើវិធានាការសមហេតុផលត្រូវបានអនុវត្តរួចហើយឬនៅ ដើម្បីធានាឱ្យមានវត្តមានរបស់ជនជាប់ចោទ និងថាតើករណីនីមួយៗនឹងត្រូវត្រួតពិនិត្យឬអត់ ដោយពិចារណាលើកាលៈទេសៈទាំងអស់។ ត្រង់ចំណុចនេះ ចៅក្រមដែលបានចុះហត្ថលេខាកត់សម្គាល់ថា ការផ្សព្វផ្សាយអំពីដីកាបញ្ជូនរឿងទៅជំនុំជម្រះនៅក្នុងប្រព័ន្ធផ្សព្វផ្សាយអាចអនុវត្តតែក្នុងករណីដែលគេមិនដឹងពីទីកន្លែងលាក់ខ្លួនរបស់ជនជាប់ចោទ ឬក៏ជនជាប់ចោទកំពុងគេចខ្លួនតែប៉ុណ្ណោះ[172]។ ឧទាហរណ៍ ការផ្សព្វផ្សាយបែបនេះមិនតម្រូវឱ្យមានទេប្រសិនបើជនជាប់ចោទមានតំណាងមេធាវីដែលគាត់បានតែងតាំង[173]។ លើសពីនេះទៀត តុលាការអាចពិចារណាថា "អង្គហេតុគ្រឹះមួយចំនួនអាចផ្តល់ជាសញ្ញាយ៉ាងច្បាស់លាស់ថាជនជាប់ចោទដឹងពីអត្ថិភាពនៃកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌប្រឆាំងគាត់ ព្រមទាំងលក្ខណៈ និងដើមហេតុនៃការចោទប្រកាន់ ហើយគាត់មិនមានចេតនាចូលរួមសវនាការ ឬក៏មានបំណងគេចវេះពីការចោទប្រកាន់"[174] ទោះបីជាគាត់មិនទាន់ទទួលបានដំណឹងជាផ្លូវការអំពីបទចោទប្រកាន់ប្រឆាំងគាត់ក៏ដោយ។ ដូចដែលបានសម្រេចដោយតុលាការសិទ្ធិមនុស្សអឺរ៉ុបនៅក្នុងរឿងក្តី *Sejovic តទល់នឹងអ៊ីតាលី* "ឧទាហរណ៍ នេះអាចជាករណីដែលជនជាប់ចោទ ប្រកាសជាសាធារណៈ ឬជាលាយលក្ខណ៍អក្សរថា គាត់មិនមានចេតនាឆ្លើយតបតាមដីកាកោះដែលគាត់បានដឹងឮ

---

[171] *សូមមើលវិ*ធាន ៥៩ នៃវិធានស្តីពីនីតិវិធី និងភ័ស្តុតាងរបស់តុលាការ SCSL ចំណងជើង "ការខកខានមិនអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន ឬដីកាបង្គាប់ឱ្យបញ្ជូនខ្លួន"។

[172] *សូមមើល ឧទាហរណ៍* វិធាន ៦១(១)(ក)នៃវិធានស្តីពីនីតិវិធី និងភ័ស្តុតាងរបស់តុលាការ ICTY និង ICTR។

[173] *សូមមើល ឧទាហរណ៍* វិធាន ១០៤ នៃវិធានស្តីពីនីតិវិធី និងភ័ស្តុតាងរបស់តុលាការ STL។

[174] រឿងក្តី *Sejdovic តទល់នឹងអ៊ីតាលី* ពាក្យសុំលេខ 56581/00 សាលដីកា សភាពេញអង្គ ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០០៦ កថាខណ្ឌ ៩៩ (លុបការលើកយោង)។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

តាមរយៈប្រភពនានា ក្រៅពីអាជ្ញាធរ ឬក៏បានគេចខ្លួនដោយជោគជ័យពីការព្យាយាមនាំខ្លួនគាត់ ឬក៏ក្នុងករណីដែលអាជ្ញាធរបានដឹងអំពីឯកសារនានាដែលបង្ហាញយ៉ាងច្បាស់ថា គាត់បានដឹងឮពីកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងគាត់ និងបទចោទប្រកាន់ដែលគាត់ប្រឈមមុខ"[175]។

40. ចៅក្រមដែលបានចុះហត្ថលេខាយល់ឃើញថា វិធាននីតិវិធីដែលបានបង្កើតនៅកម្រិតអន្តរជាតិផ្តល់ការណែនាំដ៏មានប្រយោជន៍ដើម្បីដោះស្រាយករណីបច្ចុប្បន្ននេះ ត្រង់ចំណុចដែលវិធានទាំងនេះកំណត់ពីលក្ខខណ្ឌ ដែលត្រូវបន្តកិច្ចដំណើរការនីតិវិធីដោយមិនមានរៀបចំសវនាការបង្ហាញខ្លួនលើកដំបូង។ ដោយពិនិត្យឃើញថា គោលការណ៍ទាំងនេះមិនផ្ទុយពីច្បាប់កម្ពុជា ប៉ុន្តែបែរជាបំពេញបន្ថែមលើច្បាប់កម្ពុជាដើម្បីដោះស្រាយកិច្ចដំណើរការនីតិវិធីជាពិសេសនេះនៅចំពោះមុខ អ.វ.ត.ក ដូច្នេះ ទឡ្ហីករណ៍របស់សហមេធាវីដែលថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបំពេញកិច្ច*ហួសពីដែនអំណាច* ក្នុង "ការបង្កើតនីតិវិធីថ្មី គឺការដាក់ឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ*"[176] គឺជាទឡ្ហីករណ៍គ្មានអង្គសេចក្តី។ ដូចគ្នានេះដែរ ចៅក្រមដែលបានចុះហត្ថលេខាយល់ឃើញថា ខុសពីការអះអាងរបស់សហមេធាវី[177] សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនចាំបាច់ត្រូវបញ្ជូនបញ្ហានេះទៅអង្គជំនុំជម្រះនៃកិច្ចប្រជុំពេញអង្គ ដើម្បីស្នើសុំវិសោធនកម្មវិធានផ្ទៃក្នុងទេ គឺគាត់ត្រូវតែសម្រេចលើបញ្ហានេះនៅចំពោះមុខគាត់សិន បន្ទាប់មកសម្រាប់គោលបំណងនាពេលអនាគត គាត់អាចស្នើសុំវិសោធនកម្មវិធានផ្ទៃក្នុង ដូចមានចែងយ៉ាងច្បាស់នៅក្នុងវិធាន ២ នៃវិធានផ្ទៃក្នុង។

## ឃ. កំហុសដែលបានចោទប្រកាន់នៅក្នុងការអនុវត្តច្បាប់ទៅលើករណីបច្ចុប្បន្ន

---

[175] តុលាការ ECtHR រឿងក្តី *Sejdovic តទល់នឹងអ៊ីតាលី* ពាក្យសុំលេខ 56581/00 សាលដីកា សភាពេញអង្គ ថ្ងៃទី០១ ខែ មីនា ឆ្នាំ ២០០៦ កថាខណ្ឌ ៩៩(លុបការលើកយោង)។ *សូមមើលផងដែរ* កថាខណ្ឌ ៩៨ ដែលក្នុងនេះ តុលាការ ECtHR បែងចែករឿងក្តីរបស់ Sejdovic ខុសពីរឿងក្តីរបស់ Medenica "ដែលត្រូវបានជូនដំណឹងក្នុងរយៈពេលមួយដ៏សមរម្យ អំពីកិច្ចដំណើរការនីតិវិធីប្រឆាំងគាត់ និងពេលវេលានៃសវនាការ" ហើយគាត់ " ក៏មានជំនួយ និងបានទាក់ទងជាមួយនឹងមេធាវីតាមការជ្រើសរើសរបស់គាត់"។

[176]បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៦៩។

[177]បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៦៩-៧២។

41. ចៅក្រមដែលបានចុះហត្ថលេខាកត់សម្គាល់ថា សហមេធាវី មិនជំទាស់ទៅនឹងអង្គហេតុដែលថា អ៊ឹម ចែម ត្រូវបានកោះហៅយ៉ាងត្រឹមត្រូវឱ្យមកបង្ហាញខ្លួនលើកដំបូងដែលគ្រោងធ្វើឡើងនៅថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៤ ហើយថា គាត់ខកខានមិនបានបង្ហាញខ្លួន។ សហមេធាវី មិនបានបង្ហាញពីមូលហេតុសមស្របដែលគាត់មិនបានបង្ហាញខ្លួនទេ។ សហមេធាវី មិនជំទាស់ទៅនឹងសេចក្ដីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលថា អ៊ឹម ចែម មិនមានចេតនាមកបង្ហាញខ្លួននៅចំពោះមុខ អ.វ.ត.ក នៅកាលបរិច្ឆេទណាមួយទេ។ ត្រង់ចំណុចនេះ សហមេធាវី ជំទាស់ទៅនឹងអង្គហេតុដែលថា សហចៅក្រមស៊ើបអង្កេត មិនបានស្វែងរកលទ្ធភាពដែលអាចដាក់គាត់ឱ្យស្ថិតក្រោមការពិនិត្យនៅក្នុងខេត្តដែលគាត់ស្នាក់នៅ។ ទោះយ៉ាងណា សហមេធាវី មិនបានបង្ហាញពីសញ្ញាណាដែលថា អ៊ឹម ចែម មានចេតនាចូលរួមក្នុងការបង្ហាញខ្លួនលើកដំបូងដែលរៀបចំធ្វើឡើង ក្នុងកាលៈទេសៈពិសេសបែបនោះទេដែលខុសពី អោ អាន[178]។ លើសពីនេះទៀត សហមេធាវី មិនបានអះអាងថា មិនមានវិធានការគ្រប់គ្រាន់ដើម្បីអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួនទេ បើមិនអញ្ចឹងទេ ត្រូវបង្ហាញថា ត្រូវមានកិច្ចខិតខំប្រឹងប្រែងថែមទៀតចំពោះបញ្ហានេះ។ តាមពិត សហមេធាវីទាមទារសិទ្ធិឱ្យអ៊ឹម ចែម បង្ហាញខ្លួនដោយផ្ទាល់នៅក្នុងការបង្ហាញខ្លួនលើកដំបូងខណៈដែលខ្លួនគាត់ផ្ទាល់ រារាំងមិនឱ្យមានការបង្ហាញខ្លួនលើកដំបូងកើតឡើងទេ។ ដីកាបង្គាប់ឱ្យនាំខ្លួននៅតែមិនទាន់អនុវត្ត អស់រយៈពេលជាងមួយឆ្នាំហើយ ទោះបីជា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានព្យាយាមជាច្រើនដងដើម្បីឱ្យមានកិច្ចសហការពីនគរបាលយុត្តិធម៌ ទាំងដោយផ្ទាល់ទាំងតាមរយៈប្រធានគណៈកម្មការសន្តិសុខប្រចាំ អ.វ.ត.ក ក៏ដោយ[179]។ ដោយពិនិត្យមើលកាលៈទេសៈទាំងនេះ ចៅក្រមដែលបានចុះហត្ថលេខាយល់ឃើញថា សហចៅក្រមស៊ើបអង្កេត មិនមានកំហុសទេនៅក្នុងសេចក្ដីសន្និដ្ឋានដែលថា វិធានការសមហេតុផលទាំងអស់បានអនុវត្តរួចហើយដើម្បីធានាឱ្យមានវត្តមានរបស់ អ៊ឹម ចែម នៅក្នុងការបង្ហាញខ្លួនលើកដំបូង។ ឥឡូវនេះ ចៅក្រមដែលបានចុះហត្ថលេខានឹងត្រឡប់ទៅពិនិត្យមើលថាតើ សហចៅក្រមស៊ើបអង្កេត មាន

[178] *សូមមើល* កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ អោ អាន ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ D242 ដែលក្នុងនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានកត់សម្គាល់ថា "ដោយសន្មតថា អោ អាន បានសម្រេចគោរពតាមដីកាកោះឱ្យគាត់បង្ហាញខ្លួនលើកដំបូងនោះ សហមេធាវីរបស់ អោ អាន បានធ្វើការស្នើទៅ ស.ច.ស.អ ដោយស្នើថា ការបង្ហាញខ្លួនលើកដំបូងគួរធ្វើឡើងនៅក្រុងបាត់ដំបង" ហើយបន្ទាប់មកមានការជូនដំណឹងពីសហមេធាវីថា ពួកគាត់នឹងចូលរួមការបង្ហាញខ្លួនលើកដំបូងដែលគ្រោងធ្វើឡើងនៅបាត់ដំបង។

[179] *សូមមើល* ដីកាសម្រេចរងការជំទាស់ កថាខណ្ឌ ២១-៣០។

កំហុស ឬអត់នៅក្នុងសេចក្តីសម្រេចជូនដំណឹងអំពីបទចោទប្រកាន់ តាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរប្រគល់ជូនទៅសហមេធាវីរបស់ អ៊ឹម ចែម។

42. ដោយប្រឈមមុខនឹងបញ្ហាដែល អ៊ឹម ចែម ខកខានមិនបានបង្ហាញនៅចំពោះ អ.វ.ត.ក សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អាចដាក់បទចោទប្រកាន់នៅក្នុងដីកាបង្គាប់ឱ្យនាំខ្លួន និងបន្តកិច្ចស៊ើបសួររហូតដល់បិទកិច្ចស៊ើបសួរ ដោយគ្មានការចូលរួមរបស់ អ៊ឹម ចែម ដូចមានចែងនៅក្នុងច្បាប់កម្ពុជា។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានសម្រេចមិនធ្វើដូច្នេះទេ ហើយបានសម្រេចជូនដំណឹង អ៊ឹម ចែម ជាផ្លូវការអំពីបទចោទប្រកាន់ ដើម្បីឱ្យគាត់ទទួលបានសិទ្ធិចូលរួមកិច្ចស៊ើបសួរ និងឱ្យសហមេធាវីរបស់គាត់ អាចចូលពិនិត្យមើលសំណុំរឿង។ ទោះបីជានីតិវិធីនេះមិនធម្មតាក៏ដោយ ក៏នីតិវិធីនេះឆ្លើយតបតាមស្ថានភាពអង្គហេតុមួយដែលស្មើនឹងស្ថានភាពមិនធម្មតា។ ត្រង់ចំណុចនេះ មានការកត់សម្គាល់ថា អ៊ឹម ចែម បានតែងតាំងសហមេធាវីពីររូបដើម្បីតំណាងគាត់ចាប់តាំងពីថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៤[180]។ សហមេធាវីបានស្នើសុំចូលពិនិត្យមើលសំណុំរឿងចាប់តាំងពីថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៤[181]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិធ្លាប់បានសម្រេចថា សិទ្ធិទាំងនេះអាចទទួលបានតែ “ជនត្រូវចោទ” តែប៉ុណ្ណោះ គឺជនដែលត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យដោយផ្លូវការ[182]។ ដោយឈានដល់ចំណុចមួយនៅក្នុងកិច្ចស៊ើបសួរដែលគាត់យល់ឃើញថា មានភស្តុតាងគ្រប់គ្រាន់ដើម្បីដាក់ អ៊ឹម ចែម ឱ្យស្ថិតក្រោមការពិនិត្យហើយនោះ ទើបសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបន្តផ្តល់ឋានៈឱ្យ អ៊ឹម ចែម ជា “ជនត្រូវចោទ” និងផ្តល់សិទ្ធិដែលមានជាប់ជាមួយនឹងឋានៈនេះ។ ចៅក្រមដែលបានចុះហត្ថលេខាយល់ឃើញថា គោលបំណងនេះគឺស្របតាមស្មារតីនៃវិធានផ្ទៃក្នុង ដែលចែងថា ជនដែលត្រូវកាត់សេចក្តីនៅចំពោះមុខ អ.វ.ត.ក ត្រូវចូលរួមកិច្ចស៊ើបសួរ ហើយក៏ស្របតាមគោលការណ៍ជាសារវ័ន្តនៃវិធានផ្ទៃក្នុង ដែលតម្រូវថា វិធានផ្ទៃក្នុង “ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់

---

[180] *សូមមើល* ទម្រង់ ៧៖ សំណើសុំចាត់តាំងសហមេធាវី ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ D122/13.1។

[181] សំណើរបស់អ្នកស្រី អ៊ឹម ចែម សុំដីកាសម្រេចអនុញ្ញាតឱ្យចូលពិនិត្យមើលសំណុំរឿង ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ D201។

[182] *សូមមើល ឧទាហរណ៍* សំណុំរឿង ០០៤(អបជ ០៥) សេចក្តីសម្រេចលើសំណើរបស់ក្រុមការពារក្តីតា អាន សុំចូល ពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេត ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារ D121/4។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C • C.E.T.C

ជនសង្ស័យ និងជនត្រូវចោទ"[183]។ លើសពីនេះទៀត ការអនុញ្ញាតឱ្យ អ៊ឹម ចែម ចូលរួមកិច្ចស៊ើបសួរ គឺជួយបង្ហាញការពិត។ អនុលោមតាមវិធាន ៥៥(៥) នៃវិធានផ្ទៃក្នុង "សហចៅក្រមស៊ើបអង្កេតអាចចាត់វិធានការស៊ើបសួរដែលនាំទៅរកការបង្ហាញការពិត" ហើយដើម្បីសម្រេចគោលដៅនេះ "តាមការចាំបាច់ អាចចេញដីកានានាដើម្បីបំពេញកិច្ចស៊ើបសួរ"។ ហេតុដូច្នេះ ចៅក្រមដែលបានចុះហត្ថលេខាយល់ឃើញថា នៅក្នុងកាលៈទេសៈពិសេសនៃករណីបច្ចុប្បន្ននេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានអំណាច និងមានយុត្តិកម្មស្វែងរកជម្រើសវិធីផ្សេងដើម្បីជូនដំណឹងដល់ អ៊ឹម ចែម អំពីបទចោទប្រកាន់ប្រឆាំងគាត់ ដូច្នេះបន្ទាប់មក អ៊ឹម ចែម អាចត្រូវបានចាត់ទុកថាជាជនត្រូវចោទ ហើយទទួលបានសិទ្ធិដែលមានជាប់ជាមួយនឹងឋានៈជាជនត្រូវចោទ។

43. ចំពោះវិធីដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានជ្រើសរើសដើម្បីជូនដំណឹងដល់ អ៊ឹម ចែម អំពីបទចោទប្រកាន់ប្រឆាំងគាត់ ចៅក្រមដែលបានចុះហត្ថលេខាកត់សម្គាល់ថា អនុលោមតាមវិធាន ៤៦ នៃវិធានផ្ទៃក្នុង "រាល់ដីកាទាំងអស់របស់សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះត្រូវជូនដំណឹងដល់ភាគី ឬមេធាវីរបស់ភាគី"។ ទោះយ៉ាងណា ការជូនដំណឹងអំពីបទចោទប្រកាន់ត្រូវផ្តល់ជូនផ្ទាល់ទៅសាមីខ្លួន[184] ពីព្រោះថា ជាធម្មតា នេះគឺជាពេលវេលាដំបូងដែលគាត់បានដឹងឮអំពីកិច្ចដំណើរការនីតិវិធីនេះ។ អាចជំទាស់បានថា គួរតែអាចព្យាយាមប្រគល់ឱ្យ អ៊ឹម ចែម ដោយផ្ទាល់នូវឯកសារដែលមានចំណងជើងថា "ការជូនដំណឹងអំពីបទចោទប្រកាន់"។ ប៉ុន្តែ ចៅក្រមដែលបានចុះហត្ថលេខាយល់ឃើញថា ការជូនដំណឹងទៅសហមេធាវី គឺជាមានភាពសមស្រប និងត្រឹមត្រូវនៅក្នុងកាលៈទេសៈពិសេសនៃករណីបច្ចុប្បន្ននេះ។ ត្រង់ចំណុចនេះ ចៅក្រមដែលបានចុះហត្ថលេខាកត់សម្គាល់ថា អ៊ឹម ចែម ធ្លាប់បានបដិសេធមិនព្រមទទួលស្គាល់ការប្រគល់ដីកាកោះ[185] ហើយជាទូទៅបដិសេធមិនព្រមទាក់ទងជាមួយនឹងតុលាការទេ ដោយបញ្ជាក់ថា

---

[183]វិធាន ២១(១) នៃវិធានផ្ទៃក្នុង។

[184]*វិធាន ៥៧ នៃវិធានផ្ទៃក្នុង។ សូមមើល ឧទាហរណ៍* វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICTY វិធាន ៥៣*ស្ទួន*។ វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICTR វិធាន ៥៣*ស្ទួន*។ វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ SCSL វិធាន ៥២ និងវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ STL វិធាន ៧៦(ខ)។

[185]កំណត់ហេតុនៃការប្រគល់ដីកាកោះ ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ A150/1។

គាត់មិនមានចេតនាបង្ហាញខ្លួននៅចំពោះមុខ អ.វ.ត.ក ទេ[186]។ ប៉ុន្តែ អ៊ឹម ចែម បានប្រាស្រ័យទាក់ទងជាមួយនឹងតុលាការ តាមរយៈសហមេធាវីរបស់គាត់ រាប់បញ្ចូលទាំងការពិភាក្សាអំពីការចូលរួមរបស់គាត់នៅក្នុងការបង្ហាញខ្លួនលើកដំបូងផងដែរ[187]។ សហមេធាវីក៏ធ្លាប់បានស្នើសុំឱ្យផ្តល់ជូននូវសំណៅមួយច្បាប់នៃឯកសារនានាដែលបានប្រគល់ទៅ អ៊ឹម ចែម[188]។ បន្ថែមពីលើនេះទៀត អ៊ឹម ចែម បច្ចុប្បន្ននេះគឺជាកម្មវត្ថុនៃដីកាបង្គាប់ឱ្យនាំខ្លួន ប៉ុន្តែគាត់បដិសេធមិនព្រមចូលខ្លួនក្នុងតុលាការ។ នៅក្នុងកាលៈទេសៈទាំងនេះ ការប្រគល់ឱ្យ អ៊ឹម ចែម ដោយផ្ទាល់នូវការជូនដំណឹងអំពីបទចោទប្រកាន់ អាចបង្កើតឱ្យមានភាពតានតឹងថែមទៀតនៅក្នុងករណីនេះ ដោយមិនបានទទួលលទ្ធផលខ្លឹមសារណាទេ។ គួរកត់សម្គាល់ផងដែរថា គោលបំណងនៃការជូនដំណឹងដល់ អ៊ឹម ចែម អំពីបទចោទប្រកាន់ បានសម្រេច តាមរយៈការជូនដំណឹងទៅសហមេធាវីរបស់គាត់។ ពិតណាស់ ក៏មានការចោទប្រកាន់ដែលថា អ៊ឹម ចែម មិនបានទទួលឯកសារទាំងនេះ ប៉ុន្តែអង្គហេតុដែលថា គាត់បានដាក់បណ្តឹងឧទ្ធរណ៍ជំទាស់នឹងការជូនដំណឹងអំពីបទចោទប្រកាន់ គឺបញ្ជាក់ថា គាត់បានទទួលការដឹងឮរួចហើយអំពីការជូនដំណឹងនេះ ហើយសហមេធាវីបានបំពេញភារកិច្ចវិជ្ជាជីវៈរបស់ខ្លួនដើម្បីផ្តល់ជូនគាត់នូវសំណៅមួយច្បាប់នៃឯកសារនោះ បើមិនអញ្ចឹងទេ ក៏បានជូនដំណឹងដល់គាត់អំពីខ្លឹមសារនៃឯកសារនោះដែរ។ ក្នុងករណីណាក៏ដោយ ចុងក្រោយបំផុត គ្មានអ្វីដែលរារាំងសហចៅក្រមស៊ើបអង្កេតទាំងពីររូប ឬក៏មួយរូប មិនឱ្យជូនដំណឹងដល់ អ៊ឹម ចែម ដោយផ្ទាល់អំពីបទចោទប្រកាន់ទេ ប្រសិ អ៊ឹម ចែម បង្ហាញខ្លួននៅចំពោះមុខតុលាការ។

---

[186] *សូមមើល* ដីកាសម្រេចរងការជំទាស់ កថាខណ្ឌ ៦១ ដោយ*ដកស្រង់* អត្ថបទសារព័ត៌មានដែលមានសេចក្តីដកស្រង់ពីបទសម្ភាសជាមួយ អ៊ឹម ចែម ៖ សារព័ត៌មាន ភ្នំពេញ ប៉ុស្តិ៍ *បន្ទាប់ពីចេញសាលក្រម ជនសង្ស័យខ្មែរក្រហម នៅតែមាន:* ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១៤។

[187] កំណត់សម្គាល់របស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទាក់ទងនឹងការបង្ហាញខ្លួនលើកដំបូងរបស់ អ៊ឹម ចែម ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ A150/2។ ការឆ្លើយឆ្លងអ៊ីម៉ែលរវាងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ជាមួយនឹងសហមេធាវីអន្តរជាតិ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ A150/2/2.1។

[188] *សូមមើល* លិខិតរបស់មេធាវីការពារក្តីទាក់ទងនឹងទម្រង់បែបបទនៃការប្រគល់ដីកាកោះជូនអ្នកស្រី អ៊ឹម ចែម ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ A122/5។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

44. ចុងក្រោយបំផុត ចៅក្រមដែលបានចុះហត្ថលេខាយល់ឃើញថា ច្បាស់ណាស់ ការជូនដំណឹងតាមរយៈសហមេធាវី គឺជាមធ្យោបាយមួយកាន់តែសមស្របជាងការជូនដំណឹងតាមរយៈប្រព័ន្ធផ្សព្វផ្សាយ ដែលបានលើកឡើងដោយសហមេធាវី។ ដូចបានលើកឡើងខាងលើ[189] ដំណោះស្រាយនេះអាចអនុវត្តបាន ក្នុងករណីដែលគេមិនស្គាល់ពីទីកន្លែងរបស់ជនសង្ស័យ គឺមិនមែនក្នុងករណីដែលគាត់មានមេធាវីតំណាងទេ។ ដោយពិនិត្យឃើញថា គេស្គាល់ពីទីកន្លែងរបស់ អ៊ឹម ចែម ហើយគាត់មានមេធាវីតំណាង ដែលគាត់បានតែងតាំងនោះ ការប្រគល់ជូនសហមេធាវីនូវការជូនដំណឹងអំពីបទចោទប្រកាន់ គឺជាវិធីមួយកាន់តែផ្ទាល់មែនទែនដើម្បីធានាថា គាត់បានទទួលដំណឹងអំពីបទចោទប្រកាន់។ ការធ្វើដូច្នេះក៏ធានាថាបានគោរពតាមភាពសម្ងាត់នៃឯកសារស្តីពីការដាក់ឱ្យស្ថិតក្រោមការពិនិត្យ ដែលមិនទាន់ជាឯកសារសាធារណៈទេនៅក្នុងដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី ។

45. ដោយពិនិត្យមើលបញ្ហាខាងលើ ចៅក្រមដែលបានចុះហត្ថលេខាយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនមានកំហុសទេក្នុងការសម្រេចដាក់ អ៊ឹម ចែម ឱ្យស្ថិតក្រោមការពិនិត្យដោយគ្មាន ការបង្ហាញខ្លួនលើកដំបូងតាមវិធាន ៥៧ នៃវិធានផ្ទៃក្នុង និងការសម្រេចជូនដំណឹងគាត់អំពីបទចោទប្រកាន់ប្រឆាំងគាត់ តាមរយៈឯកសារជាលាយលក្ខណ៍អក្សរប្រគល់ជូនទៅសហមេធាវី។ នីតិវិធីពិសេសនេះគឺជាវិធីមួយស្របច្បាប់ និងសមស្របដើម្បីដោះស្រាយស្ថានភាពបច្ចុប្បន្ននេះ ដែលជាស្ថានភាពមិនធម្មតា និងមិនធ្លាប់មានពីមុនមក ដូច្នេះហើយក៏មិនមានចែងនៅក្នុងច្បាប់ជាធរមាននៅ អ.វ.ត.ក ដែរ។ ដោយមិនបានរំលោភបំពានសិទ្ធិរបស់ អ៊ឹម ចែម ទេ នីតិវិធីដាក់ឱ្យស្ថិតក្រោមការពិនិត្យដែលអនុវត្តដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ធានាថាប្រយោជន៍របស់ អ៊ឹម ចែម ត្រូវបានការពារនៅក្នុងអំឡុងពេលស៊ើបសួរ ជាពិសេស ដោយអនុញ្ញាតឱ្យគាត់ចូលពិនិត្យមើលសំណុំរឿង តាមរយៈសហមេធាវីរបស់គាត់[190] ដើម្បីឱ្យស្នើសុំបំពេញកិច្ចស៊ើបសួរ[191] ស្នើសុំតទល់ជាមួយនឹងសាក្សីនានា[192] និងស្នើសុំមោឃភាពកិច្ចដំណើរការ

---

[189] *សូមមើល* កថាខណ្ឌ ៣២ ខាងលើ យោងលើវិធាន ៦១(១)(ក) *ឧទាហរណ៍* វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICTY និង ICTR។

[190] វិធាន ៥៥(៥) នៃវិធានផ្ទៃក្នុង។

[191] វិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង។

[192] វិធាន ៦០(២) នៃវិធានផ្ទៃក្នុង។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

នីតិវិធី[193]។ ការអនុវត្តនេះក៏ស្របតាមច្បាប់កម្ពុជា និងវិធាននីតិវិធីដែលបានបង្កើតនៅកម្រិតអន្តរជាតិ ដែលអនុញ្ញាតឱ្យអនុវត្តវិធានការពិសេសនៅពេលដែលដីកាបង្គាប់ឱ្យនាំខ្លួនមិនបានអនុវត្ត ទោះបីជាសាលាក្តីបានអនុវត្តវិធានការសមហេតុផលទាំងអស់ក៏ដោយ។ បន្ថែមពីលើនេះទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានអនុញ្ញាតឱ្យ អ៊ឹម ចែម ចូលរួមកិច្ចស៊ើបសួរតាមរយៈវិធានការពិសេស ដែលពិចារណាលើលទ្ធភាពមានកម្រិតរបស់គាត់នៅតុលាការ ឧទាហរណ៍ លទ្ធភាពតែតាមរយៈសហមេធាវីដែលគាត់បានតែងតាំងតែប៉ុណ្ណោះ។ តាមរយៈការអនុញ្ញាតនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានស្វះស្វែងបំពេញការងាររបស់ខ្លួនក្នុងការស្វែងរកការពិតអំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងអំឡុងពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដូច្នេះគាត់បានបំពេញកិច្ចស្ថិតនៅក្នុងដែនកំណត់នៃសមត្ថកិច្ចរបស់គាត់ ហើយទូទៅជាងនេះទៀត គឺដើម្បីប្រយោជន៍យុត្តិធម៌។ ដោយបានរំឭកដោយអង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY "យុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ មិនអាចសម្រេចតាមការខកខានរបស់បុគ្គល ឬរដ្ឋនានានោះទេ គឺត្រូវតែស្វះស្វែងសម្រេចបេសកកម្មរបស់ខ្លួនក្នុងការលាតត្រដាងការពិតអំពីអំពើដែលបានប្រព្រឹត្ត និងទុក្ខវេទនាដែលបានទទួលរង ព្រមទាំងបង្ហាញអត្តសញ្ញាណ និងចាប់ខ្លួនជនដែលត្រូវបានចោទថាជាអ្នកទទួលខុសត្រូវ"[194]។ ចៅក្រមដែលបានចុះហត្ថលេខាសន្និដ្ឋានថា ដីកាសម្រេចរងការជំទាស់ មិនមានកំហុសដែលតម្រូវឱ្យមានអន្តរាគមន៍។

46. អាស្រ័យហេតុនេះ ចៅក្រមដែលបានចុះហត្ថលេខា យល់ឃើញថា បណ្តឹងឧទ្ធរណ៍ពុំមានខ្លឹមសារឡើយ ហើយដីកាសម្រេចដែលរងការជំទាស់ ត្រូវតម្កល់ទុក។

**រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦**

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

**Oliver BEAUVALLET** **Steven J. BWANA**

[193] វិធាន ៧៦ នៃវិធានផ្ទៃក្នុង។

[194] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Karadzić និង Mladić*, IT-95-5-R61 និង IT-95-18-R61 ការត្រួតពិនិត្យឡើងវិញលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ តាមវិធាន ៦១ នៃវិធានស្តីពីនីតិវិធី និងភស្តុតាង ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ១៩៩៦ កថាខណ្ឌ ៣។